ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Nov-2015, 15:30
CMS/CFO: Sann Rada

## <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខ</u>
## <u>សាធារណៈ</u>

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

**ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៩:១៤នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម ផ្លូរិនស៍ ដេផេល វ៉ាឈិន-ម៉ុមបា
*(Judge Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក វុលគ័រ នឺលិច*(Mr. Volker NERLICH)*

លោក ផន ធឿន

លោក ប៉ៅឡូ ឡូបា *(Mr. Paolo LOBBA)*

លោក សីលា ផៃឡេន *(Mr.Sheila PAYLAN)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicholas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

**មេធាវីការពារក្តីលោក នួន ជា**

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

លោក សុន អរុណ

**មេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោក អាកធួរ វ៉ែកគែន *(Mr.Arthur VERCKEN )*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms. Marie GUIRAUD)*

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម គង់ ស្រីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ុង មុន្នីចរិយា | ខ្មែរ |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត | អង់គ្លេស |
| ចៅក្រម យ៉ា ណារិន | ខ្មែរ |
| ចៅក្រម ស៊ិន រិទ្ធ | ខ្មែរ |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ | អង់គ្លេស |
| ចៅក្រម សោម សិរិវឌ្ឍ | ខ្មែរ |
| ចៅក្រម ផ្លូរិនស៍ ម៉ុមបា | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ទាត់ ធឿន (SCW-5) | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សីៈ លោក ឆាត់ ឆឿន (SCW-5)


សួរដោយប្រធានអង្គជំនុំ ផ្តើមពីៈ......ទំព័រ ២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពីៈ......ទំព័រ ៤
សួរដោយចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត ផ្តើមពីៈ......ទំព័រ ២២
សួរដោយលោក អាកទួរ វ៉េកកែន ផ្តើមពីៈ......ទំព័រ ៥២
សួរដោយលោក គង់ សំអុន ផ្តើមពីៈ......ទំព័រ ៦៨
សួរបន្តដោយចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត ផ្តើមពីៈ......ទំព័រ ៧០
សួរដោយលោកស្រី ម៉ារី ហ្គីរូដ៍ ផ្តើមពីៈ......ទំព័រ ៧២
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពីៈ......ទំព័រ ៧៩
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពីៈ......ទំព័រ ៨៤
សួរដោយចៅក្រម ផ្លូវរិនស៍ ម៉ុមបា ផ្តើមពីៈ......ទំព័រ ៨៨
សួរដោយចៅក្រម ម៉ុង មុន្នីចរិយា ផ្តើមពីៈ......ទំព័រ ៨៩
សួរដោយចៅក្រម សោម សិរិវឌ្ឍ ផ្តើមពីៈ......ទំព័រ ៩២
សួរបន្តដោយចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត ផ្តើមពីៈ......ទំព័រ ៩៤
សួរដោយចៅក្រម យ៉ា ណារិន ផ្តើមពីៈ......ទំព័រ ៩៨
សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពីៈ......ទំព័រ ១០០
សួរដោយ ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ ផ្តើមពីៈ......ទំព័រ ១០០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៤:០៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយ!

ថ្ងៃនេះតុលាការ -- អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី (SCW-5) ទាត់ ធឿន។

ហើយអង្គជំនុំជម្រះសូមអភ័យទោសដែរ ដោយសារមានការយឺតពេលវេលាបន្តិចដោយសារស្ទះឡាន អ៊ីចឹងហើយបានជាវាមកមិនទាន់។ អ៊ីចឹងជាបន្តនេះគឺ ដល់លោកក្រឡាបញ្ជី ភាគី មេធាវីហើយនិងសាក្សីមានវត្តមានហើយឬនៅ?

**ក្រឡាបញ្ជី៖**

សូមជម្រាបប្រសាសន៍ឯកឧត្តមប្រធាន ថ្ងៃសវនាការថ្ងៃនេះ ក្រឡាបញ្ជីសង្កេតឃើញថាគ្រប់ភាគីមានវត្តមាន លើកលែងជនជាប់ចោទខាង លោក នួន ជា ដូចអត់ឃើញមានវត្តមានទេ មានលោក ខៀវ សំផន ហើយដើមបណ្តឹង -- ហើយនិងគ្រប់ភាគីខាងសហព្រះរាជអាជ្ញាជាតិអន្តរជាតិ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដោយឡែកមានដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ ចូលរួមជាលក្ខណៈបុគ្គលហ្នឹងមានចំនួន ប្រាំបួនរូប ទី១ លោក សឿន សុវណ្ណី, អ្នកស្រី សេង ស៊ីវត្ថា, អ្នកស្រី ហួ ចន្ថា, លោកស្រី សុផាន់ សុវណ្ណនី, លោក យស ផល, អ្នកស្រី ពេជ ស្រីផល, លោក ស សារិន, លោក ចៅ នី, និងលោក ស៊ូ សុទ្ធាវី។ បាទ សូមអរគុណ។

[០៩:១៦:២០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ទាក់ទងនឹងជនជាប់ចោទ នួន ជា គាត់អត់មានវត្តមាននៅពេលនេះបាទ។

**លោក សុន អរុណ៖**

ខ្ញុំបើតាមរដ្ឋបាលប្រាប់ខ្ញុំព្រឹកមិញថា លិខិតស្នាមដែលមិនមានវត្ត -- ដោយលោកនួន ជា មិនមានវត្តមាននៅទីនេះ គឺមានហេតុផលត្រឹមត្រូវ ឯកសារបានជូនដូចរាល់ពេលអ៊ីចឹង។ ប៉ុន្តែហេតុអ្វីបានជាក្រឡាបញ្ជីមិនជូនទៅលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកក្រឡាបញ្ជីបានទទួលឯកសារហ្នឹងនៅ? ឯកសារសុំ--

**ក្រឡាបញ្ជី៖**

បាទ ជម្រាបប្រសាសន៍ឯកឧត្តមប្រធាន ក្រឡាបញ្ជីបានទទួលលិខិតឯកសារកាលពីសប្ដាហ៍មុនបាទ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ អ៊ីចឹងដោយសារជនជាប់ចោទ នួន ជា គាត់ស្នើសុំលះបង់សិទ្ធិ ចូលរួមសវនាការនៅទីនេះ ហើយទៅតាមកំណត់ហេតុបញ្ជាក់សុខភាពរបស់គ្រូពេទ្យបានបញ្ជាក់ថាគាត់ មានជំងឺ ហើយនិងមិនអាចចូលរួមសវនាការដោយផ្ទាល់នៅទីនេះបាន ប៉ុន្តែគាត់អាចចូលរួមបាននៅកន្លែងឃុំខ្លួនជាន់ខាងក្រោមដី។

អ៊ីចឹងហើយអង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតឲ្យគាត់នៅបន្ទប់ខាងក្រោម ហើយសូមឲ្យខាងមន្ត្រីសោតទស្សន៍ គឺភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់គាត់ចូលរួមសវនាការពីខាងក្រោមមក។

អ៊ីចឹងជាបន្ត គឺមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី រហស្សនាម SCW-5 – ទាត់ ធឿន។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៩:៥៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

ជម្រាបសួរសាក្សី ថ្ងៃនេះគឺតុលាការអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការអញ្ជើញលោកដើម្បីចូលរួមក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងសំណុំរឿងលេខ ០០២/០១ ដែលមានជនជាប់ចោទ ខៀវ សំផន ហើយនិងនួន ជា នៅក្នុងបណ្ដឹងសាទុក្ខរបស់គូភាគី។ អ៊ីចឹងហើយតុលាការតម្រូវឲ្យលោកចូលមកផ្ដល់សក្ខីកម្ម អ៊ីចឹងតុលាការសួរអត្តសញ្ញាណរបស់លោក។

**ស៖** ហើយលោកឈ្មោះអី?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ទាត់ ធឿន បាទ។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណា ហើយនៅភូមិ ឃុំ ស្រុក ខេត្តណា?

**ឆ៖** នៅថ្ងៃ -- ខ្ញុំមិនចាំបានច្បាស់លាស់ដែរទេ ខែមករា ឆ្នាំ៥៥ នៅភូមិ--

**ស៖** លោកៗមានសេចក្ដីប្រកាសនេះហើយ? មានទេ? សេចក្ដីប្រកាសស្ដីពីអត្តសញ្ញាណដែលក្រឡាបញ្ជីបានឲ្យលោកនេះហ្នឹង។ ប្រហែលជាលោកអាចទទួល។ អ៊ីចឹងលោកពិនិត្យមើល លោកបានផ្ដិតមេដៃទទួលស្គាល់ហើយថាលោកនៅទីណា ហើយថ្ងៃខែឆ្នាំកំណើតហ្នឹង គឺមាននៅក្នុងហើយ ដូច្នេះបើសិនជាត្រឹមត្រូវហើយគ្រាន់តែពិនិត្យមើលទៅ ហើយលោកឆ្លើយតាមហ្នឹង ក៏អាចបានដែរ អត់មានបញ្ហាអីទេ អ៊ីចឹងសូមលោកបន្ត។

[០៩:២១:៤៩]

**ឆ៖** បាទ លោកប្រធាន ខ្ញុំសូមយកតាមកំណត់អត្តសញ្ញាណហ្នឹងបានផ្ដិតមេដៃទទួលយកហើយបាទ។

**ស៖** អ៊ីចឹងហើយ ប៉ុន្តែលោកបញ្ជាក់ដើម្បីមាននៅក្នុងកំណត់ត្រាប្រតិចារឹក។ អ៊ីចឹងសូមលោកឆ្លើយមក។

**ឆ៖** បាទ នៅថ្ងៃទី០១ ក្នុងខែ០១ ឆ្នាំ១៩៥៥ ខ្ញុំកើតនៅភូមិកង្កួត ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង។

**ស៖** លោកមានសញ្ជាតិជាអ្វី? ហើយមុខរបរសព្វថ្ងៃ?

**ឆ៖** ខ្ញុំសញ្ជាតិខ្មែរ មុខរបរសព្វថ្ងៃគឺធ្វើកងយុទ្ធពលខេមរភូមិន្ទ។

**ស៖** ឋានៈជាអ្វីដែរ?

**ឆ៖** ឋានៈឧត្តមសេនីយត្រី។

**ស៖** ឪពុកលោកឈ្មោះអ្វី? ម្ដាយលោកឈ្មោះអ្វី? រស់ ឬក៏ស្លាប់?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ឡឹក ទាត់ (ស្លាប់), ម្ដាយឈ្មោះ យ៉ង់ សឿម (ស្លាប់)។

**ស៖** ប្រពន្ធ? ហើយនិងមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធពីមុនខ្ញុំស្លាប់ មានកូនប្រាំ។ ប្រពន្ធក្រោយមានកូនពីរ រស់នៅសព្វថ្ងៃ។

**ស៖** ប្រពន្ធលោកឈ្មោះអីបាទ?

**ឆ៖** ប្រពន្ធដែលស្លាប់ឈ្មោះ យ៉ុង សួ។ ប្រពន្ធដែលរស់រាល់ថ្ងៃគឺ ធូ ចាន់ថន។

[០៩:២៤:០៣]

**ស៖** កូនលោកដែលក្រោយពីរនាក់ហ្នឹង គឺប្រុសប៉ុន្មាន ស្រីប៉ុន្មាន? ហើយទីលំនៅបច្ចុប្បន្នរបស់

លោកនៅឯណា?

**ឆ៖** ទីលំនៅ -- កូនប្រពន្ធនៃសព្វថ្ងៃនេះ គឺមានប្រុសមួយ ស្រីមួយ។ ហើយទីលំនៅបច្ចុប្បន្ន នៅភូមិចម្ការសំរោងពីរ សង្កាត់ចម្ការសំរោង ក្រុងបាត់ដំបង។

**ស៖** ខ្ញុំសូមប្រាប់សិទ្ធិ ហើយនិងកាតព្វកិច្ចរបស់លោកដែលជាសាក្សីក្នុងការផ្តល់សក្ខីកម្មនៅពេលនេះ។ គឺលោកមានសិទ្ធិមិនឆ្លើយទៅនឹងសំណួរ ឬក៏ធ្វើអំណះអំណាងណាមួយដែលនាំឱ្យលោកហ្នឹងមានពិរុទ្ធភាព ឬក៏មានការចោទប្រកាន់មកលើលោក។ ហើយលោកត្រូវឆ្លើយទៅនឹងសំណួរទាំងឡាយ លើកលែងតែសំណួរ ឬក៏ការធ្វើអះអាងដែលនាំឱ្យខ្លួនលោកហ្នឹងមានពិរុទ្ធភាព។ ហើយលោកត្រូវឆ្លើយនូវអ្វីដែលជាការពិតតាមការដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬក៏ហេតុការណ៍ពាក់ព័ន្ធទៅនឹងសំណួរ។ លោកធ្លាប់ឆ្លើយនៅចំពោះមុខ អ.វ.ត.ក. ពីមុនមកទេនៅចំពោះមុខអង្គ -- សហចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** បាទ ខ្ញុំបានធ្លាប់ឆ្លើយនៅ២០១៣ នៅចៅក្រមស៊ើបអង្កេត។

**ស៖** បាទ សុំម្តងទៀត។ លោកធ្លាប់បានឆ្លើយទេ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពីមុនហើយនិងក្រោយនេះ?

**ឆ៖** បាទ អត់ដែលបានឆ្លើយទេ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបន្ត សូមអញ្ជើញលោកសហមេធាវីជនជាប់ចោទ នួន ជា តាំងសំណួរដល់សាក្សី។

សូមអញ្ជើញ!

[០៩:២៦:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ។ ខ្ញុំជាសហមេធាវី--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី នៅខ្លះសំណួរដែលខ្ញុំមិនទាន់បានសួរទៅសាក្សី។

អ៊ីចឹង សូមអញ្ជើញលោកអង្គុយសិនចុះ បាទ!

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរ -- ខ្ញុំចង់សួរសំណួរមួយទៀតដែលទាក់ទងទៅនឹងសាក្សីដែរ អំពីទំនាក់ទំនងញាតិជាមួយជនជាប់ចោទទាំងពីរ ហើយនិងជាមួយដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ តើលោកធ្លាប់មានទំនាក់ទំនង -- មានទំនាក់ទំនងញាតិអ៊ីចឹងទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ គោរពលោកប្រធាន គឺទំនាក់ទំនងញាតិជាមួយនឹងជនជាប់ចោទ ខ្ញុំអត់ដែលមានទេ។

**ស៖** ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី?

**ឆ៖** បាទ ហ្នឹងក៏អត់មានដែរ បាទ។

**ស៖** ឆ្លើយម្ដងទៀត ហ្នឹងអត់ឮទេ ក្នុងមីក្រូអត់ឮទេ។

**ឆ៖** បាទ លោកប្រធាន គឺខ្ញុំអត់មានទេបាទ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមគោរពឯកឧត្តមប្រធាន សូមគោរពអង្គសវនាការទាំងមូល។ ដើម្បីឲ្យមាននៅក្នុងប្រតិចារឹក សូមឲ្យឯកឧត្តមប្រធានជួយជម្រាបសួរសាក្សីថា តើគាត់បានធ្វើសម្បថហើយឬនៅ?

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ខ្ញុំមិនបានសួរនេះដែរ។ គឺលោកបានធ្វើសម្បថហើយនៅ ពីមុនពេលដែលចូលមកហ្នឹង?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ លោកប្រធាន បានធ្វើសម្បថជាមួយតាដំបងដែកហើយៗ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអរគុណ។ ហើយសូមអញ្ជើញលោកមេធាវីតាំងសំណួរ។ បាទ សូមអញ្ជើញ!

[០៩:២៩:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណសាជាថ្មីលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរសាជាថ្មីលោកសាក្សី។ លោកទើបតែជម្រាបជូនលោកប្រធាន អំពីឈ្មោះរបស់

លោក។ តើឈ្មោះកំណើតរបស់លោកនេះ ឈ្មោះអ្វីដែរ? ថ្ងៃខែឆ្នាំ -- នាមខ្លួនរបស់លោកៗ ឈ្មោះអី?

ប្រហែលជាមាន អាចគាត់ស្តាប់សំណួរខ្ញុំមិនបានច្បាស់ទេមើលទៅ។ ខ្ញុំនឹងសួរសំណួរខ្ញុំឡើងវិញ។ លោកអាចជម្រាបអង្គជំនុំជម្រះបានទេឈ្មោះដែលលោកប្រើនោះ កាលពីកើតមកនោះ ដាក់ឈ្មោះអីឈ្មោះកំណើតដំបូងបំផុតនោះ?

**ឆ៖** បាទ លោកមេធាវីគឺឈ្មោះកំណើតឈ្មោះ ធូ ម៉ាង។

**ស៖** តើលោកមានឈ្មោះហៅដទៃទៀតទេ? ឬក៏លោកប្រើឈ្មោះ ធូ ម៉ាង នេះជារៀងរហូតមក? ឬក៏ក្រោយមកលោកមានប្រើប្រាស់ឈ្មោះផ្សេងដែរ?

**ឆ៖** បាទ មានឈ្មោះផ្សេងក្រោយមក។

**ស៖** តើលោកអាចជម្រាបឈ្មោះផ្សេងៗទៀតដែលលោកប្រើប្រាស់ហ្នឹងបានទេ?

**ឆ៖** បាទ បាន។ ឈ្មោះដែលប្រើប្រាស់ក្រោយៗមក មានឈ្មោះ ហំ, មានឈ្មោះ ធឿន រាល់ថ្ងៃ។

**ស៖** លោកសាក្សី នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលលោកឆ្លើយជូនចៅក្រមស៊ើបអង្កេត លោកឆ្លើយថា នៅពេលមួយនោះលោកក្លាយទៅជាកូនចិញ្ចឹមរបស់ មូល សម្បត្តិ ហៅ -- កូនធម៌ របស់ មូល សម្បត្តិ ហៅ រស់ ញឹម។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ធ្វើម៉េចបានជាលោកក្លាយទៅជាកូនធម៌របស់ រស់ ញឹម?

**ឆ៖** បាទ ព្រោះខ្ញុំវាមិនដឹងថាវាយ៉ាងម៉េចដែរ ប៉ុន្តែ ខ្ញុំសុំបញ្ជាក់ថា ខ្ញុំស្គាល់ រស់ ញឹម តាំងពីឆ្នាំ ១៩៦០។ គាត់ទៅតែសម្រាកនៅផ្ទះខ្ញុំ នៅចម្ការរបស់ខ្ញុំ ពីរបីខែ គាត់ទៅពីរបីថ្ងៃ ហើយខ្ញុំជាអ្នកបម្រើគាត់តាំងពីនោះមក។ ហើយក៏ស្គាល់គាត់ ហើយក៏គោរពគាត់ដូចជាឪពុកបង្កើត។

[០៩:៣៩:១០]

**ស៖** តើមានមូលហេតុអីបានជា មូល សម្បត្តិ ហៅ រស់ ញឹម ហ្នឹងមកផ្ទះរបស់លោក? ដោយសារថាគាត់នេះលាក់ខ្លួនក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាគាត់ត្រូវ គឺថាធ្វើការលាក់ខ្លួន។ ហេតុអីបានជាគាត់មកផ្ទះរបស់លោក?

**ឆ៖** ព្រោះផ្ទះខ្ញុំវា -- ខ្ញុំមិនដឹងថាគាត់ធ្វើសមាជិកស្អីទេ ប៉ុន្តែកាលពេលហ្នឹងខ្ញុំនៅតូចៗ ហើយខ្ញុំក៏ផ្ទះខ្ញុំនៅក្នុងព្រៃ នៅក្នុងចម្ការ ចម្ការក្រូចនៅព្រៃ ដាច់ស្រយាលពីគេ។

**សៈ** តើលោកដឹងថា រស់ ញឹម មានកូន ឬមានកូនបង្កើត ឬក៏កូនធម៌ ឬក៏កូនចិញ្ចឹមអីដទៃទៀតទេ?

**ឆៈ** បាទ កូនបង្កើតគាត់មាន កូនចិញ្ចឹម កូនធម៌ដូចខ្ញុំមាន។

**សៈ** ខ្ញុំសូមសួរអំពីកូនបង្កើតរបស់គាត់វិញម្តង តើត្រឹមត្រូវទេដែលថា កូនច្បងគេបង្អស់របស់គាត់ឈ្មោះ ជាម, មួយឈ្មោះ ឆ្នាំង?

**ឆៈ** បាទកូនជាបងឈ្មោះ ជាល ហៅ ឆ្នាំង។

[០៩:៣៦:០៥]

**សៈ** តើគាត់មានកូនបង្កើតក្រៅពី ជាល ឆ្នាំង នេះទៀតទេ?

**ឆៈ** មាន ឈ្មោះ ធី, ឈ្មោះ កញ្ជែង (កូនពៅ កូនស្រី)។

**សៈ** ចុះកូនចិញ្ចឹមរបស់គាត់ តើគាត់មានកូនចិញ្ចឹមប៉ុន្មាននាក់ ហើយបើមានហ្នឹងអ្នកទាំងនោះមានឈ្មោះអ្វីខ្លះដែរ?

**ឆៈ** បាទ តាមខ្ញុំដឹងគឺមានឈ្មោះ សឿត – ឡឹក សឿត ហៅ វង់ ជាកូនចិញ្ចឹមគាត់ដែរ ហើយឈ្មោះ ខួង, ឈ្មោះ ណាម, ឈ្មោះ ធួង ជាកូនចិញ្ចឹមគាត់ដែរ។

**សៈ** ចុះកូនចិញ្ចឹមម្នាក់ទៀតឈ្មោះ ហ៊ីង?

**ឆៈ** បាទ សូមម្តងទៀត វាខ្ទរមីក្រូ ស្តាប់មិនសូវច្បាស់។

**សៈ** គាត់អាចមានកូនចិញ្ចឹមម្នាក់ទៀតឈ្មោះ ហ៊ីង តើលោកស្គាល់ដែរ ឬទេ?

**ឆៈ** បាទ មានឈ្មោះ ហ៊ីង។

**សៈ** តើ ហ៊ីង នៅពេលមួយក្នុងឆ្នាំ១៩៧៥ ដល់ ៧៩ គាត់ធ្លាប់ធ្វើជាមេបញ្ជាការកងពល នៅភូមិភាគពាយ័ព្យដែរទេ?

**ឆៈ** បាទ មានមិនច្បាស់ដែរ វាយូរឆ្នាំហើយ អ៊ីចឹងក៏មិនសូវចាំច្បាស់ តែមានធ្វើបញ្ជាការ។

[០៩:៣៩:១០]

**សៈ** តើលោកដឹងថា តួនាទីរបស់ ប៊ុន ហ្នឹងមានតួនាទីអីដែរ ចន្លោះពីឆ្នាំ១៩៧៥ ដល់ ៧៩?

**ឆៈ** បាទ សូមម្តងទៀត វាមិនច្បាស់ថា ចង់សួរន័យយ៉ាងម៉េច ខ្ញុំអត់យល់បាទ។

**សៈ** លោកតែទើបបញ្ជាក់អម្បាញ់មិញថា កូនធម៌មួយទៀតឈ្មោះ វង់ ហៅ សិដ្ឋ។ តើលោកនៅចាំថា គាត់នេះមានតួនាទីអ្វីដែរ ចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩?

**ឆ៖** បាទ ឈ្មោះ វង់, ឈ្មោះ សឿត ហៅ វង់ កាលពីចន្លោះឆ្នាំហ្នឹង គឺបញ្ជាការយោធាតំបន់៤ ក្រោយមក ក៏ទៅជាអនុប្រធានតំបន់៤។

**ស៖** លោកទើបតែនិយាយអំពីកូនច្បងបង្អស់ឈ្មោះ ជាល ហៅ ឆ្នាំង របស់ រស់ ញឹម។ តើគាត់មានតួនាទីអ្វីដែលចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩?

**ឆ៖** បាទ ឈ្មោះ ជាល ហៅ ឆ្នាំង គាត់មានតួនាទី គឺអនុប្រធានតំបន់ទី៥ ក៏មិនដឹង គឺប្រធានតំបន់ទី៥ ក៏មិនដឹង ប៉ុន្តែនៅក្នុងតំបន់ទី៥។

[០៩:៤១:៣៤]

**ស៖** តើលោកដឹងថា ជាល ហៅ ឆ្នាំង ហ្នឹង រៀបការជាមួយនារីណាដែរ? អ្នកណាដែលជាប្រពន្ធរបស់ ជាល ហៅ ឆ្នាំង នេះ?

**ឆ៖** បាទ ខ្ញុំមិនចាំបានឈ្មោះប្រពន្ធទេ ប៉ុន្តែខ្ញុំចាំបានឪពុកក្មេករបស់ ឆ្នាំង គឺ សោ ភឹម ប្រធានភូមិភាគបូព៌ាជាឪពុកក្មេក។

**ស៖** តើលោកចាំទេថា ជាល ហៅ ឆ្នាំង ភ្ជាប់ពាក្យជាមួយកូនស្រី សោ ភឹម ហ្នឹងនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងថានៅពេលណាទេ ប៉ុន្តែពេលដែលខ្ញុំដឹង គេបានចាប់ដៃគ្នាជាប្ដីប្រពន្ធហើយ។

**ស៖** តើលោកនៅចាំបានទេថា អ្នកទាំងពីរនេះ បានក្លាយទៅជាប្ដីប្រពន្ធនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ ប៉ុន្តែពេលដែលខ្ញុំដឹង ដូចខ្ញុំបញ្ជាក់ថា ក្នុងឆ្នាំ៧៨ បានខ្ញុំដឹងថា គឺជាប្ដីប្រពន្ធ មានផ្ទៃពោះហើយ។

[០៩:៤៣:២៥]

**ស៖** តើវាអាចត្រឹមត្រូវដែរឬទេ បើសិនណាជាខ្ញុំប្រាប់ទៅលោកថា ជាល ហៅ ឆ្នាំង នេះ ភ្ជាប់ពាក្យជាមួយកូនស្រី សោ ភឹម នៅក្នុងខែកក្កដា ១៩៧៥ ហើយក៏រៀបការនៅខែមករា ១៩៧៦ អាចជួយរំឭកដល់ការចង់ចាំរបស់លោកបានទេ?

**ឆ៖** បាទ ខ្ញុំមិនច្បាស់ដែរទេ បាទ។

**ស៖** តើលោកមាននៅចាំថា ហេតុអ្វីបានជាកូនប្រុសរបស់ រស់ ញឹម រៀបការជាមួយកូនស្រីរបស់ សោ ភឹម? មានមូលហេតុអីទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**សៈ** តើលោកចាំថា ឪពុកធម៌របស់លោកធ្លាប់ធ្វើដំណើរទៅកាន់ភូមិភាគបូព៌ា ដើម្បីទៅលេងទៅសួរសុខទុក្ខកូនប្រសាស្រីរបស់គាត់ នៅឆ្នាំមួយពាន់ប្រាំបួនរយ -- ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ៧៦ដែរទេ?

**ឆៈ** បាទ មាន។

[០៩:៤៥:០០]

**សៈ** តើលោកចាំបានទេថា ឪពុកធម៌របស់លោកនេះទៅលេងកូនប្រសាស្រីរបស់គាត់ញឹកញាប់ប៉ុនណាដែរ? ហើយគាត់ទៅម្តងៗហ្នឹងគាត់ស្នាក់នៅទីនោះអស់រយៈពេលប៉ុនណាដែរ?

**ឆៈ** បាទ ខ្ញុំដឹងតែគាត់ -- ដែលខ្ញុំបានដឹង គឺពេលលើកទី១ ដែលគាត់ទៅ តែមិនដឹងថាទៅលេងកូនប្រសាក៏ទៅលេងភ្ជាប់ពាក្យអី ខ្ញុំអត់ដឹងទេ។ គឺក្រោយពេលសន្និបាតនៅភ្នំពេញចប់នៅក្នុងឆ្នាំ៧៥ គាត់ក៏ចេញទៅភូមិភាគបូព៌ា ប្រហែលជាមួយអាទិត្យបានគាត់បកទៅពាយ័ព្យវិញ។

**សៈ** តើលោកកំពុងនិយាយអំពីអង្គមីទ្ទិងនៅភ្នំពេញនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ មួយខែក្រោយរំដោះទីក្រុងភ្នំពេញ?

**ឆៈ** ខ្ញុំមិនចាំបានថា រំដោះហើយមួយខែ ឬក៏ប៉ុន្មានខែទេ វាយូរពេក វាភ្លេចដែរ។ ចាំថាពេលដែលធ្វើដំណើរមកសន្និបាតហ្នឹងគឺខ្ញុំរួមដំណើរការពារមកជាមួយ កាលនោះផ្លូវជាតិលេខ៥ មិនទាន់បានធ្វើតជាប់បានទេ ពីកំពង់ឆ្នាំងមកឧដុង្គ នៅកាត់ដាច់ជាកង់នៅឡើយ ត្រូវបរវាងទៅស្រុកឯកមាសចេញតាមក្រាំងចេក ក្រាំងល្វា ឡើងមកឧដុង្គវិញ។ មិនតែប៉ុននុ៎ង ចាំបានតែប៉ុណ្ណឹងទេបាទ។

[០៩:៤៧:១៥]

**សៈ** តើលោកនៅចាំថា តើ សោ ភឹម នេះធ្លាប់បានក្លាយជា -- ធ្លាប់ -- សោ ភឹម ធ្លាប់បានធ្វើដំណើរមកភូមិភាគពាយ័ព្យដើម្បីមកលេងកូនប្រុស និងលេងកូនប្រសាស្រីគាត់ទេ?

**ឆៈ** បាទ គាត់ធ្លាប់មក ភូមិភាគពាយ័ព្យគាត់មករកកូនក្រូចពោធិ៍សាត់ដាំ។

**សៈ** ហើយនៅពេលណាដែលគាត់ធ្វើដំណើរមកភូមិភាគពាយ័ព្យដើម្បីមកសួរសុខទុក្ខកូនរបស់គាត់? តើគាត់ធ្លាប់បានប្រើប្រាស់ឱកាសមកលេងនេះ ដើម្បីមកនិយាយសំណេះសំណាលលេងជាមួយឪពុកធម៌របស់លោកឈ្មោះ រស់ ញឹម ហ្នឹងដែរឬទេ?

**ឆៈ** បាទ គាត់មកដេកនៅផ្ទះជាមួយគ្នា។ មិនដឹងថាគាត់សំណេះសំណាលនិយាយពីស្អី ខ្ញុំអត់ដឹងទេ។

**សៈ** តើលោកនៅចាំកម្មាភិបាលជាន់ខ្ពស់ដទៃទៀត ឬក៏មេបញ្ជាការយោធា ធ្លាប់បានមកចូល

រួមក្នុងអង្គប្រជុំដែល សោ ភឹម ហើយនិងឪពុកធម៌របស់លោកគាត់ប្រជុំ។ តើលោកចាំថាមានបញ្ហាការនិងកម្មាភិបាលដទៃទៀតចូលរួមដែរទេ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ គ្រាន់តែថាមាន ប៉ុន្តែខ្ញុំមិនចាំបានដោយសារវាយូរពេក។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះនៅពេលក្រោយ។ លោកសាក្សី លោកនៅចាំ សោ ភឹម បានច្បាស់ទេ? តើលោកធ្លាប់ដែលបាននិយាយលេងជាមួយ សោ ភឹម ដោយផ្ទាល់ដែរ?

[០៩:៤៩:៤២]

**ឆ៖** បាទ ខ្ញុំ -- យូរហើយខ្ញុំអាចមិនចាំច្បាស់បានទេ បើកាលពីថ្មីៗខ្ញុំនៅចាំបាន តែឥឡូវវាយូរហើយ។ ហើយការនិយាយលេងជាមួយគាត់ ខ្ញុំក៏មិនដែលបានទៅនិយាយលេងជាមួយគាត់ដែរ។

**ស៖** ឥឡូវនេះ ខ្ញុំគិតថា លោកសាក្សី លោកបានស្គាល់ឪពុកធម៌របស់លោកច្បាស់ជាង សោ ភឹម។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ អំពីឪពុកធម៌របស់លោកនេះទៅ នូវអ្វីដែលលោកចាំ? ដូចជានិយាយអំពីអត្តចរិត កាយវិការ ឥរិយាបថរបស់គាត់ជាដើម។ល។

**ឆ៖** បាទ គាត់គេហៅថា តាញឹមៗ គឺមុខគាត់ញញឹមរហូត គាត់មិនដែល ដូចថាស្តីបន្ទោសដាក់កូនចៅខ្លាំងទេ។

**ស៖** មានចំណុចអ្វីផ្សេងៗទៀតដែរ ដែលលោកត្រូវជម្រាបជូនអង្គជំនុំជម្រះបានដែរ?

**ឆ៖** បាទ សូមម្តងទៀត ខ្ញុំមិនយល់ថា ឃ្លាហ្នឹងយ៉ាងម៉េច?

**ស៖** តើលោកនៅចាំអ្វីខ្លះដែរ? ឧទាហរណ៍ ការងាររបស់គាត់ តើលោកចាំថាគាត់មានធ្លាប់ធ្វើសេចក្តីសម្រេចចិត្តផ្នែកខាងយោធានេះ ក្នុងពេលមានសង្គ្រាមនេះ តើលោកចាំអ្វីដែរ ចំពោះការធ្វើសេចក្តីសម្រេចរបស់ផ្នែកខាងកងទ័ពរបស់គាត់នាពេលនោះ?

**ឆ៖** បាទ ពីសម័យកាលនៅធ្វើសង្គ្រាម ឬក៏ក្រោយរំដោះហើយ ខ្ញុំអត់យល់ត្រង់ហ្នឹងបាទ។

**ស៖** ខ្ញុំចង់សួរទាំងពីរតែម្តង។ គឺចន្លោះពីឆ្នាំ១៩៧០ រហូតមកដល់ពេលគាត់ស្លាប់នៅខែមិថុនា ១៩៧៨។

[០៩:៥២:៣៦]

**ឆ៖** បាទ នៅក្នុងពេលសង្គ្រាមពីឆ្នាំ៧០ គាត់នៅភ្នំ គេហៅភ្នំធំ មានភ្នំធំនៅក្នុងក្រុង ភ្នំធំនៅជាប់ភ្នំក្រវាញ ហៅថា មន្ទីរលេខ២០។

**ស៖** ខ្ញុំនឹងសួរអំពី រស់ ញឹម នេះ នៅពេលក្រោយបន្ថែមទៀត។ សំណួរមួយចុងក្រោយអំពីបញ្ហា

រស់ ញឹម ប៉ុន្តែ ក្រុមមេធាវីការពារក្តី នួន ជា នេះ ព្យាយាមពីរបីឆ្នាំមក ហើយដើម្បីស្វែងរករូបថតឪពុកធម៌របស់លោក។ ហើយមកដល់ពេលនេះ ក្រុមមេធាវីការពារក្តីយើងខ្ញុំនេះ មិនមានឱកាសទទួលបានរូបថតរបស់ រស់ ញឹម ទេ។ តើលោកមាននៅសល់ រូបថតរបស់ រស់ ញឹម ខ្លះដែរទេ?

**ឆ៖** បាទ គឺខ្ញុំអត់មានទេ ប៉ុន្តែកាលពីឆ្នាំ៧៩ ដែលខ្ញុំបាននាំកងទ័ពវៀតណាមវាយដល់ព្រំដែនដល់កោះកុងអីចប់សព្វមុខហើយ ខ្ញុំបានមកឃើញរូបថតគាត់មាននៅទួលស្លែង នៅបន្ទប់លេខបី ចុងខាងជើងគេបន្ទប់លេខបី គេដាក់ រស់ ញឹម អ៊ីចឹងតែម្តង។ រូបថតគាត់ប្រហែលជា ១៨ ឬ ១០ -- ១២ គុណ១៤ ប្រហែលប៉ុណ្ណឹង។ ហើយប្រពន្ធគាត់នៅបន្ទប់៣០ជាង ខ្ញុំមិនចាំបានវាយូរឆ្នាំពេក នៅបន្ទប់៣០ជាង បីកូនតូច គឺកូនពៅ គេបិទនៅនឹងជញ្ជាំងបន្ទប់ ដែលដាក់ម្នាក់ៗហ្នឹងឯង។ ហើយនៅបិទនៅហ្នឹងគឺមានរូប ហ៊ូ យន់, ហ៊ូ នឹម មក បន្ទប់គាត់ បន្ទប់ទី៣ហ្នឹងគឺ រស់ ញឹម។ បាទ ដល់ក្រោយមកខ្ញុំទៅទៀត បាត់ទៅ មិនដឹងថាអ្នកណាគេបកយកបាត់ទៅ។

[០៩:៥៥:២៨]

**ស៖** ខ្ញុំជឿជាក់ថា រូបថតនេះនៅតែមិនទាន់រកឃើញនៅឡើយ។ ពីខាងភូមិភាគពាយ័ព្យវិញ លោកនៅស្គាល់ឈ្មោះ ហេង ទាវ ហៅ តាប៉ែត ហៅ តាកន្ទុល ដែរទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** ចុះលោកនៅនឹកឃើញអ្វីខ្លះដែរអំពីឈ្មោះនេះ?

**ឆ៖** បាទ កាលនោះគាត់ជាសមាជិករបស់ភូមិភាគពាយ័ព្យ។

**ស៖** តើគាត់ជាមនុស្សដែលមានឋានៈលេខ២ នៅភូមិភាគពាយ័ព្យមែនទេ?

**ឆ៖** បាទ គាត់មនុស្សលេខ៤ នៅភូមិភាគពាយ័ព្យ។

**ស៖** តើក្រោយមក គាត់ក្លាយទៅជារដ្ឋមន្ត្រីនៃរបប ហេង សំរិន របបសាធារណរដ្ឋប្រជាមានិតកម្ពុជា១៩៧៩ ដែរទេ?

**ឆ៖** ក្រោយឆ្នាំ១៩៧៩ គាត់បានរួចចេញពីគុកច្បារមន ដែលកងទ័ពទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិវាយរំដោះទៅ គាត់បានទៅ ហើយគាត់បានចូលធ្វើការមកវិញនៅក្នុងរដ្ឋកម្ពុជារហូតដល់គាត់ចូលនិវត្ត រហូតដល់គាត់ស្លាប់នៅឆ្នាំ៨៧ -- ៨៥ បាទ។

**ស៖** តើលោកធ្លាប់ធ្វើការជាមួយគាត់ទេ លោកដូចជាថាធ្លាប់ធ្វើជានីរសារអីជាដើម ធ្លាប់ទេ?

[០៩:៥៧:៤៦]

**ឆ៖** បាទ ជានីរសារគឺវា -- ខ្ញុំជានីរសារ។ វាធ្លាប់ទាំងអស់ហ្នឹងឯង រត់ពីតាមួយ យកទៅតាមួយ តាមួយទៅតាមួយៗ គឺធ្លាប់ទាំងអស់ ទាំងតាប៉ែត ហៅតាកន្ទុល, ទាំងតាភឹង ហៅ កឺ, ទាំងតាគុំ តាសាយ។ បាទ ខ្ញុំជាអ្នកនីរសារ រត់សំបុត្រទៅមកបាទ។

**សៈ** លោកសាក្សី តើតាប៉ែត ហៅតាកន្ទុល ឬក៏ហៅ -- ហើយក៏ហៅឈ្មោះក្រៅថា ហេង ទាវ គឺជាមនុស្សលេខ៤ នៅភូមិភាគពាយ័ព្យ ឬក៏អត់ ដោយសារថាឪពុកធម៌របស់លោកនេះគាត់មានឋានៈលេខ១ ហើយតាកន្ទុលឋានៈលេខ៤ ចុះអ្នកណាដែលមានឋានៈលេខ២ និងលេខ៣?

**ឆ៖** ឋានៈលេខ២ គឺតាកឺ – តាភឹង ហៅថាកឺ, ឋានៈលេខ៣ តាគុំ។

**សៈ** បាទ សូមអរគុណលោកសាក្សី។ លោកសាក្សី ខ្ញុំសូមអាននូវសម្រង់ខ្លីមួយដែលជាចម្លើយរបស់កម្មាភិបាលភូមិភាគពាយ័ព្យ។ ហើយខ្ញុំ -- ក្រោយពេលដែលខ្ញុំអានឲ្យលោកស្ដាប់ហើយ ខ្ញុំចង់ឲ្យលោកឆ្លើយតប តើលោកយល់យ៉ាងដូចម្ដេចដែរ?

ឯកឧត្តមប្រធាន ខ្ញុំមានចេតនាយោងទៅលើសំណួរ-ចម្លើយទី១៦នៃឯកសារ E319/13.3.58, អង់គ្លេសមានលេខ 00970468, បារាំងមានលេខ 00974762 និងភាសាខ្មែរមានលេខ 00947282។

ដូច្នេះ លោកសាក្សី សំណួរដែលសាកសួរទៅលើកម្មាភិបាលនេះ គឺមានដូចតទៅនេះ៖ "តើលោកដឹងទេអំពីតួនាទី តាហេង?" ហើយកម្មាភិបាលនេះឆ្លើយថា៖ "តាហេង ទាវ គឺជាអនុប្រធានភូមិភាគពាយ័ព្យ គាត់ក៏ទទួលខុសត្រូវលើតំបន់១។ ប៉ុន្តែ តាសាយ គឺជាប្រធានតំបន់១។ ពួកគាត់គឺជាមនុស្សដែលមានអំណាចធំជាងគេពីរនាក់នៅក្នុងភូមិភាគ ហើយតាញឹម ហៅ កៅ ហើយនិង តាហេង ទាវ ហៅ តាប៉ែត។ តាញឹម គឺជាមនុស្សកាច់សាហាវ។ ចំណែក តាហេង ទាវ គឺជាមនុស្សស្លូតបូត។ នៅក្នុងឆ្នាំ៥៦ តាកៅ ហើយនិង តាប៉ែត ត្រូវបានគេហៅទៅ ដោយសារតែមានការប្រកាសឲ្យចាប់ខ្លួនពួកគាត់ទាំងពីរ។ ការប្រកាសបានបញ្ជាក់ថា ប្រសិនបើអ្នកណាអាចចាប់ តាញឹម បុគ្គលនោះអាចទទួលបានលុយប្រាក់ -- ទឹកប្រាក់ ៩០.០០០រៀល។ ហើយអ្នកណាអាចចាប់ តាហេង ទាវ បានទទួលបានទឹកប្រាក់ ៨០.០០០រៀល។ តាហេង ទាវ នៅរស់រានមានជីវិតក្រោយឆ្នាំ៧៩ ហើយគាត់ក្លាយជារដ្ឋមន្ត្រីសហជីពនៅក្នុងរបប ហ៊ុន សែន, ហេង សំរិន។" តើលោកសាក្សី អ្វីដែលកម្មាភិបាលភូមិភាគពាយ័ព្យបានរៀបរាប់ដូចដែលខ្ញុំបានអានជូនលោកស្ដាប់ហ្នឹងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ?

[១០:០២:០៨]

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោលលោកប្រធាន។ ខ្ញុំដឹងថាសាក្សីនេះកើតនៅឆ្នាំ៥៥ ហើយចម្លើយនេះគឺនិយាយយោងទៅលើហេតុការណ៍ឆ្នាំ៥៦។ ដូច្នេះ នៅពេលនោះសាក្សីគាត់មានអាយុទើបតែ១ឆ្នាំប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចង់ឲ្យមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់អំពីពេលវេលា។

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់ប្រហែលជាធ្លាប់ស្តាប់ឮហេតុការណ៍នេះនៅពេលក្រោយ។ ខ្ញុំមិនបានសួរជាក់លាក់អំពីហេតុការណ៍ឆ្នាំ៥៦ នោះទេ។ ខ្ញុំគ្រាន់តែសួរពិសេសថា តើៗការដែលគេនិយាយថា តាញឹម ជាមនុស្សកាច ចំណែក តាហេង ទារ ជាមនុស្សស្លូតហ្នឹង វាត្រឹមត្រូវឬក៏មិនត្រូវ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះ ខ្ញុំសួរឡើងវិញ លោកសាក្សីថាតើ កម្មាភិបាលដែលបញ្ជាក់ថា តាញឹម ជាមនុស្សកាច់ ចំណែក តាហេង ទារ ជាមនុស្សស្លូតយ៉ាងម៉េចដែរ? ត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ តាប៉ែត ហៅ តាកន្ទុល ហ្នឹង ហើយ តាហេង ទារ ហ្នឹង គឺគាត់មនុស្ស ហៅថារបៀបគាត់ -- ចរិតរបស់គាត់ជាអ្នកបួស ឬក៏អ្នកសិល្ប: គាត់មិនកាចទេ។ ហើយ តាញឹម ពេលមួម៉ៅ ពេលកាចម្តងៗ ពេលដែលឈឺ ពេលដែលគាត់ឈឺជំងឺក្នុងមាត់ ដំបៅមាត់។

**ស៖** លោកសាក្សី តើឈ្មោះ ស៊ុវ ហេង ធ្វើឲ្យលោកនឹកឃើញអ្វីដែរ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ។

**ស៖** ប្រហែលជាខ្ញុំអានមិនត្រូវ ប៉ុន្តែ ស៊ុវ ហេង គឺជាអ្នកបង្កើតបក្សកុម្មុយនីស្តកម្ពុជា។ តើលោកចាំទេ? តើលោកនឹកឃើញទេ?

[១០:០៤:៥១]

**ឆ៖** ខ្ញុំបាទ ខ្ញុំឮតៗតែពីឪចិញ្ចឹមនិយាយអ៊ីចឹងដែរ។

**ស៖** លោកសាក្សីដែលអាចថាអ្នកបង្កើតបក្សកុម្មុយនីស្តកម្ពុជាមួយនេះ ត្រូវបានគេសម្លាប់ភ្លាមៗក្រោយឆ្នាំ៧៥។ តើលោកដឹងទេថា តើឪពុកធម៌ -- ឪពុកចិញ្ចឹមរបស់លោកមានអ្វីពាក់ព័ន្ធទៅនឹងការសម្លាប់គាត់នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** ស៊ីវ ហេង គឺជាសាច់ញាតិរបស់ នួន ជា គឺកូនក្ដីរបស់ខ្ញុំ។ តើលោកចាំអំពីឈ្មោះ នួន ជា នេះដែរទេ?

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះ ខ្ញុំក៏មិនដែលបានជួបផ្ទាល់គាត់ដែរ។

**ស៖** មុននឹងខ្ញុំបន្តទៅមុខទៀត ឥឡូវនេះ ខ្ញុំចង់សួរលោកបន្តិចនូវសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការងាររបស់លោកក្រោយឆ្នាំ៧៩។ តើវាត្រឹមត្រូវដែរឬទេ ដែលថាលោកទៅសិក្សានៅសហភាពសូវៀតនៅក្នុងទសវត្សរ៍ឆ្នាំ៨០?

**ឆ៖** បាទ ខ្ញុំទៅក្រោយពេលដែលរំដោះហើយ ខ្ញុំនៅក្នុងកងយុទ្ធពលខេមរភូមិន្ទ។ កាលហ្នឹងងារជាកងទ័ពរដ្ឋកម្ពុជា ខ្ញុំបានទៅរៀននៅសហភាពសូវៀតពិតប្រាកដមែនបាទ។

**ស៖** តើលោករៀននៅសហភាពសូវៀតអស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** បាទ រយៈពេលដែល១៨ខែ។ នៅនោះគេគិតម៉ោង មេរៀនណាប៉ុន្មានរយម៉ោងៗ អស់មេរៀនគ្រប់ម៉ោងមកវិញ។

**ស៖** តើលោកសិក្សាហ្នឹងសិក្សានៅសាលាបណ្ឌិតសភាយោធាមែនទេ?

**ឆ៖** បាទ សាលានាយទាហានជាន់ខ្ពស់នៅមូស្គូវ៉ា នៅមូស្គូស្កាយ៉ា បាទ។

[១០:០៨:២៥]

**ស៖** តើលោកចាំទេថា លោកសិក្សានៅសាលាយោធាជាន់ខ្ពស់ហ្នឹងចន្លោះពីឆ្នាំណាដល់ឆ្នាំណាដែរ?

**ឆ៖** បាទ ឆ្នាំ៨០ ចុងឆ្នាំ៨០បាទ មិនដឹង ប្រហែលជាជិតពាក់កណ្ដាល ឬក៏ចុងឆ្នាំ៨០ ដល់ឆ្នាំ៨៣។

**ស៖** ដូច្នេះ នៅប្រទេសសូវៀតទេ នៅពេលដែលប្រធានាធិបតី ប្រេសនិក *(Brejnev)* បានស្លាប់នៅសូវៀតនោះ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ កាលហ្នឹងវាប្រហែលជាតា ប្រេសនិក ហ្នឹងឯងជាប្រធានាធិបតី។

**ស៖** ហើយនៅពេលដែលលោកត្រឡប់មកពីសូវៀតវិញ លោកនៅបន្តធ្វើការជាយោធាតទៀត។ ដូច្នេះ តើលោកអាចរៀបរាប់អំពីអាជីពការងារជាកងទ័ពក្រោយពេលដែលលោកត្រឡប់មកពីសូវៀតបានទេ?

[១០:១០:១០]

**ឆ៖** បាទ ខ្ញុំចេះមេរៀន។ និយាយរួមគឺទៅរៀនគ្រាន់តែបំពេញបន្ថែម។ អាជីពយោធា គឺវាយមិនឲ្យខ្មែរក្រហមយកទឹកដីវិញបាន មិនឲ្យយកភូមិឃុំវិញបាន។ បាទ ខាងផ្នែកពាយ័ព្យ គឺបាត់ដំបង សៀមរាប ពោធិ៍សាត់ ខេត្តបន្ទាយមាន គឺបន្ទាយមានជ័យ។

**ស៖** តើនៅពេលណា -- នៅក្រោយមក នៅពេលណាដែលលោកក្លាយជាឧត្តមសេនីយ៍ត្រី?

**ឆ៖** បាទ គឺឆ្នាំ២០០១។

**ស៖** ចន្លោះពីឆ្នាំ៧៩ ដល់ ២០០១ហ្នឹង តើលោកធ្លាប់ធ្វើជាមេបញ្ជាការនៅមន្ទីរសន្តិសុខមួយដែលគេហៅថា ប-២ ឬក៏ តេ-៦ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលធ្វើទេ។

**ស៖** តើលោកធ្លាប់ឮឈ្មោះមន្ទីរនេះដែរឬទេ?

**ឆ៖** បាទ ធ្លាប់ឮ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី។ ខ្ញុំនឹងនិយាយអំពីឆ្នាំ៧០ ដល់ ៧៩ ដោយសាររបៀបពេលវេលាខ្លី។ ដូច្នេះ ខ្ញុំសូមសង្ខេបនូវតួនាទីរបស់លោក ហើយបើសិនខ្ញុំនិយាយខុស សូមលោកនិយាយប្រាប់ខ្ញុំឲ្យខ្ញុំកែតម្រូវ។ លោកចូលទាហានក្រោយរដ្ឋប្រហារ នៅខែមីនា ឆ្នាំ៧០ បន្ទាប់មកទៀតលោកក្លាយទៅជាអ្នកប្រយុទ្ធក្នុងកងទ័ពខ្មែរក្រហម លោកធ្វើការជានីរសារ ហើយមាន -- ហើយនៅពេលមួយលោកបានក្លាយជាប្រធាននីរសារ ក្រោយមកទៀតលោកក្លាយជាអនុប្រធានសេនាធិការនៃភូមិភាគពាយ័ព្យ ហើយក្រោយមកទៀតគេបញ្ជូនលោកទៅប្រទេសចិន ដើម្បីរៀន -- ដើម្បីបណ្ដុះបណ្ដាលក្លាយខ្លួនអាកាសយានិកប្រហែលជាក្នុងឆ្នាំ៧៦។ តើអ្វីដែលខ្ញុំសង្ខេបអំពីការងាររបស់លោកក្នុងរយៈពេលពីមុន រហូតដល់ពេលលោកធ្វើដំណើរទៅប្រទេសចិនហ្នឹង តើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ។

[១០:១៥:00]

**ស៖** តើលោកបានក្លាយជាបក្ខជន ឬក៏បក្ខជនពេញសិទ្ធិនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ហើយប្រសិនបើលោកក្លាយជាសមាជិក ឬក៏ក្លាយជាបក្ខជនមែន តើនៅពេលណា?

**ឆ៖** បាទ ខ្ញុំអត់បានចូលបក្សហ្នឹងគេទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្ថែមទៀត ពាក់ព័ន្ធទៅនឹងតួនាទីយោធារបស់លោក។ លោកបានបញ្ជាក់ថា លោកគឺជាអ្នក -- គឺជាយុទ្ធជនចន្លោះ៧០ ដល់ ៧៥។ តើលោកធ្លាប់ចូលរួមនៅក្នុងការ

ប្រយុទ្ធជាមួយនឹងទាហានរបស់ លន់ នល់ ដែរឬទេ?

**ឆ៖** មានធ្លាប់ដែរ។

**ស៖** តើលោកអាចរៀបរាប់ដោយសង្ខេបអំពីតួនាទីរបស់លោកនៅក្នុងការប្រយុទ្ធទាំងនេះ បានដែរឬទេ?

**ឆ៖** បាទ ក្នុងការប្រយុទ្ធ ខ្ញុំជានីរសារបញ្ជាការសមរភូមិ។ នីរសារស្តាំ បានន័យថាខាងស្តាំដៃរបស់មេបញ្ជាការ គឺផ្នែកទាក់ទង រត់ពីចុងស្លាបខ្សែត្រៀមមកដល់មេបញ្ជាការ ពីមេបញ្ជាការទៅចុងស្លាបខ្សែត្រៀមខាងស្តាំដៃ។ ប្រយុទ្ធឡើងទៅមុខ គឺថយក្រោយ។ មេបញ្ជាការប្រាប់ខ្ញុំ ខ្ញុំនឹងផ្សព្វផ្សាយ។ នីរសារ គឺរត់ទៅផ្សព្វផ្សាយ។

[១០:១៦:២៤]

**ស៖** តើការណ៍នេះមានន័យថា នៅពេលនោះ លោកដឹងច្បាស់អំពីព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងសមរភូមិដែរឬទេ ពីចន្លោះឆ្នាំ៧០ ដល់ ៧៥នោះ?

**ឆ៖** បាទ វានៅសមរភូមិ វាកំណាត់ៗ ខ្ញុំដឹង មានមួយកំណាត់ ខ្ញុំអត់ដឹង។ ពេលខ្ញុំរត់សាររត់សំបុត្រនៅមន្ទីរលើ ខ្ញុំអត់បានចូលរួមសមរភូមិទេ។ ពេលដែលត្រូវអន្តរាគមន៍ជួយដល់សមរភូមិ គឺខ្ញុំត្រូវចុះមកជួយ។ អ៊ីចឹង វាមានកំណាត់ៗ។ ដូចជាសមរភូមិវាយយកស្រុកលាច ស្រុកភ្នំក្រវាញ ហ្នឹងខ្ញុំចុះមក។ មកភូមិវាយយកបំណាក់កំរែង ទៅវែរមាស ខ្ញុំចុះមកជួយ បាទ ប៉ុណ្ណឹង។

**ស៖** តើលោករាយការណ៍ផ្ទាល់ទៅឪពុកចិញ្ចឹមរបស់លោក គឺ តាញ៉ឹម ឬមួយក៏លោករាយការណ៍ទៅអ្នកផ្សេងទៀត?

**ឆ៖** ពេលចប់ៗ ខ្ញុំបកទៅកន្លែងខ្ញុំវិញ ខ្ញុំរាយការណ៍ជូនគាត់។ តែមុននឹងទៅកន្លែង ខ្ញុំរាយការណ៍ មេសមរភូមិ គេរាយការណ៍ទៅគាត់ហើយៗ។

**ស៖** ខ្ញុំនឹងជជែកពីចំណុចនេះបន្ថែមទៀតនៅពេលក្រោយ។ តើលោកក្លាយជាប្រធាននីរសារនៅពេលណា?

**ឆ៖** បាទ សូមម្តង ខ្ញុំស្តាប់មិនច្បាស់។

**ស៖** តើលោកចាំទេថា លោកក្លាយទៅជាប្រធានរបស់នីរសារនៅពេលណា?

**ឆ៖** បាទ ក្នុងចន្លោះឆ្នាំ៧៣ ក្នុងអំឡុងប៉ុណ្ណឹង តែមិនដឹងខែណាទេ។

[១០:១៩:២៥]

**ស៖** សូមបន្តទៀត ប្រសិនបើលោកចង់និយាយលោកសាក្សី។ បាទ ខ្ញុំសូមសួរលោកបន្តទៀត តើលោកចាំទេ ថាតើមាននីរសារប៉ុន្មាននាក់ដែរ នៅក្រោមការការដឹកនាំរបស់លោក? តើមាននីរសារប៉ុន្មាននាក់ដែលរាយការណ៍ជូនលោក? ហើយលោកប្រធាននីរសារនោះ តើប្រធានទៅលើមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំប្រធាននីរសាររត់ផ្លូវឆ្ងាយ។ ផ្លូវឆ្ងាយ បានន័យថាពីភូមិទៅតាមតំបន់។ អ៊ីចឹងមានគ្នាបីនាក់ ខ្ញុំប្រធាន។

**ស៖** នៅក្នុងការវាយប្រយុទ្ធចុងក្រោយនៅពោធិ៍សាត់នៅបាត់ដំបង ស៊ីសុផុន ប៉ៃលិននៅក្នុងដើមឆ្នាំ៧៥នោះ តើនៅក្នុងពេលវាយប្រយុទ្ធហ្នឹងលោកគឺជាប្រធាននីរសារដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅតែនីរសាររត់ពីបញ្ជាការសមរភូមិមុខមកមន្ទីរលេខ២០ខាងក្រោយ។

**ស៖** ដូច្នេះ លោកក៏ចូលរួមយ៉ាងសកម្មនៅក្នុងការវាយប្រយុទ្ធនៅខេត្តពោធិ៍សាត់ដែរ។ អ៊ីចឹងពេលដែលមានការវាយប្រយុទ្ធនៅក្នុងខេត្តពោធិ៍សាត់ឆ្នាំ៧៥ លោកនៅជាប្រធាននីរសារអ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅជានីរសារ។

**ស៖** ខ្ញុំនឹងនិយាយនៅពេលក្រោយបន្តិចទៀត ទាក់ទងនឹងការវាយប្រយុទ្ធនៅពោធិ៍សាត់ បាត់-ដំបង ប៉ុន្តែឥឡូវនេះ ខ្ញុំចង់និយាយអំពីការងាររបស់លោកជាយោធាបន្ត។ លោកបានបញ្ជាក់ថា លោកបានក្លាយទៅជាអនុប្រធានសេនាធិការតំបន់ -- សេនាធិការភូមិភាគ ហើយខ្ញុំបានអាននូវចម្លើយមួយដែលថាលោកទទួលខុសត្រូវលើឃ្លាំង -- លោកទទួលខុសត្រូវលើភស្តុភារ ហើយលោកទទួលខុសត្រូវលើការដាំដុះស្រូវនៅក្នុងយោធា។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំសង្ខេបទៅលើតួនាទីរបស់លោកក្នុងនាមជាអនុប្រធានសេនាធិការភូមិភាគ។ តើខ្ញុំសង្ខេបអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១០:២២:៤៥]

**ស៖** តើលោកចាំទេថា លោកក្លាយទៅជាអនុប្រធានសេធិការភូមិភាគនៅពេលណា? ខ្ញុំគិតថាៗប្រហែលជាឆ្នាំ៧៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនចាំបានច្បាស់លាស់ទេ ប៉ុន្តែប្រហែលជាក្នុងឆ្នាំ៧៥ហ្នឹងឯង ក្រោយពេលដែលយន្តហោះរបស់សៀមទម្លាក់គ្រាប់បែកនៅសៀមរាបបានពីរថ្ងៃ បានតែងតាំងខ្ញុំឡើងសេនាធិការរងភូមិភាគ ទទួលបន្ទុកដឹកជញ្ជូនអាវុធចេញពីការដ្ឋានចម្ការចេកយកទៅលាក់នៅក្នុងព្រៃ។

**សៈ** តើវាជាការត្រឹមត្រូវដែរឬទេ ដែលថាការវាយប្រហារដោយយន្តនៅលើខេត្តសៀមរាបហ្នឹងគឺក្នុងខែកុម្ភៈ ឆ្នាំ៧៦? ប៉ុន្តែលោកបានបញ្ជាក់រួចហើយថា លោកទៅប្រទេសចិននៅខែមករា ឆ្នាំ៧៦ ដូច្នេះ ខ្ញុំចង់ដឹងច្បាស់ថា តើលោកក្លាយទៅជាសេនាធិការរងនៃភូមិភាគហ្នឹងនៅឆ្នាំណាដែរ?

**ឆៈ** បាទៗ ខ្ញុំសូមរំឭកកន្លែងនេះឡើងបន្តិច គឺខុសត្រង់ណេះបន្តិច។ ពេលដែលយន្តហោះសៀមវាយនៅអូរឡាក់ ច្រឡំទម្លាក់នៅសៀមរាប។ យន្តហោះសៀមទម្លាក់ -- យន្តហោះទម្លាក់ បាញ់ទម្លាក់ -- ទម្លាក់គ្រាប់បែក និងបាញ់នៅអូរឡាក់ៗ អូរជ្រៅ ប៉ៃលិន មិនមែនសៀមរាបទេ សូមទោសបាទ និងនៅភ្នំឆត្រ បាញ់នៅតាមព្រំដែន ទម្លាក់គ្រាប់បែកតាមព្រំដែន។

**សៈ** ប៉ុន្តែលោកមិនចាំច្បាស់អំពីខែ ដែលលោកក្លាយជាអនុសេនាធិការហ្នឹងទេមែនទេ?

[១០:២៥:២០]

**ឆៈ** បាទ អំពីខែខ្ញុំមិនច្បាស់នោះទេ ប៉ុន្តែដឹងថាក្នុងរដូវ ពេលបកពីសន្និបាតនៅភ្នំពេញទៅក្រោយពីប្រធានភូមិភាគ ប្រធាន អនុប្រធានអីសន្និបាតចប់។ ក្រៅពី តាញ៉ឹម ទៅ ពីប៉ូពតបានតែងតាំងខ្ញុំឲ្យទៅអនុប្រធាន ហើយទទួលបន្ទុកការដ្ឋានហ្នឹង ហើយនិងសំខាន់ គឺប្រមូលគ្រាប់អាវុធទាំងនៅពេលសង្គ្រាម និងជយភណ្ឌដែលប្រមូលបានពីសង្គ្រាមទុកដាក់ ធ្វើឃ្លាំងទុកដាក់ឲ្យឆ្ងាយផុតពីក្រុង។

**សៈ** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហានេះនៅពេលក្រោយលោកសាក្សី ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកអំពីបញ្ហាមួយទៀតក្នុងនាមលោកជានាយសេនាធិការរង គឺមានសាក្សី -- គឺមានមនុស្សម្នាក់មកឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត ដែលថា តាហាំ ក្លាយទៅជាអនុប្រធានតាឃ្លាំង។ តើលោកជាអ្នកប្រធានរបស់ ឃ្លាំង ដែលជានាយសេនាធិការយោធាដែរឬទេ?

**ឆៈ** បាទ ខ្ញុំស្តាប់អត់ច្បាស់ សូមអានម្តងទៀតបាទ។

**សៈ** នៅពេលដែលលោកក្លាយជានាយសេនាធិការរង តើលោករាយការណ៍ទៅ តាឃ្លាំង ដែលជាសេនាធិការដែរឬទេ? តើលោកជាគឺជាអនុរបស់ ឃ្លាំង ដែរឬទេ?

**ឆៈ** បាទ គឺការរាយការណ៍ទុកដាក់អាវុធ គ្រាប់ទាំងអស់ គឺខ្ញុំរាយការណ៍ឲ្យតែ តាញ៉ឹម ទេ។

**សៈ** ហេតុអ្វីបានជាលោករាយការណ៍តែ តាញ៉ឹម? ហេតុអ្វីបានដូចជាលោកមិនរាយការណ៍ទៅ ឃ្លាំង ដែលជាមេរបស់លោកនោះ? ហេតុអីត្រូវរាយការណ៍ទៅ តាញ៉ឹម វិញ?

[១០:២៨:១៥]

**ឆៈ** ព្រោះការងារនេះ តាញ៉ឹម អ្នកប្រគល់ឲ្យខ្ញុំ មិនអាចរាយការណ៍ទៅអ្នកមិនបានប្រគល់

ភារកិច្ចឲ្យខ្ញុំទេ។

**ស៖** លោកបាននិយាយៗរួចហើយ ដូច្នេះខ្ញុំនឹងសួរលោកបន្ថែមបន្តិចទៀត។ លោកនិយាយនៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេត លោកថា មានម្តងហ្នឹងលោកប្រមូលអាវុធប្រហែលជា ២០.០០០ដើម ជាអាវុធរបស់យោធា ហើយលោកបានទុកអាវុធនោះ ហើយលោកបានទទួលស្គាល់ថា លោកជាអ្នកប្រមូលអាវុធ។ ដូច្នេះ ខ្ញុំចង់សួរថាលោកទុកអាវុធហ្នឹងនៅកន្លែងណា ហើយហេតុអ្វីបានជាវាចាំបាច់ត្រូវប្រមូលអាវុធទុក ស្តុកទុកបែបនេះ?

**ឆ៖** បាទ អាវុធនេះ គឺអាវុធដែលបានពីទាហាន លន់ នល់។ អាវុធជាជយភណ្ឌ ទៅលាងដាក់ប្រេង លាបខ្លាញ់ ធ្វើឃ្លាំងទុក។

**ស៖** នៅក្នុងចម្លើយជូនអ្នកស៊ើបអង្កេត គឺថាលោកបាន លោកយកអាវុធនេះទៅទុកនៅក្នុងឃ្លាំងធ្វើពីឫស្សីមួយនៅជិតភ្នំវាយចាប។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ធ្វើដាក់នៅជិតភ្នំវាយចាបពិតប្រាកដមែន ប៉ុន្តែមិនធ្វើពីឫស្សីទេ។ ប្រហែលជាអ្នកសរសេរហ្នឹង ឬក៏អ្នកអានយ៉ាងម៉េចទេ គឺថាធ្វើនៅក្នុងព្រៃឫស្សី។ គឺឃ្លាំងអាវុធហ្នឹងនៅក្នុងព្រៃឫស្សី។

**ស៖** ប្រហែលជា -- ខ្ញុំនិយាយថាដូចដែរ ប្រហែលជាមានបញ្ហាបកប្រែ។ លោកសាក្សី លោកចាំទេថាពេលណាដែលលោកចាប់ផ្តើមយកអាវុធទៅទុកនេះ? នៅពេលណាជាក់លាក់នោះ? ខ្ញុំដឹងថាតាញឹម នេះ គឺថាបានបញ្ជាឲ្យយកអាវុធនេះទៅទុក។

[១០:៣១:១៦]

**ឆ៖** បាទ គឺពេលវេលាខ្ញុំមិនចាំបានជាក់លាក់ទេ វាយូរឆ្នាំពេក។ តែគ្រាន់ដឹងថា ក្រោយពីពេលដែលគាត់ទៅពីសន្និបាតភ្នំពេញវិញ។

**ស៖** តើមានមូលហេតុអីដែលគាត់ឲ្យលោកប្រមូលអាវុធ ២០.០០០ដើម ពីអតីតទាហាន លន់ នល់ យកទៅទុកហ្នឹង? តើគាត់មានបានប្រាប់លោកថាយ៉ាងម៉េចដែរ?

**ឆ៖** បាទ គឺគាត់ -- បញ្ហាមូលហេតុ គឺអាវុធហ្នឹងវាមិនបានលាបលាងប្រេង លាបខ្លាញ់។ អាហ្នឹងមូលហេតុរបស់វា ហើយវានៅរាយប៉ាយនៅកន្លែងចម្ការចេក។ អ៊ីចឹង គាត់ឲ្យខ្ញុំទៅធ្វើឃ្លាំងដាក់ឲ្យឆ្ងាយពីក្រុង។ អាវុធបានពីទាហាន លន់ នល់ ទុកនៅចម្ការចេកហ្នឹងដាក់ដោយឡែកទៅ អាវុធដែលគ្រាប់ដែលសល់ពីធ្វើសង្គ្រាមនៅភាគីខាងរណសិរ្សហ្នឹង គឺទុកដោយឡែកទៅ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ហេតុអ្វីបានជាគេយកអាវុធនេះ ទៅទុក

នៅក្នុងឃ្លាំងក្នុងព្រៃឫស្សី? ហេតុអ្វីក៏ទុកនៅទីនោះ? តើមានមូលហេតុអីដែលនាំឲ្យមានការលាក់អាវុធនៅទីនោះដែរ?

**ឆ៖** បាទ នេះជាការធ្លាប់មានពិសោធទុកដាក់គ្រាប់ស្បៀងកាលពីសម័យសង្គ្រាម។ ទុកនៅក្នុងព្រៃឫស្សីពិបាកនឹងអ្នកទៅរកឃើញ អ្នកដែលគេចង់។ តែមួយវស្សា ឆ្លងកាត់តែមួយវស្សា គឺព្រៃឫស្សី មែកឫស្សីវាដុះជិតផ្លូវ ជិតលុបបាតអស់ ពិបាក។ ក្រៅពីអ្នកទុក គឺអ្នកថ្មីមិនអាចទៅរកឃើញដោយគ្មានប្លង់ទេ បាទ។

**ស៖** តើមូលហេតុនៃការលាក់ទុកអាវុធនេះ គឺដើម្បីកុំឲ្យទ័ពមជ្ឈិមរកឃើញ ឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

[១០:៣៥:០០]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីបញ្ហានេះវិញ។ លោកអាចជម្រាបអង្គជំនុំជម្រះបានទេ អាវុធប្រភេទនេះជាអាវុធវែង អាវុធអាកា៤៧ ឬក៏ជាអាវុធធុនប្រភេទណាដែរ?

**ឆ៖** បាទ ភាគច្រើនគឺ អាអ៊ែ១៥ និង អាអ៊ែ១៦។

**ស៖** តើមានអ្វីដែលធ្វើឲ្យលោកចាំថាចំនួនសរុបនៃកាំភ្លើងទាំងអស់នោះ គឺមានចំនួន ២០.០០០ដើម?

**ឆ៖** បាទ គឺសរុបដោយខ្លីទេចំនួនហ្នឹង។ វាអាចលើសហ្នឹងទៀត ប៉ុន្តែខ្ញុំនិយាយតែប្រហែលប៉ុណ្ណឹង តែវាមិនមែនតែ អាអ៊ែ១៥, ១៦ ទាំងអស់សុទ្ធទេ តែពីរប្រភេទហ្នឹងវាច្រើន។ ក្នុងហ្នឹងវាមានសេវេនធីធូ, វាមានសេវេនធីណៃ, មានតម្រងអឹមអង ហៅប្រាំបីណាត់នោះ មានអាប្រែនចុងសអាប្រែនបង់ងពីលើនោះ។

**ស៖** តើអ្នកណាដឹងអំពីការលាក់អាវុធ ២០០.០០០ដើមនេះ ក្រៅពីរូបលោក ហើយនិង រស់ញ៉ឹម?

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ការសួរបែបនេះគឺសួរឲ្យសាក្សីឆ្លើយស្មានៗទេ។ តើអាចថា អាចសួរថាអ្នកណាប្រាប់លោកអំពីការលាក់អាវុធ ឬក៏អ្នកណាខ្លះដឹងពីទីលាក់អាវុធ វាជាការត្រឹមត្រូវជាង។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

យើងអនុញ្ញាតឲ្យសួរបែបនេះ គាត់អាចឆ្លើយ តើមានមូលហេតុអ្វីដែលអាចឲ្យគាត់ដឹងអំពី

ការលាក់អាវុធនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកដឹងថាមានអ្នកណាដឹងអំពីការយកអាវុធទៅទុកនេះ ក្រៅពីលោក ហើយនិង រស់ ញឹម ទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ យកអាវុធទៅទុកក្រៅពីខ្ញុំ និង រស់ ញឹម អត់មានអ្នកណាដឹងទេ មានតែតាៗបីនាក់ ដែលគាត់ជាអ្នកធ្វើឃ្លាំង។

**ស៖** តើក្រៅពីលោកហ្នឹង ថាមានមនុស្សបីនាក់ហ្នឹង តើជាអ្នកណាខ្លះ?

**ឆ៖** បាទ តាៗគាត់នៅខាងដឹកជញ្ជូនសម័យសង្គ្រាម ព្រោះវាយូរពេក ខ្ញុំប្រហែលជា រកសុំរក នឹកបន្តិចឈ្មោះរបស់គាត់ តាៗ ដូចជាឈ្មោះ តារ៉ន, តាឈឿន, ចាស់ៗហើយ អាយុ ហុកជាងហើយ កាលនោះ ហើយ តាចៅ។

[១០:៣៩:២២]

**ស៖** លោកសាក្សី តើ សុន សេន ដឹងអំពីការយកអាវុធទៅទុកនេះទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** លោកសាក្សី ខ្ញុំចូលទៅការវាយប្រយុទ្ធនៅខេត្តពោធិ៍សាត់ បាត់ដំបង និងទីរួមខេត្តដទៃទៀត។ មុននឹងខ្ញុំចូលទៅសួរចំណុចនេះ ខ្ញុំសុំសង្ខេបចម្លើយរបស់លោកនិយាយអំពីរចនាសម្ព័ន្ធយោធា។ តើត្រឹមត្រូវទេ ដែលថាលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតថា មានកងពលចំនួនពីរនៅភូមិភាគពាយ័ព្យ ហើយមេបញ្ជាការដូចដែលយើងហ្នឹង គឺឈ្មោះ ខ្លែង។ ខ្លែង បានរាយការណ៍មកជូន រស់ ញឹម ហើយ កងពលនីមួយៗមានកងទ័ពប្រយុទ្ធហ្នឹង -- ប្រហែល -- យុទ្ធជនប្រហែល៥.០០០នាក់ ហើយកងពលនីមួយៗមានបីវរសេនាធំ ហើយមួយវរសេនាធំ មានបីកងវរសេនាតូច ហើយមួយកងវរសេនាតូច មានបីកងអនុសេនាតូច។ នៅពេលដែលលោកធ្វើជាអនុបញ្ជាការហ្នឹង គឺលោកត្រូវបាន -- រ៉ែន គឺថាមកជំនួសលោកនៅខាងផ្នែកប្រធានឃ្លាំង ហើយប្រធាននីរសារនេះឈ្មោះ ឌឿន ក្រោយមកឃើញថាមកជំនួសលោកធ្វើជាប្រធាននីរសារ។ តើត្រឹមត្រូវដែរឬទេលោក?

**ឆ៖** ឈ្មោះ បាទ ឈ្មោះ រ៉េន មកទទួលជំនួសខ្ញុំ តែមិនទទួលនៅឃ្លាំងអាវុធទេ ទទួលនៅខាងស្បៀង ព្រោះអាវុធ ខ្ញុំបានយកទៅទុកដាក់ផុតបាត់អស់ហើយ។

**ស៖** នៅដើមដំបូងនៃសំណួររបស់ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សូមលោកផ្អាកមួយនាទី ដើម្បីឲ្យខាងនោះផ្លាស់ប្ដូរ ឌីវីឌី។

*(សម្រាករយៈពេលខ្លី)*

[១០:៤២:៣៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្ត!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកមេធាវី ដោយសារតែពេលវេលាខ្ញុំសូមកាត់លោកបន្តិច សួរតែសំណួរពីរតូចខ្លីៗទេ វាអាចនឹងសន្សំពេលវេលា វាប្រសើរជាង កុំឲ្យយើងភ្លេចទៅបាន។

**សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** លោកសាក្សី តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះថា នៅពេលណាដែលលោកក្លាយទៅជាអនុសេនាធិការភូមិភាគ? តើលោកចាំកាលបរិច្ឆេទទេ ចាំខែឆ្នាំណាទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ប្រហែលជាខ្ញុំមិនចាំច្បាស់ទេ វាយូរឆ្នាំពេកដែរហើយ ហើយចេះតែដឹងថា ក្រោយពីសន្និបាតនៅភ្នំពេញហើយបាទ ដឹងតែប៉ុណ្ណឹងបាទ តែខែប្រហែលជាចុងឆ្នាំ ឬក៏ប្រហែលចុងឆ្នាំ៧៥ ហើយវាមិនចុងពេក ក៏វាមិនកណ្ដាលដែរ ប្រហែលចន្លោះប៉ុណ្ណឹង។

**ស៖** តើវាអាចថា ក្រោយរំដោះទីក្រុងភ្នំពេញ ឬមុនពេលរំដោះទីក្រុងភ្នំពេញ?

**ឆ៖** ក្រោយរំដោះទីក្រុងភ្នំពេញ ឆ្នាំ៧៥ បាទ។

**ស៖** សូមសួរលោកមួយសំណួរទៀត ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោកត្រង់ផ្នែកនេះ លោកនិយាយថា មនុស្សបីនាក់ដឹងអំពីឃ្លាំងអាវុធ តើអ្នកណាដែលជាអ្នកយកអាវុធហ្នឹងទៅទុកតែម្ដងហ្នឹង?

**ឆ៖** បាទ អ្នកដឹកនាំអាវុធទៅគឺខ្ញុំ អ្នកដឹកទៅតែម្ដង ហើយអ្នកទៅជ្រើសរើសកន្លែងធ្វើឃ្លាំងគឺខ្ញុំអ្នកជ្រើសរើស។ តាបីនាក់នោះ គាត់ជាជាងធ្វើរោង ធ្វើផ្ទះដាក់ធ្វើឃ្លាំងបាទ។

[១០:៤៥:៣៧]

**ស៖** តើខ្ញុំយល់ត្រឹមត្រូវទេ ថាអាវុធហ្នឹងពីមុន គឺថាអ្នកដទៃធ្លាប់ប្រើប្រាស់អាវុធហ្នឹង?

**ឆ៖** បាទ អាវុធហ្នឹង គឺទាហានលន់ នល់ ធ្លាប់ប្រើប្រាស់។

**ស៖** អ្នកណាជាអ្នកដឹកអាវុធទៅដាក់នៅឃ្លាំងហ្នឹង?

**ឆ៖** បាទ ខ្ញុំអ្នកដឹក ខ្ញុំបរឡានខ្លួនខ្ញុំ។

**ស៖** លោកដឹកនាំតែម្នាក់ឯងទេ?

**ឆ៖** បាទ ពេលដែលលើកឡើងឡាន ពីចម្ការចេកទៅ គឺមានកម្លាំងនៅចម្ការចេកជួយលើកដាក់ឡាន ប៉ុន្តែបើកឡានទៅ គឺបើកតែខ្ញុំម្នាក់ឯងទេ។ ទៅដល់ឃ្លាំងកន្លែងធ្វើថ្មីនោះ គឺមានតាៗបីនាក់ជាអ្នកជួយរើចុះ ហើយជាអ្នកលាបប្រេង លាបខ្លាញ់ រៀបបញ្ឈរទុកក្នុងឃ្លាំង បាទ។

**ស៖** សូមអរគុណ។ ខ្ញុំអស់សំណួរហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម មីឡាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដើម្បីបញ្ជាក់ឱ្យច្បាស់នេះ គឺខ្ញុំសូមទុកប្រធានបទនេះទាំងស្រុងសិន។ ខ្ញុំនឹងសួរអំពីការវាយប្រហារនៅពោធិ៍សាត់និងនៅទួលពោធិ៍ជ្រៃ។ លោកសាក្សី ឥឡូវនេះ ខ្ញុំសូមសួរលោកអំពីមូលហេតុនៃ នៅពីខាងក្រោយការលាក់អាវុធទុកនេះ។ តើមានមូលហេតុអីដែលនាំឱ្យយកអាវុធទៅលាក់ទុកបែបនេះ។ តើលោក រស់ ញឹម និងអ្នកដទៃទៀតនេះ ត្រូវយកអាវុធនេះទៅប្រើប្រាស់ដោយរបៀបណា ក្នុងបំណងអ្វីដែរ?

[១០:៤៨:១៦]

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ គឺអ្នកដទៃអត់បានយកប្រើប្រាស់ទេ ហើយ រស់ ញឹម ក៏អត់បានយកប្រើប្រាស់ដែរ ព្រោះអាវុធដែលកាលពីធ្វើសង្គ្រាមកាន់នៅជាប់ដៃ ទាហាននៅមានទាំងអស់ នេះជាអាវុធជយភណ្ឌទេ។ ហើយក្រោយមក ដែលខ្ញុំតស៊ូវាយជាមួយប៉ុល ពត វិញ ខ្ញុំទៅយកអាវុធហ្នឹង ប្រើប្រាស់ បាទ។

**ស៖** តើនេះ គឺជាគោលបំណងតាំងពីដើមរបស់លោកក្នុងការលាក់អាវុធហ្នឹង ដើម្បីឱ្យលោក រស់ ញឹម លោក និងអ្នកដទៃទៀត អាចយកអាវុធនេះមកប្រើប្រាស់ក្នុងការបះបោរប្រឆាំងនឹងប៉ុល ពតដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ កាលនោះ គឺវាអត់មានលាក់អាវុធ មានបំណងយ៉ាងម៉េច គឺខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំ

គ្រាន់តែដឹងថា ខ្ញុំជាអ្នករក្សាឃ្លាំងអាវុធទុកដាក់ឲ្យល្អ តែប៉ុណ្ណឹង។ តែក្រោយមក ដែលខ្ញុំយកប្រើប្រាស់វិញ ក្រោយដែលគេចាប់ខ្ញុំពីរដង ចាប់ខុស ចាប់ច្រឡំ ក្នុងឆ្នាំ៧៨។ ពេលនោះ ខ្ញុំក៏សម្រេចចិត្តថា ខ្ញុំមិនអាចនៅជាមួយ ប៉ុល ពត បានទៀតទេ។ មិនអាចនៅជាមួយ រស់ ញឹម បានទៀតទេ។ ខ្ញុំក៏ទៅប្រមូលកម្លាំងដែលសេសសល់ និងកម្លាំងដែលគេដកយកទៅកាប់ចម្ការធ្វើស្រែហ្នឹង រៀបចំឡើងវិញដើម្បីការពារ។ និយាយរួម គឺដំបូងនិយាយថាទៅធ្វើចោរព្រៃទេ យកលួចអង្ករសហករណ៍ហូប លួចអង្ករ ប៉ុន្តែដល់ខ្ញុំវាយទៅ ក៏នាំគ្នាទៅច្រើនក៏ខ្ញុំទៅយកអាវុធនៅហ្នឹងទៅ យកមកចែកចាយទៅបាទ។

[១០:៥០:៤០]

**សៈ** លោកសាក្សី ខ្ញុំបន្តទៅបន្តិច លោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា នៅពេលមួយនោះ ចន្លោះពីឆ្នាំ៧៥ ដល់ ៧៩ លោកក្តោបក្តាប់ទាហានភូមិភាគពាយ័ព្យរាប់ពាន់នាក់ ហើយលោកចាប់ផ្តើមបះបោរប្រឆាំងនឹងមជ្ឈិម។ តើត្រឹមត្រូវដែរទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

មេធាវីការពារក្តីហាក់ដូចជាយោងលើព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ៧៨។ ក៏ប៉ុន្តែសំណុំរឿង ០០២/០១ គឺពាក់ព័ន្ធត្រឹមតែឆ្នាំ៧៧តែប៉ុណ្ណោះ ហើយគោលនយោបាយរួមដែលសាលាដំបូងផ្តោតលើហ្នឹងគឺឈប់ត្រឹម១ខែធ្នូ ឆ្នាំ១៩៧៧ សហឧក្រិដ្ឋរួមនោះគឺបញ្ចប់ត្រឹមឆ្នាំ១៩៧៧ ដែរ។ ដូច្នេះសូមបញ្ជាក់ឲ្យបានច្បាស់នៅពេលដែលយើងសួរសំណួរអំពីរឿងហេតុដែលបានកើតឡើងក្រោយឆ្នាំ១៩៧៧នោះ គឺយើងនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ហើយ។ យើងមានសំណុំរឿងមួយទៀត គឺ០០២/០២ ដែលវិភាគទៅលើបញ្ហានេះ ប្រសិនបើយើងលើកឡើងអំពីបញ្ហាដែលហួសពីខែធ្នូ ឆ្នាំ១៩៧៧ នោះគឺវាមិនមានផលប្រយោជន៍អីសម្រាប់តុលាការកំពូលនោះទេ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យភាគីកុំសួរសំណួរដែលវាពាក់ព័ន្ធនឹងរយៈកាលដែលនៅវិសាលភាពនៃសំណុំរឿង០០២/០១។

**លោក អាកទួរ វែកកែន៖**

ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមស្តាប់ឲ្យបានច្បាស់ ដោយដើមបណ្តឹងរដ្ឋប្បវេណីគឺវាមានសារៈសំខាន់ណាស់។ ជាដំបូងគឺខែធ្នូ ឆ្នាំ៧៧ គឺជាការកំណត់ដោយចិត្តឯង ដោយសាលាដំបូង ក៏ប៉ុន្តែអ្វីដែលយើងកំពុងតែធ្វើនៅទីនេះគឺខ្លឹមសារនៃ ការលំបាកដែលកើតចេញមកពីការបំបែកនីតិវិធី។ ដូចដែលមេធាវីដើមបណ្តឹងបានលើកឡើងអ៊ីចឹង យើងទាំងអស់គ្នាគឺមិនឯកភាពទៅតាមការបំបែកនីតិវិធីទេ ហើយសហព្រះរាជអាជ្ញាក៏មិនឯកភាពដែរ។ ដូច្នេះហើយនៅពេលនេះ គឺយើងមានបញ្ហានៅ

ទីនេះ យើងបានរៀបរាប់លម្អិតនៅក្នុងបណ្តឹងសាទុក្ខរួចមកហើយ។ យើងគឺថាយើងមានការលំបាកខ្លាំងណាស់ពាក់ព័ន្ធទៅនឹងបញ្ហានេះ។

[១០:៥៣:១៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ឯកឧត្តមប្រធានសូមឱ្យខ្ញុំឆ្លើយតប។ វាជាចំណុចសំខាន់ណាស់។ ខ្ញុំយោងទៅលើសាលក្រមៗដែលត្រូវបានប្តឹងសាទុក្ខ ហើយសាលក្រមដែលសាលាតុលាការកំពូលនឹងសម្រេច គឺមានបញ្ជាក់ច្បាស់ណាស់នៅក្នុងសាលក្រមថា អង្គហេតុគឺបញ្ចប់ត្រឹមតែខែធ្នូតែប៉ុណ្ណោះ។ ដូច្នេះ គោលនយោបាយនៃសហឧក្រិដ្ឋកម្មរួមក៏ត្រូវបញ្ចប់ត្រឹមតែខែធ្នូ ឆ្នាំ១៩៧៧ដែរ។ អ៊ីចឹងអ្វីៗកំណត់ត្រឹមតែឆ្នាំ៧៧ តែប៉ុណ្ណោះ បើសិនជាយើងមើលសាលក្រមគឺច្បាស់តែម្តង។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សំណួរហ្នឹងគឺស្នើសុំ -- ចង់ស្វែងយល់ទំនាក់ទំនងរវាងរចនាសម្ព័ន្ធនៃការ -- រចនាសម្ព័ន្ធយោធា ដូច្នេះយើងចង់ដឹងអំពីចំណុចនេះ ដូច្នេះវាអាចជួយដល់អង្គជំនុំជម្រះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម មីឡាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសួរថា តើការ -- អាវុធដែលប្រើប្រាស់ដោយលោកនិងកងទ័ពចំនួនជាង ២.០០០នាក់ដែលលោកយកទៅភ្នំនោះនៅចន្លោះពីឆ្នាំ១៩៧៥ ទៅ ៧៩ គឺដើម្បីបះបោរប្រយុទ្ធជាមួយនឹងប៉ុល ពត ប្រយុទ្ធជាមួយនឹងគណៈកម្មាធិការមជ្ឈិម ឬក៏យ៉ាងណា?

**លោក នីកូឡាស គូមជែន៖**

អ៊ីចឹង ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ។ ដឹងថាសាក្សីត្រឡប់មកប្រទេសចិននៅក្នុងឆ្នាំ១៩៧៧ ហើយគាត់លើកឡើងអំពីឆ្នាំ១៩៧ ៨ក្រោយពីគាត់ត្រូវបានគេចាប់ខ្លួនពីរដង ហើយគាត់ក៏បានសម្រេចចិត្តថាចូលទៅក្នុងព្រៃ។ សក្ខីកម្មរបស់គាត់បានឆ្លើយច្បាស់ហើយ គឺនៅក្នុងឆ្នាំ១៩៧៨។

[១០:៥៥:២០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនគិតយ៉ាងដូច្នេះទេ អ៊ីចឹងហើយបានជាខ្ញុំរៀបចំសំណួរនេះ គឺចន្លោះពីឆ្នាំ៧៥-៧៩។ ដូច្នេះ ខ្ញុំ

គួរត្រូវបានអនុញ្ញាតឲ្យសួរសំណួរបែបហ្នឹង។

**ស៖** គឺនៅឆ្នាំចន្លោះ ៧៥ ទៅដល់ ៧៩ តើលោកហើយនិងកងទ័ពដែលលោកនាំទៅជាមួយលោកចូលទៅក្នុងព្រៃ -- រត់ចូលទៅក្នុងព្រៃដើម្បីចាប់ផ្តើមធ្វើការបះបោរ។ តើនេះវាជាប់ពាក់ព័ន្ធទៅនឹងអាវុធដែលលោកបានយកទៅលាក់ទុកទាំង ២០.០០០ដើម ដែលរឹបអូសបាន ដែលជារបស់ជយភណ្ឌបានពីទាហាន លន់ នល់?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ គឺអាវុធនេះ មិនមែនលាក់ទុកសម្រាប់តស៊ូប្រឆាំងជាមួយប៉ុល ពត ទេ ដំបូង។ គឺទុកដាក់ឲ្យបានល្អប៉ុណ្ណឹងទេ។ តែក្រោយពេលដែលទៅចាប់ខ្ញុំពីរដងខ្ញុំរកមុខអ្នកចាប់អត់ឃើញ។ ចាប់លើកទី១ ចំអនុប្រធានរបស់ខ្ញុំ អនុប្រធានកុមារ ព្រោះកាលហ្នឹង ខ្ញុំចិញ្ចឹមកុមារ ក្មេងកំព្រា វាយបែកក្បាលបែកក្បូងអស់ សួរទៅមិនមែនខ្ញុំបានលែងមកវិញ។ លែងមកវិញហើយមកប្រាប់ខ្ញុំៗថា “បើផ្ទះឯងនៅឯណាទៅៗ”។ ស្អែកឡើង បាន១ពីរថ្ងៃបានខ្ញុំរកម៉ូតូបានជិះ ខ្ញុំមកសួរ ឪញ៉ឹម ហ្នឹង ឆ្នាំ៧៨ ហើយ។ ថា “ហេតុអ្វីឪឯងឲ្យគេចាប់ខ្ញុំ?” គាត់ថា “គាត់អត់ដឹងទេ”។ ដល់អ៊ីចឹងខ្ញុំថា “បើធ្វើឪ ធ្វើមេ មិនដឹងគេចាប់អ៊ីចឹងៗ បានវាពាយអស់មួយពាយ័ព្យ។ ហើយឥឡូវសូមនិយាយឲ្យច្បាស់បើថាឪឯងមានបំណងចាប់ខ្ញុំគឺបាញ់ខ្ញុំសម្លាប់នៅត្រង់ហ្នឹងទៅ។ តែបើបាញ់ខ្ញុំមិនស្លាប់ទេ គឺខ្ញុំមានវិធីផ្សេងហើយ។” ខ្ញុំក៏មិននិយាយអ្វីច្រើនខ្ញុំក៏បកទៅវិញទៅ។ បានប្រហែលជាមួយអាទិត្យក្រោយ ទៅចាប់ម្តងទៀត ចាប់ចំកុមារជំទង់របស់ខ្ញុំ ច្រឡំថាខ្ញុំដែរ ព្រោះទៅចាប់ទាំងពីរលើកនេះ គឺចាប់នៅពេលយប់ ព្រលប់ៗស្ទាក់ចាប់តាមផ្លូវមកពីបូមទឹកដាក់ស្រូវ។

[១០:៥៨:១៧]

ហើយខ្ញុំបានមកសួរគាត់ម្តងទៀត។ ខ្ញុំថា “លើកនេះ លើកទី២ ហើយសូមនិយាយពិត” ហើយគាត់នៅតែបដិសេធថា គាត់អត់ដឹង ហើយខ្ញុំក៏ដោះកាំភ្លើងមុខខ្ញុំ ដកឲ្យគាត់ ខ្ញុំដកយកគ្រាប់តែមួយគ្រាប់ទេ ហើយឲ្យគាត់ប្រាំពីរគ្រាប់ ខ្ញុំថា “បាញ់ខ្ញុំឲ្យហើយទៅ ខ្ញុំទុកមួយគ្រាប់បាញ់ឪឯងវិញ។ ហើយបាញ់ក្នុងរយៈ -- ក្នុងប្រាំពីរគ្រាប់ហ្នឹងបាញ់ធ្វើយ៉ាងម៉េចឲ្យងាប់ទៅ បើងាប់ បើមិនងាប់ទេ ខ្ញុំបាញ់ឪឯងវិញហើយមួយគ្រាប់នេះ។ ខ្ញុំយកកាំភ្លើងពីឪឯង ខ្ញុំបាញ់វិញហើយ” ហើយគាត់ក៏មិនឆ្លើយតប។ គាត់ថា “អញមិនដែលចាប់កូនខ្លួនឯងទេ មានតែពួកសន្តិសុខមជ្ឈិមទេ” ហើយខ្ញុំថា “ឥឡូវចាប់ពីថ្ងៃហ្នឹងទៅអត់មានឪមានកូនទៀតទេ ខ្ញុំសម្រេចចិត្តថាខ្ញុំតស៊ូប្រឆាំងអង្គការវិញហើយ។ កាលនោះខ្ញុំមិនទាន់ហៅ

ប៉ុល ពត ទេ។ ប្រឆាំងអង្គការវិញហើយ អ្នកណាដែលតាមខ្ញុំទៅជាមួយខ្ញុំបាន អ្នកណាមិនទៅ ហើយទៅតាមរករឿងខ្ញុំគឺខ្ញុំបាញ់វិញហើយ" ប្រាប់គាត់ប៉ុណ្ណឹង។ ហើយគាត់ថា "អ្ហែងកុំធ្វើអីលឿនពេក!"។ ខ្ញុំថា "មិនលឿនយ៉ាងម៉េច បើវាចាប់អស់រលីងអ៊ីចឹងហ្នឹង ហៅមករៀនសូត្រភ្នំពេញបាត់ៗ"។ រួចខ្ញុំក៏សម្រេចចិត្តចេញទៅ ពេលនោះហើយដែលធ្វើឲ្យខ្ញុំមានគំនិតចាប់ផ្តើមយកអាវុធ ២០.០០០ដើមហ្នឹងប្រើប្រាស់ឡើងវិញទើបតែពេលហ្នឹងទេ បាទ លោកមេធាវី។

[១១:០០:៣០]

**ស៖** លោកសាក្សី ឥឡូវហ្នឹងយើងទុកមួយភ្លែតសិន ទុកកៀនមួយភ្លែតសិន រវាងជម្លោះរវាងលោក ហើយនិងឪពុកចិញ្ចឹមរបស់លោក ហើយក៏ទុកមួយអន្លើសិននូវការចាប់ខ្លួនរបស់លោក។ ឥឡូវនេះ ខ្ញុំចង់សួរលោកថាៗតើមានផែនការអ្វីដែរឬទេនៅពេលដំបូងក្នុងការបះបោរ? ហើយថាតើអ្នកណាជាអ្នកនៅពីក្រោយផែនការបះបោរនេះ?

**ឆ៖** បាទ ផែនការបះបោរនេះ គឺគ្មានអ្នកណានៅពីក្រោយទេ គឺធ្វើដោយខ្លួនឯង ដោយថារស់នៅក្នុងរបបអង្គការហ្នឹងលែងបានហើយ ព្រោះបាត់មិត្តជាច្រើន យុទ្ធមិត្តជាច្រើន។ កាលហ្នឹងគេហៅមិត្តៗអ៊ីចឹង មិនមែនហៅបង ហៅប្អូនទេ ហៅតែមិត្ត ហើយសមមិត្ត បាត់អស់ហើយ។ មករៀនភ្នំពេញបាត់ ហើយដល់ទៅចាប់ខ្ញុំ ចាប់ទៅចេះតែទេវតាជួចជួយខ្ញុំដែរ ចាប់មិនបាន ខ្ញុំក៏សម្រេចចិត្តថាយកអាវុធហ្នឹងប្រើទៅ។ ហើយអត់មានអ្នកណានៅពីក្រោយខ្នងខ្ញុំទេ មានតែខ្ញុំទេអង្វរគាត់ អង្វរទាំងតាប៉ែត អង្វរទាំងតាកឹ អង្វរទាំងតាញឹម ថាឲ្យប្រឆាំងនឹងអង្គការទៅ។ ហើយសូមអង្វរ តាប៉ែត នៅផ្ទះគាត់ទៅធ្វើមេដឹកនាំខ្ញុំឡើងវិញទៅនៅក្នុងព្រៃតស៊ូឡើងវិញ គាត់ថាគាត់ចាស់ហើយ គាត់ទៅមិនបានទេ។ ខ្ញុំទៅអង្វរតាកឹថា "អង្គការអាចផ្តាសុីកូនឯងហើយ ខ្ញុំមិននៅទេ ខ្ញុំចេញតស៊ូប្រឆាំងវិញហើយ ឪឯងទៅធ្វើមេដឹកនាំខ្ញុំទៅ" គាត់ថា "អញទៅតែឯង ឪទៅតែឯងនោះវាយ៉ាប់ ចាំមើលពិភាក្សាគ្នាសិន"។ អ៊ីចឹងទៅ ខ្ញុំក៏សម្រេចចិត្តថាខ្ញុំទៅ អត់មានអ្នកណាដឹកនាំនៅពីក្រោយខ្ញុំទេ អត់មានទេបាទ។

[១១:០៣:០៧]

**ស៖** លោកសាក្សី គឺជារឿងដ៏គួរឲ្យចាប់អារម្មណ៍មែនទែនដែលលោកបាននិយាយរៀបរាប់។ ប៉ុន្តែ តើវាជាការពិតទេ ដែលថាមានពេលខ្លះនៅពាក់កណ្តាលឆ្នាំ៧៥ គឺ រស់ ញឹម ហើយនិង សោ ភឹម ព្រមទាំង វ៉ន វេត ហើយអាចនឹងមានទាំង កុយ ធួន ផងដែរបានចាប់ផ្តើមជជែកគ្នា ហើយពួកគេជជែកអំពីផែនការបះបោរជាចំហប្រឆាំងជាមួយនឹងរដ្ឋាភិបាល ឬក៏ ថាតើវាជាការត្រឹមត្រូវដែរឬទេ ដែលខ្ញុំ

និយាយបែបនេះ?

**ឆ៖** បាទ ខ្ញុំមិនដឹងថាត្រឹមត្រូវ មិនត្រឹមត្រូវទេ ប៉ុន្តែកាល -- ក្រោយឆ្នាំ៧៥មក ពេលដែលមកសន្និបាតនៅភ្នំពេញហ្នឹង គាត់បានជួបគ្នានៅបុរីកីឡាឯណោះ ខ្ញុំក៏ជូនគាត់មកដល់ហ្នឹងដែរ ហើយគាត់ទៅជជែកគ្នា បញ្ហាមិនថារៀបចំការបះបោរទេ គឺនិយាយតែទាមទារធ្វើម៉េចប្រជុំមជ្ឈិមហ្នឹងឲ្យបានប្រជាជនវិលត្រឡប់ទៅនៅផ្ទះដើមវិញ ទៅនៅភូមិករវិញ។ ហើយលុយដែលបោះទៅហើយហ្នឹង ធ្វើសារាចរចាយ និងតស៊ូមតិក្នុងមជ្ឈិម។ អាហ្នឹងតាមការគាត់ជជែក និយាយគ្នា ដល់ពេលគាត់ហូបបាយជុំគ្នានុ៎ង។

**ស៖** ដូច្នេះតាមលោក គឺថាគោលដៅនៃការបះបោរនោះ តើវាជាការត្រឹមត្រូវដែរទេ?

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

មេធាវីការពារក្តី គឺថាសាក្សីមិនបានបញ្ជាក់អំពីការបះបោរនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងកែតម្រូវលោកស្រីចៅក្រម។

[១១:០៥:៣៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ថាតើស្ថានការណ៍ -- តើលោកដឹងអំពីផែនការ គឺមានផែនការដើម្បីធ្វើឃាត ប៉ុល ពត ក៏ដូចជាធ្វើវិទ្ធង្សនាបដិវត្តដោយការបង្កជាភាពរញ៉េរញ៉ៃទាំងផ្ទៃក្នុង និងខាងក្រៅ។ ឧទាហរណ៍ដូចជាការធ្វើការវាយប្រយុទ្ធជាមួយប្រទេសថៃ ហើយក៏ដូចជាការរៀបចំធ្វើរដ្ឋប្រហារ។ តើលោកដឹងអំពីផែនការទាំងអស់នេះដែរទេ? តើលោកដឹងថាវាមានសកម្មភាពទាំងអស់នេះកើតឡើងដែរឬទេ នៅឆមាសទី២ ឆ្នាំ៧៥?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ បាទ។

**ស៖** តើលោកធ្លាប់ឮអំពីផែនការប្រមូលកងទ័ពរវាងខាងបូព៌ា ជាមួយខាងឧត្តរដើម្បីវាយទៅលើពោធិ៍ចិនតុង ទៅលើស្ថានីយវិទ្យុនៅដើមឆ្នាំ៧៧ ដែរឬទេ?

**ឆ៖** បាទ អត់ដឹងដែរ។

**ស៖** តើលោកចាំអំពីតួនាទីរបស់ប្រទេសជិតខាង គឺប្រទេសវៀតណាម គឺតួនាទីរបស់

វៀតណាមក្នុងការងើបបះបោរផ្នែកយោធាដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេខាងវៀតណាម ព្រោះខ្ញុំនៅជិតថៃឯណោះ។

[១១:០៧:៣៤]

**ស៖** តើលោកធ្លាប់ឮបុរសម្នាក់ គឺកម្មាភិបាលវៀតណាមម្នាក់ ហេង សូ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ឮទេ បើ ស៊ូ ឮ, បើ សូ អត់ដែរឮទេ។

**ស៖** បាទ ខ្ញុំសូមទោសខ្ញុំអានមិនត្រឹមត្រូវ គឺគាត់ឈ្មោះ ហាយ សូ។

**ឆ៖** អត់ទេ ឈ្មោះ ហាយ ស៊ូ, មិនមែន សូ ទេ។

**ស៖** ខ្ញុំចងរំឭកការចងចាំរបស់លោកបន្តិច គឺជា -- គាត់ហ្នឹងគឺជាអ្នកជំនាញខាងទ័ពព្រៃរបស់វៀតណាម ហើយគាត់ចូលរួមនៅក្នុង -- ហើយគាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍របស់វៀតណាម។ ហើយតើ -- គាត់គឺជាមិត្តភ័ក្តិរបស់ឪពុកលោកផង។ តើលោកចាំទេ?

**លោក នីកូឡាស គូមជែន៖**

លោកចៅក្រម នេះគឺជាសំណួរនាំមុខ ព្រោះថាវាជាការលើកឡើងអំពីចម្លើយ ហើយមិនមានឯកសារ មិនមានអ្វីនោះទេ។

**លោក វ៊ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែចងរំឭកការចងចាំតែប៉ុណ្ណោះ។

**សួរដោយលោក វ៊ិចទ័រ កូប៉េ៖**

**ស៖** តើអ្វីដែលខ្ញុំប្រាប់លោកធ្វើឲ្យលោកនឹកឃើញដែរទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមបញ្ជាក់ឡើងវិញ គឺទាក់ទងបញ្ហាសំណួរនាំមុខ ដើម្បី -- គប្បីកុំប្រើបាទ។

**លោក វ៊ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំនឹងមិនប្រើប្រាស់សំណួរនាំមុខទេ ប៉ុន្តែឥឡូវនេះខ្ញុំកំពុងតែជួយគាត់ ប៉ុន្តែវាអាចថាជាការនាំបន្តិចបន្តួច ប៉ុន្តែវាគ្រាន់តែចង់ឲ្យគាត់នឹកឃើញឡើងវិញតែប៉ុណ្ណោះ។

[១១:១០:១៦]

**សួរដោយលោក វ៊ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ហាយ ស៊ូ ដែលជាមិត្តភក្តិរបស់ឪពុកលោក ហើយជាអ្នកជំនាញខាងកង

ទ័ពព្រៃ ហើយគាត់នៅក្នុងការងារនោះពីឆ្នាំ៧៥ ដល់ ៧៩ តើវាធ្វើឲ្យលោកនឹកឃើញដែរឬទេអំពីចំណុច នេះ?

**លោក ទាត់ ធឿន៖**

**ឆ៖** ក្នុងឆ្នាំ ៧៥-៧៩ គឺអត់មានទេ គាត់ទៅប្រទេសវិញតាំងពីឆ្នាំ៧៣។

**ស៖** អ៊ីចឹង ឪពុករបស់លោមិនដែលធ្លាប់ជួបគាត់នៅខែឧសភា ឆ្នាំ៧៧ទេ?

**ឆ៖** អត់ដែលទេ។

**ស៖** លោកសាក្សី ខ្ញុំសុំអាននូវសម្រង់មួយ មកពីចម្លើយរបស់សាក្សីមួយរូបដែលជាឪពុកធម៌ ដែលជាកងការពារ ឪពុកចិញ្ចឹមរបស់លោក។ ឯកឧត្តមប្រធាន ខ្ញុំយោងទៅលើឯកសារគឺ E319/19.107, អង់គ្លេសមានលេខ 00970079, បារាំងមានលេខ 01044643, និងខ្មែរមានលេខ 00960676។

លោកសាក្សី សំណួរដែលគេសួរទៅលើបុគ្គលគឺនិយាយអំពីមនុស្សម្នាក់ដែលស្និទ្ធស្នាលជាមួយ នឹងឪពុកចិញ្ចឹមរបស់លោក ហើយសំណួរដូចតទៅ៖ "នៅថ្ងៃ១៧ មេសា ៧៥ តើលោករស់នៅទីណា ហើយលោកធ្វើអ្វី? ហើយគាត់ឆ្លើយថា៖ នៅថ្ងៃ១៧ មេសា ៧៥ ខ្ញុំផ្លាស់ទីទៅកង្ហត។ នៅពេលនោះ តាញ៉ឹម ហៅខ្ញុំទៅធ្វើជាអ្នកការពាររបស់គាត់។ ខ្ញុំនៅធ្វើជាអ្នកការពាររបស់គាត់រហូតដល់ពេលគាត់ ចាប់ខ្លួន។ ខ្ញុំការពារ និងតាមគាត់នៅគ្រប់កន្លែងទាំងអស់។ គាត់មានអ្នកការពារបីនាក់ រួមទាំងខ្ញុំ ប៉ុន្តែ ខ្ញុំមិនមែនជាអ្នកការពារនៅក្នុងឡានជាមួយគាត់នោះឡើយ។ ខ្ញុំធ្លាប់អមដំណើរគាត់ទៅភ្នំដិន ដែលនៅ ជាប់ព្រំដែនវៀតណាម។ សំណួរ៖ ហេតុអ្វីបានជាលោកអមដំណើរជាមួយ តាញ៉ឹម ទៅភ្នំដិន? ហើយ គាត់ឆ្លើយថា៖ គាត់ចង់ឲ្យខ្ញុំការពារគាត់នៅពេលដែលគាត់ទៅដឹកឯកសណ្ឋានយោធាពីភ្នំដិនទៅអំពិល ប្រហោងនៅស៊ីសុផុន។ ស៊ីសុផុនក៏ជាមូលដ្ឋានទ័ពរបស់តាញ៉ឹម។ សំណួរ៖ តើអំពិលប្រហោងជាកន្លែង អ្វី? ឆ្លើយ៖ "អំពិលប្រហោងជាផ្ទះរបស់ តាញ៉ឹម និងក៏ជាកន្លែងធ្វើការគាត់ដែរ។ អំពិលប្រហោងមាន ទីតាំងនៅខាងលិចផ្សារលើចម្ងាយមួយគីឡូម៉ែត្រ។ សួរ៖ តើគេយកខោអាវទាហាននោះមកធ្វើអីដែរ? ឆ្លើយ៖ ខ្ញុំមិនដឹងថាគេយកមកឲ្យអ្នកណាទេ តែតាញ៉ឹម ប្រាប់ខ្ញុំថា ខោអាវនេះគឺពីយួន។ សួរ៖ ពេល ដែលលោកទៅយកខោអាវពីភ្នំដិន តើពេលនោះមានការវាយគ្នានៅតាមទល់ដែនវៀតណាមហើយឬ នៅ? ឆ្លើយ៖ កាលនោះ មិនទាន់វាយគ្នាទេ។" លោកសាក្សី ហើយទៅក្រោមបន្តិច គេសួរគាត់បន្ថែម ទៀតអំពីមូលហេតុគឺ៖ "ហេតុអ្វីបានជាឪពុកចិញ្ចឹមរបស់លោកទទួលខោអាវសម្លៀកបំពាក់យោធាពី

វៀតណាម?” តើលោកដឹងទេហេតុអ្វី?

[១១:១៤:២៤]

**ឆ៖** បាទ ខ្ញុំមិនដែលឃើញ ហើយក៏មិនដែលឮ មិនដែលឃើញសម្លៀកបំពាក់ពីវៀតណាម។ មានតែកាត់ខោអាវដោយរោងចក្រតម្បាញខេត្តបាត់ដំបងខ្លួនឯង ហើយជ្រលក់ផ្លែមាក់ក្លឿ ជ្រលក់ស្លឹកសង្កែ ដើមសង្កែ ជ្រលក់ស្លឹកស្នួល បុកជ្រលក់ឲ្យវាខ្មៅៗទៅប៉ុណ្ណឹង។ អ៊ីចឹងយកខោអាវពីក្រៅមកអត់មានទេបាទ។

**ស៖** លោកសាក្សី តើនៅពេលនោះ ឬក៏នៅពេលក្រោយបន្តិច នៅពេលដែលលោកទៅរៀននៅសូវៀត ឬក៏នៅពេលដែលក្រោយមកទៀត ដែលលោកធ្វើការជាមួយនឹងកងទ័ពវៀតណាមហ្នឹង តើលោកដឹងទេថា នៅខែកុម្ភៈ ឆ្នាំ៧៨ គណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តវៀតណាមបានចាប់ផ្តើមការបះបោរផ្ទៃក្នុង ដែលដឹកនាំដោយ សោ ភឹម ប៉ុន្តែការបះបោរគឺមិនបានជោគជ័យ ហើយការបះបោរហ្នឹងគឺមានគោលដៅដើម្បីផ្តួលរំលំខ្មែរក្រហម តើលោកដឹងដែរឬទេ អំពីចំណុចទាំងអស់នោះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ឯកឧត្តមប្រធាន ខ្ញុំសូមកត់សម្គាល់។ ខ្ញុំចង់ដឹងថា តើគាត់បានព័ត៌មាននេះមកពីណា? គាត់បានព្យាយាមប្រើប្រាស់នៅក្នុងសំណុំរឿង០០២/០២ រួចមកហើយ ហើយគាត់ពេលនុ៎ងមិនបានផ្តល់ប្រភពទេ។ អ៊ីចឹងសូមឲ្យយើងទាំងអស់គ្នាអាចយល់ផង ថាតើគាត់យកព័ត៌មានហ្នឹងមកពីណា ដើម្បីឲ្យយើងអាចដឹងទាំងអស់គ្នា ហើយដើម្បីយើងអាចពិនិត្យមើល អាចជំទាស់តវ៉ាពាក់ព័ន្ធទៅនឹងព័ត៌មានដែលគាត់យកមកសួរសាក្សីនេះ។ អ៊ីចឹងយើងមិនដឹងថាគាត់យកឯកសារ ឬក៏រកព័ត៌មានហ្នឹងមកពីណាទេ?

[១១:១៦:៣២]

**លោក នីកូឡាស គូមជែន៖**

ប៉ុន្តែការ -- ខ្ញុំមានការជំទាស់ផ្សេង។ គឺថាអត់មានភាពពាក់អីទាល់តែសោះ ជាមួយនឹងបណ្តឹងសាទុក្ខនោះ។ វាអត់មានភាពពាក់ព័ន្ធថា តើវៀតណាមធ្វើផែនការក្នុងឆ្នាំ៧៧ ដើម្បីឈ្លានពានកម្ពុជាឬក៏អត់ ៧៨ដើម្បីឈ្លានពានឬក៏អត់។ ដូច្នេះ គឺវាអត់មានភាពពាក់ព័ន្ធ ហើយម្យ៉ាងទៀត សហការីខ្ញុំក៏បានបញ្ជាក់រួចមកហើយថា វិសាលភាពគឺក្នុងឆ្នាំ៧៧ មិនមែន៧៨ ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមឆ្លើយតប។ ការជំទាស់ទាំងពីរនេះ គឺជាការជំទាស់ គ្រាន់តែដើម្បីរំខាន ព្រោះថាទី១ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាមិនដឹងអំពីអ្វីដែលយើងបានដឹងជាទូទៅ គឺថានៅក្នុងខែកុម្ភៈ ឆ្នាំ៧៨ គឺមានឯកសារជាច្រើនដែលអ្នកជំនាញតុលាការ របស់តុលាការដូចជា ណាយ៉ាចាន់ដា គាត់សរសេរនៅក្នុងឆ្នាំ៧៨-៧៩ នៅក្នុងទស្សនាវដ្តី "ហ្វារអ៊ីស្ទើន អ៊ីកូណូមិច រីវីយូ" ដែលបាននិយាយយ៉ាងច្រើនអំពីការងារនេះ ហើយអ្នកនិពន្ធដទៃទៀតក៏បានបញ្ជាក់ទៅលើចំណុចនេះដែរ។ ដូច្នេះ ខ្ញុំគិតថាមិនមានអ្វីដែលត្រូវឆ្ងល់នោះឡើយទាក់ទងទៅនឹងហេតុការណ៍ឆ្នាំ៧៨ ខែកុម្ភៈនេះ។

ទាក់ទងទៅនឹងជំទាស់របស់ព្រះរាជអាជ្ញាវិញ ខ្ញុំមិនដឹងថាតើខ្ញុំគួរតែរៀបរាប់យ៉ាងដូចម្តេចទេ ព្រោះថាសេចក្តីរបស់វៀតណាម គឺជាការដ៏សំខាន់ ហើយតួនាទីរបស់វៀតណាមក៏ជាការសំខាន់ ដើម្បីឱ្យយើងអាចយល់អំពីអ្វីៗដែលកើតឡើងនៅកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ៧៥ ដល់ ៧៩។ វាអាចថានៅក្រៅវិសាលភាព ប៉ុន្តែខ្ញុំចង់ជម្រាបថា ទោះបីថាយ៉ាងណាក៏ដោយ ដើម្បីឱ្យយើងយល់ឱ្យបានច្បាស់អំពីហេតុការណ៍ទាំងអស់នេះ គឺដើម្បីឱ្យដឹងអំពីសុច្ចភាពពិតប្រាកដនៃសាលក្រម ហើយខ្ញុំគិតថា ឯកសារចុងក្រោយដែលយើង -- ដែលសាលាដំបូងបានប្រើប្រាស់គឺចុះថ្ងៃ -- រហូតដល់ខែមករា ឆ្នាំ៧៩ គឺឯកសារដែលគេបញ្ជូនទៅអង្គការសហប្រជាជាតិ ហើយសូម្បីតែឯកសារនៅស-២១ ក៏ប្រើរហូតទៅដល់ខែសីហា ឆ្នាំ៧៨ ផងដែរ។ ដូច្នេះ ការណ៍ដែលលើកយកមកនិយាយអំពីវិសាលភាពហ្នឹង គឺជាការចម្លែក។

[១១:១៩:០៦]

**ប្រធានអង្គជំនុំ៖**

ខ្ញុំពិនិត្យមើលទៅឃើញអ៊ីចេះ ឃើញការលើកឡើងរបស់មេធាវីអម្បាញ់មិញ គឺថាវាមានប្រភពឯកសារ ប៉ុន្តែគឺទាក់ទងនឹងបញ្ហាអង្គហេតុដែលគាត់លើកឡើងអំមិញនេះគឺ ខ្ញុំពិនិត្យទៅឃើញថា វាមិនមានការពាក់ព័ន្ធជាមួយនឹងបណ្តឹងសាទុក្ខទេ។ ទាក់ទងនឹងបញ្ហាសំខាន់គឺ អ្វីដែលគាត់លើកអំមិញនោះ គឺទាក់ទងនឹងបញ្ហាវៀតណាម ប៉ុន្តែគឺថាលោកអាចរកសំណួរផ្សេងទៀតដើម្បីសួរទៅសាក្សីបាន ប៉ុន្តែគឺកុំឱ្យវាហួសពីវិសាលភាពហ្នឹងខ្លាំងពេកបាទ ឱ្យវាមានភាពពាក់ព័ន្ធខ្លះ។

សូមអញ្ជើញ!

ឯកសារហ្នឹង បើសិនជាលក្ខណៈជាឯកសារដែលមានលេខយោង គឺសូមបញ្ជាក់មកផង។

F1/3.1

[១១:២០:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន គឺថាឯកសារE3/2379, អង់គ្លេសមានលេខ 00192401, បារាំងមានលេខ 00237080 និងខ្មែរមានលេខ 00191550។ នេះគឺជាសម្រង់ដកចេញពីសៀវភៅរបស់ ណាយ៉ា ចាន់ដា មានចំណងជើងថា "សត្រូវបងប្អូន"។ ដូច្នេះ ឯកឧត្តមប្រធាន ពាក់ព័ន្ធទៅនឹងសំណួរផ្ទាល់ គឺថាខ្ញុំមិនមានអ្វីគួរឲ្យសង្ស័យនោះទេ ដែលថាអង្គជំនុំជម្រះ -- គឺថាលោកប្រធានសម្រេចតែម្តង ដែលមិនមានជំនុំជម្រះក្នុងក្រុមប្រឹក្សាជំនុំជម្រះ ហើយបញ្ហាទាំងអស់នេះ វាប៉ះពាល់ដល់ខ្ញុំ។ម្យ៉ាងទៀត លោកប្រធាន មិនបានពិភាក្សាជាមួយចៅក្រមដទៃទៀតឡើយ ក្នុងការបង្ហាញអំពីសំអាងហេតុ និងទឡ្ហីករណ៍ដែលជាការដ៏សំខាន់បំផុតចំពោះយើងខ្ញុំ។ ដូច្នេះ ខ្ញុំស្នើសុំថា ឲ្យអង្គជំនុំជម្រះទាំងមូលពិភាក្សាគ្នាជារួមជាមុនសិន។ សូមអរគុណ។

*(សម្រាករយៈពេលខ្លី)*

[១១:២១:៤០]

**ប្រធានអង្គជំនុំ៖**

ខ្ញុំគ្រាន់តែបញ្ជាក់អំពីលោកមេធាវីឲ្យច្បាស់ថា ទាក់ទងនឹងបញ្ហាអម្បាញ់មិញនេះ គឺយើងខ្ញុំមិនជំទាស់ថាមិនឲ្យមេធាវីសួរទេ។ ប៉ុន្តែគ្រាន់តែការសួរសំណួរហ្នឹងគឺអាចជ្រើសវិធីផ្សេង ហើយតាមវិធីដែលលោកជ្រើសរើសហ្នឹង ធ្វើម៉េចកុំឲ្យវាស៊ីជម្រៅរហូតទៅដល់អង្គហេតុដែលមិនមានភាពពាក់ព័ន្ធនឹងរឿងក្តី ហើយបញ្ហានេះ ខ្ញុំនឹងពិភាក្សាគ្នាឡើងវិញម្តង។

**លោក វ៉ិចទ័រ កូប៉េ៖**

អឺចឹង ខ្ញុំសូមអភ័យទោស ដែលខ្ញុំមិនបានយល់ច្បាស់អំពីសេចក្តីសម្រេចរបស់ឯកឧត្តមប្រធាន។ ដូច្នេះខ្ញុំព្យាយាមសួរសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅពេលនោះ ឬក៏នៅពេលក្រោយមកទៀត នៅពេលដែលលោកទៅរៀនសូវៀត តើលោកដឹងអំពីសេចក្តីសម្រេចខែកុម្ភៈ ឆ្នាំ៧៨ របស់កិច្ចប្រជុំពេញអង្គបក្សកុម្មុយនីស្តកម្ពុជា -- បក្សកុម្មុយនីស្តវៀតណាម ក្នុងការចាប់ផ្តើមការប៉ះបោរដែលដឹកនាំដោយ សោ ភឹម ដែលជាការឈ្លានពានចូលទៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ តើលោកដឹងអំពីចំណុចទាំងអស់នេះទេ?

**លោក ទាត់ ធឿន៖**

**ធ៖** បាទ ខ្ញុំអត់ដឹងទេ បាទ។

[១១:២៣:០៨]

**ស៖** នៅពេលដែលលោកនៅសិក្សាសហភាពសូវៀត សិក្សានៅខាងសាលាយោធានោះ តើគេមានបង្រៀនលោកអំពីការលុកលុយរបស់សូវៀតចូលទៅក្នុងប្រទេសឆេគូស្លូវ៉ាគី ឆ្នាំ៧៦ដែរឬទេ?

**ធ៖** បាទ ទៅរៀន គេមិនមានបង្រៀនពីការឈ្លានពានទេ។ ទៅរៀន យកតែវិជ្ជាខាងក្បួនបញ្ជា ឬកងទ័ព ថ្នាក់សេនាធិការ។ គ្រប់គ្រងកងទ័ព ប៉ុណ្ណឹង រឿងឈ្លានពាន អត់មានទេ។

**ស៖** លោកសាក្សី ខ្ញុំសូមអានកំណត់ហេតុកិច្ចប្រជុំមួយ គឺជាកិច្ចប្រជុំរបស់មេបញ្ជាការយោធាមជ្ឈិម គឺខែតុលា ឆ្នាំ៧៦។ ឯកសារ E3/13, អង់គ្លេសមានលេខ 00940343, ខ្មែរមានលេខ 0005 2406, បារាំងមានលេខ 00334906 ហើយ សុន សេន បានបញ្ជាដល់មេបញ្ជាការយោធាទាំងអស់ ហើយគាត់បានបញ្ជាដូចតទៅនេះ៖ "ខ្មាំងនៅខាងបូព៌ា គឺខាងវៀតណាម ដោយមានសូវៀតនៅពីក្រោយខ្នង គឺកំពុងតែធ្វើការវាយប្រហារតាមរយៈ យ៉ា, កែវ មាស, ឈូក ហើយនិង ចក្រី"។ អ្វីដែលខ្ញុំចង់និយាយអំពីការវាយប្រហារគឺការវាយប្រហារនៅឆេកូស្លូវ៉ាគី និងមុងហ្គោលី ប៉ុន្តែជាការកម្ចាត់ចិត្តប៉ុណ្ណោះ ព្រោះខ្មាំងធ្វើបែបនេះមិនបានឡើយ។ តើលោកធ្លាប់ឮអំពីហេតុការណ៍នៅឆ្នាំ៧៦ ដែលថាវៀតណាមតាមរយៈឳពុករបស់លោកគឺថា គេនឹងធ្វើតាមរបៀបវាយលុកឆ្នាំ៦៨ នៅឆេកូស្លូវ៉ាគីដែរឬទេ?

**ធ៖** អត់មានទេ អត់ដែលឮ។

**ស៖** អ្នកជំនាញតុលាការដដែលគឺ ណាយ៉ា ចាន់ដា បានសរសេរនៅក្នុងសៀវភៅរបស់គាត់ថា "យើងបាននិយាយជាមួយនឹងយោធាវៀតណាម ឆ្នាំ៧៨ ហើយគាត់បានផ្តល់យោបល់អំពីសូវៀត អំពីយុទ្ធសាស្ត្ររបស់សូវៀតទៅវៀតណាមឆ្នាំ៧៨ ផងដែរ។ ថាតើនៅពេលដែលលោកទៅរៀននៅសូវៀត តើគេមាននិយាយអំពីចំណុចទាំងអស់នេះទេ?

[១១:២៦:២២]

**ធ៖** បាទ ខ្ញុំបញ្ជាក់រួចហើយថា ខ្ញុំទៅរៀនតែវិជ្ជាការ -- មុខវិជ្ជាកងទ័ពបញ្ជាកងទ័ព ការពារទឹកដីតែប៉ុណ្ណឹងទេ។ ប្រើប្រាស់អាវុធ ប៉ុណ្ណឹងឯង អត់មានដឹងពីគម្រោងអ្វីផ្សេងទេ អត់មានទេ គេមិនដែលបង្រៀនទេ។

**ស៖** លោកសាក្សី ខ្ញុំសូមអាននូវសម្រង់មួយទៀតមកពីកម្មាភិបាលភូមិភាគពាយ័ព្យ។

ឯកឧត្ដមប្រធាន គឺឯកសារ E319/13.3.58, អង់គ្លេសមានលេខ 00970467, បារាំងមានលេខ 00974761, ខ្មែរមានលេខ 00947282។ "សំណួរទី១៣៖ តើលោកដឹងថាហេតុអ្វីបានជាពួកនិរតីមកជំនួសពួកពាយ័ព្យនេះ? ឆ្លើយ៖ គេចោទថាពួកកម្មាភិបាលពាយ័ព្យមានអតីតទាក់ទងនឹងខ្មែរក្រហមវៀតមិញ និងមានទំនាក់ទំនងនឹងគណៈភូមិភាគបូព៌ាឈ្មោះ សោ ភឹម។ ហើយភូមិភាគទាំងពីរនេះគឺសត្រូវរបស់ប៉ុល ពត។ ទិដ្ឋភាពជាក់ស្ដែងតាមការសង្កេតរបស់ខ្ញុំ ខ្មែរក្រហមមានបីបួនក្រុម។ ក្រុមទី១ គឺក្រុមវៀតមិញ, ក្រុមទី២ ក្រុមខ្មែរក្រហមស្នេហាជាតិ, ក្រុមទី៣ គឺក្រុមខ្មែរក្រហមសីហនុ ហើយនិងក្រុមទី៤ គឺក្រុមខ្មែរក្រហមមកពីចិន ដែលមានប៉ុល ពត"។ លោកសាក្សី កម្មាភិបាលភូមិភាគពាយ័ព្យរូបនេះបាននិយាយអំពីបក្សជាច្រើននៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា។ តើលោកចាំដូច្នេះដែរឬទេ ឬមួយយ៉ាងម៉េចដែរ?

[១១:២៨:៤៦]

**ឆ៖** បាទ បើនិយាយបក្សជាច្រើន វាមានមែនហ្នឹងឯង ក៏ប៉ុន្តែរឿងដែលទៅពីនិរតីទៅជំនួសឲ្យពាយ័ព្យ គឺខ្ញុំមិន<ដឹង>ដែរ <បើ>គេទៅគេចាប់ <ទៅគេចាប់ៗ>។ គេចាប់ហើយគេដាក់ទៅៗ។ អ៊ីចឹងខ្ញុំ<ក៏>មិនដឹងដែរបាទ។

**ស៖** តើលោកខ្លួនលោកផ្ទាល់ក៏ស្ថិតក្នុងក្រុមមួយក្នុងចំណោមក្រុមទាំងបួន គឺក្រុមដែលដឹកនាំដោយវៀតណាមនោះ។ គឺជាក្រុមដែលព្យាយាមបះបោរ ហើយនិងវាយប្រឆាំងជាមួយនឹងក្រុមដែលដឹកនាំដោយ ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ថាខ្ញុំនៅក្នុងក្រុមមួយក៏បាន ក៏ប៉ុន្តែ និយាយរួមគឺកុំតែទៅចាប់ខ្ញុំ ហើយកុំសម្លាប់ក៏វាអត់មានបញ្ហា។ តែទៅចាប់ខ្ញុំ ហើយសម្លាប់អស់មិត្តភក្ដិរបស់ខ្ញុំ យុទ្ធមិត្ត ហើយខ្ញុំទៅឃើញកូនអ្នកស្រុកអត់ឪពុកម្ដាយ យើងរើសមកចិញ្ចឹម ប៉ុណ្ណឹងហើយថាខ្ញុំក្បត់ ហើយខ្ញុំមិនដែលក្បត់ស្អី ហើយខ្ញុំមិនដែលទៅធ្វើខ្ញុំយួន ខ្សែរយៈយួនឯណា បើខ្ញុំនៅជាប់ឯសៀមឯណោះនោះ។ មិនដែលទាក់ទងស្គាល់យួនទេ ហើយស្គាល់ៗឆ្នាំ៧០ ដែលមកធ្វើគ្រូបង្វឹក គ្រូហ្វឹកហ្វឺន។ ប្រហែលជាឆ្នាំ៧២ គាត់ទៅវិញអស់ហើយ ៧៣អស់ ដកទៅវិញអស់។ អ៊ីចឹង វាមិនដែលមានទាក់ទងអីហ្នឹងខ្សែរយៈយួនទេ។ បាទ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** បាទ សោ ភឹម ឬក៏ រស់ ញឹម ឪពុកធម៌របស់លោក ឬក៏ចក្រី ឬក៏កុយ ធួន ឬក៏ ទីវ អុល ហ្នឹង មានទំនាក់ទំនងអ្វី មានទំនាក់ទំនងណាមួយជាមួយវៀតណាមសម្រាប់ការបះបោរនេះដែរទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** លោកសាក្សី ឥឡូវនេះ ខ្ញុំសូមចូលទៅការចាប់ខ្លួនលោកដែលលោកទើបតែនិយាយខ្លះៗមុននេះ -- លោកប្រធាន ដូចលោកប្រធានបានកត់សម្គាល់ហើយគឺខ្ញុំបានឡើងសួរពីរម៉ោងហើយ ខ្ញុំត្រូវការពេលវេលាបន្ថែមច្រើនទៀត។ ដូច្នេះ ឯងខ្ញុំសុំថែមពេលវេលាចំនួន ១០នាទីទៀត ខ្ញុំសូមការអនុញ្ញាតដើម្បីសួរសាក្សីបន្តទៅទៀតបន្ទាប់ពីពិសាបាយថ្ងៃត្រង់ចំនួន ១ម៉ោងទៀត លោកប្រធាន។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំស្នើសុំកុំអនុញ្ញាតឲ្យមេធាវីនូវពេលវេលាបន្ថែមនេះអី នេះមិនមែនជាការកាត់ក្ដីឡើងវិញទេ។ មេធាវីការពារក្ដីលើកសំណួរដែលមិនពាក់ព័ន្ធដូចជាសួរនៅក្នុងបញ្ហាឆេកូស្លូវ៉ាគី ឆ្នាំ១៩៦៨ គាត់មិនបានទៅសាកសួរនូវអ្វីៗដែលជាមានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខនោះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៤:២៤]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង តាមការពិភាក្សាហ្នឹង ថាអនុញ្ញាតឲ្យលោកមេធាវីហ្នឹងបន្ត ១០នាទីទៀត។

បាទ សូមអញ្ជើញ!

*(ចៅក្រមពិភាក្សាគ្នា)*

សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន អនុញ្ញាតឲ្យខ្ញុំសួរ ១០នាទីឥឡូវនេះ។ បាទ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានឆ្លើយខាងដើមថា លោកត្រូវបានចាប់ខ្លួន។ តើក្រោយពេលចាប់លើកដំបូងហ្នឹង គេឃុំខ្លួនលោកនៅឯណា?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ការចាប់ខ្លួនខ្ញុំលើកទី១នោះ គឺថាវាមិនបានខ្លួនខ្ញុំពិតប្រាកដទេ ព្រោះធ្វើដំណើរទៅពីរនាក់។ ខ្ញុំជិះកង់មុខ អនុប្រធានកុមារនោះ គេជិះកង់ពីក្រោយ។ គេចាប់បានអ្នកក្រោយ ហើយគេយកទៅសួរ គេវាយសួរចម្លើយសព្វមុខ សួររកឈ្មោះខ្ញុំហ្នឹង។ ដល់ឆ្លើយថាមិនមែនទេ ក៏យកទៅសួរជាង

ម៉ាស៊ីនទឹក ម៉ាស៊ីន -- ជាងម៉ាស៊ីនបូមទឹកនៅស្រែហ្នឹង។ បានប្រាប់ថា មិនមែនខ្ញុំទេ បានគេលែងមកវិញ លែង គឺខ្ញុំគេចាប់អត់បានទេ បាទ។

**ស៖** ក្រោយពេលចាប់ខ្លួនលោក គេឃុំខ្លួនលោកហ្នឹង នៅក្រោយ -- ចាប់ខ្លួន គេឃុំលោកនៅឯណា?

**ឆ៖** ខ្ញុំបានប្រាប់ថា គេចាប់ខ្ញុំមិនបានទេ ចាប់ច្រឡំខ្ញុំ។ ចាប់ចំអនុប្រធានរបស់ខ្ញុំ។ គេមិនបានយកទៅឃុំឯណាទេ គេវាយសួរហ្នឹងតែម្តង វាយសួរ ដឹងវាខុសឈ្មោះខ្ញុំ គេលែងមកវិញ។ បានដឹងដល់ខ្ញុំហើយខ្ញុំក៏ហែកក្រមារុំក្បាលបែកឈាម ហូរឈាមហ្នឹង ខ្ញុំហែកក្រមា បុកស្លឹកទន្ទ្រានខែត្រដាក់បាយដាក់អំបិលបិតឲ្យទៅ។ ហើយខ្ញុំប្រាប់ថា "ឯងនៅណាទៅហ្នឹងទៅ មិនបាច់នៅទៀតទេ មិនបាច់មកជុំគ្នាទៀតទេ ទៅស្រុកទៅភូមិវិញចុះ កន្លែងណាដែលទៅបានសុខ"។ អ៊ីចឹងគឺគេមិនចាប់បានខ្ញុំទេ។

**ប្រធានអង្គជំនុំ៖**

បានហើយសាក្សី។

[១១:៣៧:៥៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមកាត់ផ្តាច់។ ខ្ញុំសូមអានសារដែលជាចម្លើយរបស់កម្មាភិបាលមកភូមិភាគពាយ័ព្យ គឺឯកសារ E319/13.3.38, ERN ជាភាសាអង់គ្លេស 00978422, បារាំង 01004436, ខ្មែរ 00951906។ លោកនិយាយអំពីឈ្មោះ តាហំ។ "តើតាហំ មានមុខងារអី? លោកឆ្លើយថា៖ ជាអនុសេនាធិការភូមិភាគជាអនុប្រធានរបស់ តាខ្លែង។ តើមានអ្វីកើតឡើងដល់ចំពោះតាហំ? ឆ្លើយ៖ តាហំ ក៏ត្រូវបានចាប់ខ្លួនពួកគេត្រូវបានចាប់ខ្លួន។ ខ្ញុំបានទទួលព័ត៌មានថាកងពលទាំងពីរនៃភូមិភាគពាយ័ព្យមានផែនការវាយបកមកលើពួក ប៉ុល ពត វិញ ប៉ុន្តែផែនការនេះត្រូវបែកធ្លាយដោយសារភ្នាក់ងាររបស់មជ្ឈិម ហេតុដូច្នេះឯងបានជាកងទ័ពមួយចំនួនត្រូវគេចាប់ខ្លួន។ តាហំ ត្រូវបានគេចោទប្រកាន់ថា បញ្ជូនអាវុធយកទៅភ្នំវាយចាប។ ខ្ញុំដឹងបញ្ហានេះពីអ្នកបើកឡានម្នាក់ ដែលបានដឹកអាវុធទាំងអស់នេះយកទៅទីនោះ ក្រោយឆ្នាំ១៩៧៨។ ហើយនៅក្នុងកិច្ចប្រជុំថា បើសិនណាជា គឺថាយើងត្រូវតែងើបបះបោរដូចភូមិភាគបូព៌ាដែរ"។ លោកសាក្សី តើលោកត្រូវបានចាប់ខ្លួនជាមួយ ខ្លែង ដែរឬទេ? ហើយលោកត្រូវបានគេបញ្ជូនដែលចោទប្រកាន់ថាបានបញ្ជូនអាវុធ ដូចដែលយើងកំពុងតែពិភាក្សាគ្នានេះដែរទេ?

**ឆ៖** បាទ គឺគេចាប់ខ្លួនខ្ញុំអត់បានទេ ហើយអាវុធដែលយកទៅទុកហ្នឹង គឺនិយាយដូចជាច្រំដែល

ថា មិនបានយកទៅលាក់ទុកដើម្បីប្រឆាំងនឹង ប៉ុល ពត ទេ គឺរក្សាទុកឲ្យវាបានល្អ។ តែក្រោយ ប៉ុល ពត ធ្វើបាបខ្ញុំ ចាប់ខ្ញុំ ចាប់មិនបាន គឺខ្ញុំក៏សម្រេចចិត្តយកអាវុធហ្នឹងប្រើវិញទៅ វាយបកវិញទៅ បាទ។

[១១:៤០:៣៦]

**សៈ** លោកសាក្សី ក្រោយពេលគេចង់ចាប់ខ្លួនលោកហ្នឹង តើលោកទៅនាំកងទ័ពប៉ុន្មាននាក់ទៅជាមួយលោកចូលទៅក្នុងព្រៃដើម្បីបះបោរប្រឆាំងជាមួយមជ្ឈិម? តើកងទ័ពដែលលោកនាំទៅសរុបហ្នឹងទាំងអស់មានប៉ុន្មាននាក់ដែរ?

**ឆៈ** បាទ គឺមុនដំបូងខ្ញុំទៅតែប្រាំបួននាក់ទេ ទៅតែប្រាំបួននាក់ តាំងចិត្តថាធ្វើចោរទេ ចោរលួចស្រូវសហករណ៍ស៊ីហ្នឹង។ ខមាលទោស និយាយស៊ីអ៊ីចឹងចុះ កាលហ្នឹងហៅស៊ីអ៊ីចឹង ហូប បាទ។ ក្រោយខ្ញុំវាយទៅ វាយពួកដែលទើសមុខទើសមាត់ខ្ញុំ បន្ទាយពួក១០៨ចេញទៅ ពេលហ្នឹងគឺ បាក់កងចល័តក៏ទៅ មេកងៗក៏ទៅ រត់ទៅតាមពីក្រោយ រត់ទៅចូលជាមួយពួកខ្ញុំ។ ពេលហ្នឹងគឺធ្វើឲ្យខ្ញុំនឹងមានទឹកចិត្តបង្កើតកងទ័ពឡើងវិញ ហើយកងចល័តក៏គាត់និយាយថា គាត់នៅក៏ងាប់ ទៅហ្នឹងក៏ងាប់ បើមកហ្នឹងមានកាំភ្លើងតស៊ូ គាត់អាចនឹងរស់បានយូរ។ អ៊ីចឹង ខ្ញុំក៏បង្រៀនគាត់កាន់កាំភ្លើងទៅ ហើយខ្ញុំក៏សម្រេចចិត្តទៅយកឃ្លាំងកាំភ្លើងហ្នឹងមកប្រើវិញទៅ។

[១១:៤២:១៩]

**សៈ** លោកសាក្សី ខ្ញុំសុំកាត់លោកត្រឹមនេះ។ ខ្ញុំសុំសង្ខេបចម្លើយរបស់លោកឆ្លើយជូនអ្នកស៊ើបអង្កេត តើនៅពេលមួយ -- លោកអាចប្រាប់ខ្ញុំថាត្រឹមត្រូវឬមួយក៏អត់។ តើលោកធ្លាប់រត់ចូលក្នុងព្រៃជាមួយកងទ័ព ២០០០នាក់ ហើយតំបន់ទាំងអស់នៅភូមិភាគពាយ័ព្យ គឺស្ថិតនៅក្រោមការត្រួតត្រារបស់លោក លើកលែងតែតំបន់៧។ លោកក៏ចាប់ផ្ដើមបើកការប្រយុទ្ធជាមួយនឹងកងទ័ពភូមិភាគនិរតី ហើយនៅពេលមួយនោះ លោកបានធ្វើការទាក់ទងជាមួយ ឈូក មកពីភូមិភាគបូព៌ាដែលដឹកនាំ -- កងទ័ពមកពីភូមិភាគបូព៌ាដែលដឹកនាំដោយ ហេង សំរិន។ តើអ៊ីចឹងដែរឬក៏អត់ទេ?

**ឆៈ** បាទ គឺការតស៊ូនេះវាមិនមែនមានអង្គការចាត់តាំងឯណាទេ។ ដូចខ្ញុំបញ្ជាក់ថា ទៅតែប្រាំបួននាក់ទេដំបូងនោះ។ ដល់តែពេលគេរត់ទៅច្រើនតាមខ្ញុំទៅ ក៏ធ្វើឲ្យខ្ញុំមានទឹកចិត្តរៀបកម្លាំងតស៊ូឡើងវិញនៅតាមតំបន់នីមួយៗ ចាត់តាំងជាមេកងតំបន់ឡើងវិញ។ ដើរជ្រើសរើសទាហានចាស់ដែលគេយកទៅលត់ដំកាប់ចម្ការនៅភ្នំវាយចាប កាប់ចម្ការនៅត្បែង ហ្នឹងគេដកអស់តំណែងហើយ គេយកទៅលត់ដំ។ អ៊ីចឹង ខ្ញុំប្រមូលគ្នាបាន២០០០នាក់ ហ្នឹងទាហានចាស់។ ហើយបូកនឹងកងចល័តរាប់ចូលហ្នឹក

ហ្វឹនបន្ថែមប្រហែលជាជិត ២០.០០០នាក់។ បាទ បុណ្ណឹង។

**សៈ** ហើយថាតើនៅពេលនោះ លោកបានទំនាក់ទំនងជាមួយកងទ័ពភូមិភាគបូព៌ាដែលដឹកនាំដោយ ហេង សំរិន ដែរឬទេ? ដែលថាលោកជាមួយនឹងកម្លាំងរបស់ ហេង សំរិន នោះបានប្រយុទ្ធជាមួយនឹងកងទ័ពភូមិភាគនិរតី។ តើត្រឹមត្រូវដែរឬទេ?

[១១:៤៤:៣៦]

**ឆៈ** បាទ ការទាក់ទងជាមួយនឹងលោកតា ហេង សំរិន ខាងរណសិរ្សសាមគ្គីសង្គ្រោះជាតិនោះគឺក្រោយពេលដែលគាត់ទៅដល់កងទ័ពរណសិរ្សទៅដល់ខេត្តបាត់ដំបងទេ។ កាលលើកមុន ខ្ញុំអត់ដឹងទេ ខ្ញុំថាមានតែខ្ញុំទេ។ អ៊ីចឹងថាវាជាឯកោ រកស៊ីតាមដំណើរ មានអី វាយបានប៉ុន្មាន ហូបប៉ុណ្ណឹង។ ដល់អ៊ីចឹងទៅ ក៏ទ័ពមជ្ឈិមហ្នឹងក៏ទៅលើកទី១ហ្នឹង ខ្ញុំវាយបាក់អស់ រត់បាត់អស់ទៅ។ អ៊ីចឹងខ្ញុំក៏បានសុខសាន្ត ប៉ុន្មានពីរខែ បីខែដែរ។ ដល់ទៅលើកក្រោយ ចេះទៅវាយៗយូរៗ បាញ់គ្នាយូរៗទៅ វាចេះតែច្រើនទៅៗ ខ្ញុំអត់ដឹងថាវារត់ពីភ្នំពេញទៅឯណា អត់ដឹងរណសិរ្សដេញពីភ្នំពេញ ខ្ញុំអត់ទេ។ ដល់សួរ ចាប់បានទៅសួរថា មានរណសិរ្សសាមគ្គីសង្គ្រោះជាតិ មាន ប៉ែន សុវណ្ណ, ជា ស៊ីម -- ហេង សំរិន, ជា ស៊ីម អ៊ីចឹងទៅ។ ពេលហ្នឹង គឺកងទ័ពទៅដល់បាត់ដំបងអស់ហើយ កងទ័ពរណសិរ្សនោះ ហើយខ្ញុំក៏បានទាក់ទងគ្នានៅនឹងបាត់ដំបងទៅ ខ្ញុំមិនទាក់ទងនៅឯបូព៌ាទេបាទ។

**សៈ** ខ្ញុំមានសំណួរច្រើនទៀតពាក់ព័ន្ធទៅនឹងការវាយប្រយុទ្ធនេះ ប៉ុន្តែខ្ញុំសូមនិយាយ -- សួរអំពីការចាប់ខ្លួនឪពុកធម៌របស់លោក រស់ ញឹម។ មានសាក្សីម្នាក់ដែលបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតថា ឪពុកធម៌របស់លោកបានដឹងអំពីការ -- ផែនការចាប់ខ្លួន ក៏បានរត់គេចចេញទៅស៊ីសុផុន ហើយក៏ត្រូវចាប់បាននៅស្វាយស៊ីសុផុន ដោយសារតែគេយកឧទ្ធម្ភាគចក្រមួយជិះទៅចាប់ខ្លួនគាត់។ តើត្រឹមត្រូវដែរឬទេ?

[១១:៤៦:៤០]

**ឆៈ** បាទ ខ្ញុំអត់ដឹងទេ ប៉ុន្តែកាលនោះអត់មានឧទ្ធម្ភាគចក្រទេ វាអស់ហើយ យន្តហោះក៏អត់មានដែរ វាស្តផាល ស្តស្តាបព្រា ស្តអីអស់ហើយ។ ហើយពេលដែលជាប់ខ្លួនគាត់ ក៏មិនដឹងថាចាប់នៅឯណាដែរ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំទៅព្រៃផុតហើយ។

**លោក វ៉ិចទ័រ កូប៉េៈ**

សូមអរគុណលោកសាក្សី ដើម្បីប្រតិចារឹក គឺថាខ្ញុំមិនទាន់សួរសាក្សីអំពីការវាយប្រយុទ្ធទៅទីរួម

ខេត្តពោធិ៍សាត់នៅក្នុងឆ្នាំ១៩៧៥ នៅឡើយ ហើយតើមានអ្វីកើតឡើងទៅនឹងទាហាននៅទួលពោធិ៍ជ្រៃ។ ដូច្នេះ ខ្ញុំសូមស្នើសុំអង្គជំនុំជម្រះឲ្យបានជាក់លាក់ និងសូមការអនុញ្ញាតពេលវេលាពី ២០ ទៅ ២៥នាទីទៀត ដើម្បីសួរតែសំណួរទាក់ទងទៅនឹងការវាយប្រហារចូលទីរួមខេត្តពោធិ៍សាត់ និងអ្វីដែលបានកើតឡើងជាបន្តបន្ទាប់មកលើទាហានរបបសាធារណរដ្ឋខ្មែរ ទាហានដែលវាយប្រយុទ្ធដើម្បីរបប លន់ នល់ នោះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ខ្ញុំសូមបញ្ជាក់លោកមេធាវីបន្តិចទាក់ទងអំមិញនេះ គឺដំបូងលោកថាសុំ១០នាទី ហើយគាត់ត្រូវការ និងចង់សុំបន្ថែមរហូតដល់មួយម៉ោងទៀត តែអំមិញនេះគឺលោកថា សុំ២០ ទៅ៣០។ អ៊ីចឹង២០ ទៅ៣០នាទីបន្ថែមនេះ គឺសម្រាប់បញ្ចប់តែម្តង ឬក៏ត្រឹមតែសួរមួយផ្នែកហ្នឹងទេ មើលសួរបញ្ជាក់? ឥឡូវ បើសិនជាអ៊ីចឹងទេ លោកអាចថាឥឡូវសុំជាទូទៅហ្នឹងប៉ុន្មានតែម្តង? សូមបន្ថែម?

[១១:៤៨:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាមានបញ្ហាក្នុងការបកប្រែ។ ខ្ញុំស្នើសុំរយៈពេលមួយម៉ោង ហើយក្រោយមកលោកប្រធានសម្រេចឲ្យខ្ញុំ១០នាទី។ ប្រហែលវាមានការស្តាប់ច្រឡំគ្នាត្រង់ចំណុចនេះ។ ឥឡូវនេះ ខ្ញុំសុំបន្ថែមពី២០ ទៅ ២៥នាទីទៀតតែប៉ុណ្ណោះ ដើម្បីចោទសំណួរពីបញ្ហាវាយប្រយុទ្ធចូលទៅក្នុងទីរួមខេត្តពោធិ៍សាត់ និងអ្វីកើតឡើងនៅទួលពោធិ៍ជ្រៃ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះ ខ្ញុំសូមបញ្ជាក់បន្ថែមថា ២០ ទៅ ២៥ ឬក៏៣០នាទី ដែលសុំបន្ថែមហ្នឹង គឺបញ្ចប់ទាំងអស់តែម្តង ឬក៏តែមួយផ្នែកទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន សូមសរុបបញ្ចប់តែម្តង។ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំសួរអំពីខែមីនា ឆ្នាំ១៩៧៥ តើលោកនៅចាំអ្វីខ្លះដែរ អំពីការវាយប្រហារ--

**ប្រធានអង្គជំនុំ៖**

អ៊ីចេះលោកមេធាវី គឺឥឡូវយើងដល់វេលាសម្រាកហើយ។ អ៊ីចឹងសំណើរបស់លោកថា សូម

២០ទៅ៣០នាទីហ្នឹង គឺអង្គជំនុំជម្រះនឹង -- ពេលទៅហូបបាយហ្នឹង នឹងសម្រេចអំពីពេលវេលាហ្នឹង ពីពេលវេលា ហើយខ្ញុំជម្រាបផងដែរថា សាក្សី ទាត់ ធឿន គាត់អាចមានពេលវេលាដើម្បីឆ្លើយនឹងសក្ខីកម្មនៅពេលនេះ។ អ៊ីចឹង គឺនៅពេលនេះ គឺតុលាការប្រកាសសម្រាកសិន ហើយលោកមន្ត្រីខាងពន្ធនាគារសូម--

បាទ អញ្ជើញ!

[១១:៥០:៣៣]

**ចៅក្រម អាកនីស្កា ក្លួណ្ឌវីកកា មីឡាត៖**

គឺថាសម្រាប់ទាំងមេធាវីការពារក្តី ក៏ដូចសហព្រះរាជអាជ្ញា គឺសម្រាប់ការសាកសួរសាក្សី។ បាទ មេធាវីទាំងពីរក្រុម ថាតើលោកអាចយល់ស្របអំពីការប្រើប្រាស់ពេលវេលានេះ រួម គឺថាចែកគ្នាក្រោយពីពេលឈប់សម្រាកបាយថ្ងៃត្រង់ហើយនេះ ក្រុមទាំងពីរហ្នឹង ចែកគ្នាយ៉ាងម៉េចដែរ?

**លោក អាកទួរ វែកគែន៖**

ខ្ញុំមិនយល់ច្បាស់សំណួររបស់លោកស្រីចៅក្រមទេ។ ខ្ញុំគិតថា ខ្ញុំមានពេលវេលាគ្រប់គ្រាន់សម្រាប់សួរសំណួរ ហើយបើសិនបើសល់ពេលវេលាខ្លះ ខ្ញុំប្រគល់ម៉ោងសល់ហ្នឹងទៅឲ្យខាងមេធាវីកូប៉េ ក៏ប៉ុន្តែខ្ញុំមិនទាន់បានសួរពាក់ព័ន្ធទៅនឹងប្រធានបទផង។ អ៊ីចឹង ខ្ញុំពិបាកទស្សន៍ទាយគ្រោងទុកមើលណាស់ ថាតើពេលវេលាខ្ញុំសល់ ឬមិនសល់ សម្រាប់ក្រុម នួន ជា នោះ។

**ចៅក្រម អាកនីស្កា ក្លួណ្ឌវីកកា មីឡាត៖**

ការដែលអង្គជំនុំជម្រះសួរនេះ ដោយសារថាយើង គឺថាខើចពេលវេលា។ ហើយយើងក៏ចាំផងដែរថាមានសំណើសុំពីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏សុំពេលវេលាបន្ថែម។ ប៉ុន្តែដើម្បីជាផលប្រយោជន៍ថា ក្នុងការតាំងសំណួរដោយរបៀបណាៗនោះ អ៊ីចឹង យើងត្រូវពិចារណាទៅលើចំណុចនេះផងដែរ។ ហេតុដូច្នេះឯង បានជាយើងចង់បានដឹងឲ្យបានច្បាស់មុនពេលសម្រាកពិសាបាយថ្ងៃត្រង់ គឺនឹងសម្រេចទៅលើបញ្ហាសំណើសុំនេះ។

[១១:៥២:២០]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំនឹងកម្រិតពេលវេលារបស់ខ្ញុំ ពី២០ ទៅតែ២៥នាទីទេ។ និងហើយប្រគល់តួនាទីនេះ ទៅមេធាវីការពារក្តី ខៀវ សំផន ដើម្បីសួរបន្តពេញមួយរយៈពេលនៃ

រសៀលនេះ។

**ប្រធានអង្គជំនុំ៖**

ហើយសូមអរគុណ ហើយអ៊ីចឹងតុលាការប្រកាសសម្រាកសិន។

ហើយសូមអញ្ជើញមន្ត្រីពន្ធនាគារជូនជនជាប់ចោទទៅទីកន្លែងវិញ ហើយនិងជូនមកវិញ នាំមកវិញនៅវេលាម៉ោង មុនម៉ោងដប់បីនិងម្ភៃនាទី ហើយយើងម៉ោងដប់បីនិងម្ភៃនាទី យើងនឹងចូលមកវិញ។

បាទ អ៊ីចឹង សូមអញ្ជើញ ប្រកាសសម្រាក។

*(សវនាការសម្រាកពីម៉ោង ១១:៥៣ នាទី ដល់ម៉ោង ១៣:២០ នាទី)*

[១៣:២៣:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ។ ហើយតាមការពិភាក្សារបស់ចៅក្រមនៅពេលហូបបាយនេះ គឺអនុញ្ញាតឱ្យលោកមេធាវីការពារក្ដី នួន ជា គឺបន្ថែម២៥នាទី។ ហើយអ៊ីចឹងសូមអញ្ជើញលោកមេធាវីតាំងសំណួរដល់សាក្សី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហការី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំចង់ត្រឡប់ទៅនិយាយអំពីខែដំបូង ខែទី១ នៃឆ្នាំ១៩៧៥ គឺការវាយសម្រុក ការវាយប្រយុទ្ធចុងក្រោយចូលទីរួមខេត្តបាត់ដំបង ស៊ីសុផុន នៅភូមិភាគពាយ័ព្យ។ លោកដឹងថា អ្នកណាជាអ្នកដឹកនាំកងទ័ពវាយសម្រុកចូលទីរួមខេត្តទាំងនេះ? គឺអ្នកណាជាអ្នកដឹកនាំកងទ័ពវាយសម្រុកផ្ដាច់ព្រ័ត្រចូលរំបអូសទីរួមខេត្តទាំងនេះ?

[១៣:២៥:២១]

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ សូមគោរពលោកចៅក្រម និងខ្ញុំឆ្លើយនឹងសំណួរគឺ រស់ ញឹម ជាអ្នកដឹកនាំវាយ។

**ស៖** សូមអធ្យាស្រ័យ ខ្ញុំឮថា រស់ ញឹម ជាអ្នកដឹកនាំការវាយប្រហារចុងក្រោយ។ ចុះ ខ្លែង តើ

មានតួនាទីអីក្នុងការរៀបចំការវាយប្រយុទ្ធផ្ដាច់ព្រ័ត្រនេះទេ?
**ឆ៖** គាត់ជាសេនាធិការ។
**ស៖** តើគាត់ចូលរួមនៅក្នុងការរៀបចំផែនការវាយប្រយុទ្ធផ្ដាច់ព្រ័ត្រនេះទេ?
**ឆ៖** បាទ ចូល។
**ស៖** ចុះលោកវិញ តើលោកមានតួនាទីអ្វីពិតប្រាកដក្នុងការវាយសម្រុកនេះដែរ?
**ឆ៖** បាទ ខ្ញុំខាងរត់សារ១ពីទីបញ្ជាមុខមកមន្ទីរខាងក្រោយ។
**ស៖** តើវាជាការវាយប្រយុទ្ធរួមគ្នារវាងកងពលទាំងពីរ ដែលចំណុះឲ្យភូមិភាគពាយ័ព្យគឺថា តើកងពលទាំងពីរប្រយុទ្ធរួមគ្នា ឬក៏អត់ទេនៅខែមេសា ១៩៧៥?
[១៣:២៧:៤៨]
**ឆ៖** បាទ ប្រយុទ្ធវាចែកតំបន់គ្នា។ កងពល១០០៧ លេខខ្ទង់សំបុត្រ គឺវាយពីត្បូងទៅជើង ហើយ១០០៦ វាយពីជើងមកត្បូង។ លេខខ្ទង់សំបុត្រដាក់លេខ១០០៧, ១០០៦ បាទ។
**ស៖** លោកសាក្សី លោក -- ក្នុងពេលហ្នឹង តើកងពល១០០៧, ១០០៨ គឺថាមានលេខផ្សេងគ្នាដែរទេ?
**ឆ៖** បាទ វាមាន អត់មានកងពលលេខផ្សេងទេ វារបៀបប្រើ។ ការខ្ទង់ គេដាក់លេខក្បាលពាន់ ដល់ក្នុងសារដាក់លេខ០៧, ០៦។
**ស៖** តើកងពលទាំងពីរវាយប្រយុទ្ធជោគជ័យ ផ្ដាច់ព្រ័ត្រទៅលើកង -- ទៅលើទាហានរបស់ លន់ នល់ នៅពេលណា? តើក្រោយថ្ងៃ១៧ មេសា ១៩៧៥ ឬក៏យ៉ាងណា?
**ឆ៖** បាទ ថ្ងៃវា ខ្ញុំចាំមិនច្បាស់ ប្រហែលជាក្នុងថ្ងៃតែមួយ ឬក៏ក្រោយថ្ងៃមួយថ្ងៃ វាពីរថ្ងៃ ចាំមិនច្បាស់ដែរ ព្រោះខ្ញុំវាយូរឆ្នាំហើយ។
**ស៖** នៅពេលដែលកម្លាំងទាហានរបស់ លន់ នល់ បរាជ័យជាផ្លូវការ តើមានអ្វីកើតឡើងចំពោះប្រជាជនរស់នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់? តើប្រជាជនត្រូវបានគេជម្លៀសដែរ ឬក៏យ៉ាងណា?
**ឆ៖** បាទ ពេលដែលរំដោះភ្លាម មាន តាវ៉ាញ គាត់ជាអ្នកកាន់ឃោសនាសព្ទប៉ុស្តិ៍វិទ្យុចម្ការចេក អំពាវនាវឲ្យទាហាន លន់ នល់ ទាំងអស់ដាក់អាវុធ។ ប្រជាជនទាំងអស់ក៏អបអរសាទរសប្បាយ។ ក្រោយមក បានប្រហែលជា ខ្ញុំដូចមិនចាំច្បាស់ដែរទេ វាយូរហើយ វាមិនពិតប្រាកដថ្ងៃទេ។ ក្រោយមក

ប្រែក្លាយការសប្បាយរបស់គាត់ទៅជាការកើតទុក្ខ ដែលថាជម្លៀសគាត់ចេញពីផ្ទះសម្បែង ពីទីរួមខេត្ត ពីទីប្រជុំជន ចេញទៅដេកនៅព្រៃ ប្រជាជនបាននៅតាមព្រៃ អត់មានផ្ទះ អត់មានសម្បែង បាទ។

[១៣:៣១:៣៨]

**ស៖** ហើយតើមានអ្វីកើតឡើងទៅដល់ទាហាន លន់ នល់ ដែលសុំចុះចាញ់ ហើយទម្លាក់អាវុធចុះនោះ តើមានអ្វីកើតឡើងដល់ពួកគាត់?

**ឆ៖** បាទ ពេលនោះ គឺគេប្រមូលឱ្យទៅទទួលសម្តេចព្រះ នរោត្តម សីហនុ។ គេដឹកទៅទាំងឡានៗទៅ។ ហើយខ្ញុំក៏ខាងអ្នករត់សារក៏ច្រណែនដែរ នៅព្រៃយូរហើយ អត់បានទៅទទួលស្តេចនឹងគេ ចេះតែគិតគ្នាឯង អ្នករត់សារហ្នឹង។ ដល់ក្រោយមក ប្រហែលជា១០ថ្ងៃ បានខ្ញុំដឹងថា គេយកទៅសម្លាប់ចោល បាទ។

**ស៖** ហើយអ្នកណាដែលមកពី អ្នកណាដែលមកពីកម្លាំងភូមិភាគពាយ័ព្យទទួលខុសត្រូវចំពោះការសម្លាប់ទាហាន លន់ នល់ នេះ?

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមជំទាស់ ដែលសួរថាអ្នកណាដែលជាកងទ័ពនៅភូមិភាគពាយ័ព្យទទួលខុសត្រូវហ្នឹង។ គឺជាការសួរដោយឱ្យសន្មត ដូច្នេះ ខ្ញុំសូមឱ្យមេធាវីការពារក្តីរៀបចំសំណួរឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាបញ្ហាអ្វីទេ ខ្ញុំអាចរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់ គឺខ្ញុំចង់សំដៅអ្នកណាទទួលខុសត្រូវចំពោះអំពើសម្លាប់ដោយផ្ទាល់ដៃ ទៅលើទាហានរបប លន់ នល់ បាទ?

[១៣:៣៣:៥២]

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំមិនដឹងច្បាស់ទេ ឃើញតែដឹកទាំងឡានៗទៅ ថាទទួលសម្តេច ហើយអ្នកណាអ្នកសម្លាប់ ខ្ញុំក៏អត់ដឹងដែរ ព្រោះឡានដឹកទៅហ្នឹង គឺឡានដែល អាសេ.អឹម.សេ របស់ទាហាន លន់ នល់ហ្នឹង និងឡានអាដូតសំណាញ់ អ៊ីចឹងខ្ញុំឃើញថា គេបានទទួលស្តេច ឯខ្ញុំនៅយូរហើយ វាមិនបានទៅនឹងគេ វារៀងអន់ចិត្តដែរ។ ប៉ុណ្ណឹង អត់ដឹងថាអ្នកណាគេយកទៅសម្លាប់ អ្នកណាជាអ្នកដៃដល់ អ្នកសម្លាប់

គឺខ្ញុំអត់ដឹងដែរ។

**ស៖** លោកសាក្សី ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្តាប់ ចេញពីចម្លើយរបស់កងទ័ពម្នាក់មកពីភូមិភាគពាយ័ព្យ ដែលបានផ្តល់សក្ខីកម្មជូនតុលាការនេះរួចហើយ ខ្ញុំសូមអានឈ្មោះជូនគាត់។ គាត់ឈ្មោះ អ៊ុង ឆាត់ -- អ៊ុង ឆាត។ ឯកសារ E3/5774, ERN ភាសាអង់គ្លេស 00284420, បារាំង 00352333, ខ្មែរ 00277333 ។ ខ្ញុំសូមអានសម្រង់ខ្លីមួយចេញពីចម្លើយរបស់សាក្សីរូបនេះ ហើយសួរទៅលោកថាតើ លោកមានប្រតិកម្មយ៉ាងម៉េចដែរ។ "សំណួរ៖ តើកងវរសេនាតូចរបស់ តាសារុន នោះចូលរួមក្នុងប្រតិបត្តិការសម្លាប់ទាហានលន់ នល់ នៅទួលពោធិ៍ជ្រៃដែរឬទេ? ឆ្លើយ៖ អ្នកដែលចូលរួមដោយផ្ទាល់គឺ តាឃ្លាំង តាសុត និង តាសាន។" ហើយទំព័រអង់គ្លេសដដែលនេះនៅផ្នែកខាងលើនៃទំព័រដដែលគឺ គាត់ឆ្លើយដូចតទៅ៖ "សួរ៖ តើកងទ័ពខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ ហ្នឹងមកពីទ័ពខ្មែរក្រហមមកពីខាងណា? អ៊ុង ឆាត ឆ្លើយដូចតទៅ៖ អង្គភាពរបស់ខ្ញុំនៅក្នុងវរសេនាតូចលេខ២៦ ខ្ញុំដឹងថាទាហានដែលមកពីវរសេនាតូច២០៦ មកពីតំបន់៧ ហើយនិងកងទ័ពភូមិភាគពីតំបន់៤ គឺជាអ្នកធ្វើប្រតិបត្តិការសម្លាប់នេះ។" តើលោកយល់យ៉ាងម៉េចដែរចំពោះចម្លើយរបស់សាក្សីរូបនេះ?

[១៣:៣៧:០០]

**លោក នីកូឡាស គូមជែន៖**

លោកប្រធានខ្ញុំយល់ឃើញថាដូចជាមិនមានជំនួយអ្វីទេក្នុងការសួរ អានសម្រង់ហើយ សួរពីប្រតិកម្មរបស់គាត់។ គួរណាសួរថាតើគាត់ដឹង ឬក៏មិនដឹង។ តាំងសំណួរណាមួយជាក់លាក់ទៅថា តើសាក្សីរូបនេះដឹង យល់ព្រម យល់ស្របតាមឬក៏អត់។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធានបើសិនណាជាខ្ញុំត្រូវបាន -- គាត់បានបញ្ជាក់ហើយសាក្សីនេះ ថាគាត់មិនច្បាស់ថាអ្នកណាជាអ្នកទទួលខុសត្រូវ អ៊ីចឹងឯង ខ្ញុំថាសមស្របណាស់ក្នុងការសួរផ្ទៀងរូបគាត់ដោយសួរបែបនេះ ដូច្នេះខ្ញុំថាដំណាក់កាលនេះគឺអង្គជំនុំជម្រះគួរអនុញ្ញាតឲ្យខ្ញុំអានសម្រង់ចេញពីចម្លើយរបស់សាក្សី អ៊ុង ឆាត នេះ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះអំមិញខ្ញុំបាន តាមខ្ញុំស្តាប់ឮ គាត់បញ្ហាដែលគាត់សួរហ្នឹង គាត់ចង់សួរសាក្សីថា ស្អីដែលចម្លើយដែលគាត់រៀបរាប់អំមិញហ្នឹងគឺសាក្សីប្រតិកម្មយ៉ាងម៉េច? ហើយតាមខ្ញុំយល់ថាលំបាកក្នុងការ

សាក្សីក្នុងការពិចារណាក្នុងការដែលគាត់ហ្នឹងឆ្លើយតប។ អ៊ីចឹងបើមេធាវីអាចផ្លាស់ប្តូរសំណួរបានកែសំណួរហ្នឹងបាន អាចអញ្ជើញកែទៅ ដើម្បីឲ្យងាយស្រួលក្នុងការឆ្លើយផង។

**លោក វ៉ិចទ័រ កូប៉េ៖**

ពិតហើយលោកប្រធាន ខ្ញុំអាចរៀបចំសំណួរឡើងវិញ។

[១៣:៣៨:៥២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើកងកម្លាំងនៃកងពល១០០៦ និងកងពលលេខ១០០៧ ចូលរួមពាក់ព័ន្ធនៅក្នុងការសម្លាប់ ឬក៏ការប្រហារជីវិតអតីតទាហានលន់ នល់ ដែរឬទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ គឺខ្ញុំមិនដឹងដែរ ព្រោះខ្ញុំខាងអ្នករត់សារ ពីកន្លែងទីបញ្ជាការ តាញឹម មកមន្ទីររបស់គាត់នៅខាងក្រោយ មន្ទីរលេខ២០។ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកសម្លាប់ដែរបាទ។

**ស៖** តែតើអ្នកណាជាអ្នកសម្រេចថាទាហានដែលបានចុះចាញ់នេះត្រូវតែសម្លាប់ចោល? ហើយហេតុអ្វីបានគេសម្លាប់ទាហានទាំងនេះ?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរបាទ។

**ស៖** លោកមិនដឹងទាំងថាអ្នកណាជាអ្នកសម្រេចឲ្យសម្លាប់ ហើយក៏មិនដឹងថាមូលហេតុអ្វីបានជាគេសម្លាប់ទាហានទាំងនោះ។ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ។

**ស៖** ពិចារណាទៅលើរចនាសម្ព័ន្ធយោធានៃកងពល១០០៦ និងកងពលលេខ១០០៧ ដែលដឹកនាំដោយឪពុកធម៌របស់លោក។ តើត្រឹមត្រូវទេបើខ្ញុំសួរលោកថា ឪពុកធម៌របស់លោកនេះ គឺជាអ្នកដែលបានចេញបញ្ជាឲ្យសម្លាប់អតីតទាហាន លន់ នល់ ទាំងនេះ? តើវាត្រឹមត្រូវដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរទេ ព្រោះខ្ញុំនៅតែខាងរត់សំបុត្រទេ រត់សារទេបាទ។ ខ្ញុំមិនប៉ានសម្រេចថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវទេបាទ។

[១៣:៤១:១៨]

**ស៖** នៅក្នុងឆ្នាំដដែលនោះ ក្រោយមកលោកសាក្សី លោកក្លាយទៅជានាយសេនាធិការរង។ ហើយក្នុងឆ្នាំដដែល លោកក៏ទទួលខុសត្រូវចំពោះការប្រមូលអាវុធយុទ្ធភណ្ឌដែលបានមកពីទាហាន

ទាំងនេះ។ ក្នុងសមត្ថភាពរបស់លោកនេះ តើលោកបានឮទេ ក្រោយមកថាអ្នកណាជាអ្នកដែលចេញបញ្ជាឲ្យសម្លាប់ទាហានទាំងអស់នេះ?

**ឆ៖** ខ្ញុំអត់បានឮទេ ព្រោះខ្ញុំខាងទទួលបន្ទុកនឹងខាងអាវុធហ្នឹង គឺប្រមូលដែលអាវុធយកទៅគរចោលនៅប៉ុស្តិ៍ចម្ការចេកហ្នឹង រាយប៉ាយនៅហ្នឹង។ មានតែប៉ុណ្ណឹង អត់ប៉ាន ព្រោះកាលនុំងការងាររបស់អ្នកណា គឺអ្នកហ្នឹងដឹង អត់មានសួរដេញដោលគេបានទេ។ បាទ មានប៉ុណ្ណឹង។

**ស៖** ប៉ុន្តែលោកបាន -- ពិតជាបានឮថាទាហានទាំងអស់ត្រូវបានគេប្រមូលយកឲ្យប្រជុំដើម្បីទៅទទួលសម្តេចឪ ហើយលោកឆ្លើយថាលោកច្រណែនដែរ ដែលថាលោកមិនបានទៅ -- ធ្វើជាកងទ័ពយូរហើយ។ តើលោកបានឮការប្រកាសឲ្យទៅទទួលសម្តេចនៅពេលណា? ហើយអ្នកណាជាអ្នកប្រកាសឲ្យទៅទទួលសម្តេចហ្នឹង?

**ឆ៖** បាទ ពេលដែលថាឲ្យទាហានទៅទទួលសម្តេចហ្នឹង គឺ តាវ៉ាញ។

**ស៖** ប៉ុន្តែតើលោកឮសួរការអំពាវនាវនោះនៅពេលណា? តើមានការចូលរួមពេញលេញតែម្តងចូលរួមទាំងអស់គ្នាតែម្តងហើយ ក្រោយមកក៏ត្រូវគេសម្លាប់ចោលហ្នឹង តើលោកឮសួរដំណឹងហ្នឹងនៅពេលណាជាលើកដំបូងបំផុតនោះ?

**ឆ៖** បាទពេលដែលខ្ញុំឮដំណឹង ពេលដែលខ្ញុំត្រឡប់ពីយកសារទៅឲ្យមន្ទីរត្បូលេខនៅលេខ ២០។

[១៣:៤៤:០១]

**ស៖** តើហ្នឹងនៅក្នុងឆ្នាំ១៩៧៥ ឬ១៩៧៦ ឬ ១៩៧៧?

**ឆ៖** ប្រហែលជាវាយូរដែរ ខ្ញុំមិនចាំពេលវេលាប៉ុន្មានទេ ប៉ុន្តែក្នុងអំឡុងប្រហែលជារំដោះហើយបានប្រហែលជា១០ថ្ងៃ ឬក៏ បើខ្វះៗតិចតួច បើលើសៗតិចតួចដែរ បាទ។

**ស៖** ដូច្នេះ ភ្លាមៗក្រោយថ្ងៃរំដោះ លោកបានឮអំពីជោគវាសនារបស់ទាហាន លន់ នល់ ទាំងនេះ។ តើត្រឹមត្រូវទេ មានន័យថា ភ្លាមៗក្រោយថ្ងៃរំដោះមែនទេ?

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន គឺសាក្សីបានឆ្លើយថា គាត់បានឮការអំពាវនាវឲ្យទាហានទាំងនេះទៅជួបជុំគ្នាទៅទទួលសម្តេចឪ គាត់មិនបានឆ្លើយថាគាត់ឮភ្លាមៗទេ។ ដូច្នេះ មេធាវីគួររៀបចំ ថាតើគាត់បានឮនៅពេលណា?

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួររបស់ខ្ញុំប្រហែលជាវាមិនច្បាស់ ខ្ញុំអាចរៀបចំឡើងវិញបាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើពេលណាដែលលោកបានឮអំពីជោគវាសនានៃទាហាន លន់ នល់ ទាំងអស់នេះ។ លោកបានឮដំបូងហ្នឹងនៅពេលណា? ឮថាពួកគេត្រូវបានយកទៅសម្លាប់ចោល? តើក្រោយថ្ងៃរំដោះឬក៏ពេលណា?

**លោក ទាត់ ធឿន៖**

**ឆ៖** ដូចខ្ញុំបានបញ្ជាក់លើកមុនហើយ ពីមុនមកអំមិញហ្នឹងហើយថា ក្រោយថ្ងៃរំដោះប្រហែលជា១០ថ្ងៃ ឬក៏លើស ១០ថ្ងៃតិចតួច ឬក៏ក្រោម ១០ថ្ងៃតិចតួចបាទ។ ព្រោះខ្ញុំចាំវាមិនច្បាស់ ព្រោះយូរពេកហើយ។

**ស៖** តើលោកមានបាននិយាយទៅ ឃ្លាំង ឬក៏បាននិយាយទៅកាន់ឪពុកធម៌របស់លោកថា ហេតុអ្វីបានជាទាហានទាំងអស់នេះត្រូវបានគេសម្លាប់ចោល? តើវាមានមូលហេតុអីទេ? តើលោកមានការសន្ទនាគ្នា ហើយសួរពីមូលហេតុនេះទេ?

[១៣:៤៦:៣៧]

**ឆ៖** បាទ អត់មានបានសួរគាត់ទេ។ ព្រោះគាត់នៅតែគាត់ ហើយខ្ញុំក្រុមនីរសារគឺនៅឆ្ងាយពីគាត់ប្រហែលជា ៥០ម៉ែត្រ។ បាទ ខ្ញុំនៅផ្ទះមួយ គាត់នៅផ្ទះមួយជាមួយនឹងកងការពារ។ ឯខ្ញុំនីរសារគឺនៅផ្ទះមួយនៅឃុំ ក្នុងឃុំកំពង់ព្រះ ភូមិបញ្ញា ហើយខ្ញុំគ្រាន់តែពេលដែលគាត់ឲ្យសារ សារហ្នឹងគឺគាត់បិទស្រោមអស់ហើយ គឺខ្ញុំយកមកមន្ទីរលើ។ ម៉ូម្យប់ បកវិញម៉ូម្យប់។ ទៅដល់មិនបានទៅជួបគាត់ទេពេលមកដល់គ្រាន់តែប្រាប់ថា "ខ្ញុំមកវិញហើយប៉ុណ្ណឹង" ហើយខ្ញុំក៏នៅចម្ងាយពីគាត់ដដែលវិញទៅ។

**ស៖** លោកសាក្សី ខ្ញុំសុំសួរតាមរបៀបផ្សេងវិញ។ ព្រឹកមិញនេះ លោកបានផ្តល់សក្ខីកម្មអំពីការអំពាវនាវដែលថា នួន ជា និង ខៀវ សំផន។ ដោយសារថាក្នុងបណ្តឹងសាទុក្ខនេះគឺថា នួន ជា, ខៀវ សំផន បានប្តឹងសាទុក្ខទៅនឹងសេចក្តីសម្រេចនេះ។ ដោយសារថាសាលាដំបូងបានសម្រេចថា ឪពុកធម៌របស់លោកនេះ បានបញ្ជាឲ្យមានការសម្លាប់ទាហានទាំងអស់នេះ។ តើត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេ?

**លោក នីកូឡាស គូមជែន៖**

គាត់មិនបានឆ្លើយថា គាត់មិនបានដឹងថា រស់ ញឹម បញ្ជា ឬក៏មិនបញ្ជានោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបានគិតហើយថា ខ្ញុំព្យាយាមជាការពិតហើយ ក៏ប៉ុន្តែខ្ញុំយល់ថា ខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរ អ៊ីចឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើឪពុកធម៌របស់លោកជាអ្នកចេញបញ្ជាឲ្យសម្លាប់ឪពុកធម៌ទាំងអស់នេះជាផ្លូវការតែម្ដង ឬក៏យ៉ាងណាលោក -- ទាហាន លន់ នល់ ជាផ្លូវការតែម្ដងឬក៏យ៉ាងណា?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាសំណួរនេះគឺថាសំណួរដដែលទេ ខ្ញុំសុំជំទាស់។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរនេះគឺសំណួរដដែលមែន ប៉ុន្តែសុំលោកសាក្សីឆ្លើយនឹងសំណួរហ្នឹងម្ដងទៀតចុះ។

**លោក ទាត់ ធឿន៖**

**ឆ៖** ខ្ញុំមិនដឹងថា ពីត្រឹមណាអ្នកបញ្ជាសម្លាប់ពីត្រឹមណាទេ ខ្ញុំអត់ដឹងទេ។

[១៣:៤៩:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ មិនថ្វីទេលោកសាក្សី។ តើលោកដឹងទេថា ក្រោយថ្ងៃរំដោះថ្ងៃ១៧ ខែមេសា ១៩៧៥ នៅក្នុងកងទ័ពភូមិភាគពាយ័ព្យនេះ គឺថាវាមានការអារម្មណ៍ខឹងសម្បាសងសឹក ចំពោះអំពើឃោរឃៅព្រៃផ្សៃការសម្លាប់ពីសំណាក់កងទ័ពលន់ នល់ ដូច្នេះគឺក៏មានកំហឹង និងក៏មានអំពើសងសឹកនេះ។ លោកបានឮពីបញ្ហានេះទេ?

**ឆ៖** បាទ អត់ដែលឮពាក្យទាំងអស់នោះទេ ការសងសឹកទេ ឮថារំដោះប្រទេសបានតែប៉ុណ្ណឹង ហើយសប្បាយជួបជុំបងប្អូន ក្រុមគ្រួសារឡើងវិញ។ បាទ ដឹងតែប៉ុណ្ណឹង។

**ស៖** ហើយសំណួរចុងក្រោយរបស់ខ្ញុំ លោកសាក្សី គឺទាក់ទងទៅនឹងព្រឹត្តិការណ៍ជាក់លាក់ដែលកើតឡើងនៅឯទួលពោធិ៍ជ្រៃ មានភស្តុតាងបង្ហាញថា មេបញ្ជាការទាហាន លន់ នល់ នៃ -- បានកាត់កទាហានទាំងអស់នេះ។ ខ្ញុំចង់បង្ហាញជូនលោកនូវរូបថតមុនថ្ងៃរំដោះថ្ងៃ១៧ មេសា ៧៥ នេះ គឺជាសំណួរចុងក្រោយរបស់ខ្ញុំលោកប្រធាន ហើយខ្ញុំសូមបង្ហាញឯកសារ E319 អង់គ្លេស 0039--

**អ្នកបកប្រែ៖**

លោកប្រធានសូមការអធ្យាស្រ័យ មេធាវីអាន ERN ញាប់ពេក តាមអត់ទាន់ទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអានមួយៗ ខំគាត់តាមអត់ទាន់ទេ អានឡើងវិញបាទ!

[១៣:៥២:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺជារូបថតចេញពីសៀវភៅមួយដែលសរសេរដោយលោក ហ្វីលីព ស្សូត គឺឯកសារ E3/9, អង់គ្លេស 00396327, បារាំង 00639638 មិនមានការបកប្រែជាភាសាខ្មែរនៅឡើយទេ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះឲ្យខាងផ្នែកសោតទស្សន៍ ដើម្បីបង្ហាញរូបថតនេះទៅឲ្យសាក្សីមើល ហើយសួរថាតើគាត់យល់យ៉ាងណាដែរ?

លោកប្រធាន តើខ្ញុំទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញរូបថតនេះនៅលើអេក្រង់ទេ?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញដាក់បង្ហាញ!

*(ការបង្ហាញរូបភាពនៅលើអេក្រង់)*

[១៣:៥៣:៥៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នេះគឺជារូបថតដែលគេបានថតដូចតទៅ នៅក្នុងសង្គ្រាមស៊ីវិល នៅក្នុងពីចន្លោះពីឆ្នាំ១៩៧០ ដល់៧៥ ទាហានទាំងសងខាងហ្នឹង គឺថាក៏បានកាត់ក្បាលកងទ័ពកុម្មុយនីស្តដែរ។ រូបថតដែលលោកបានឃើញនេះ តើវាអាចជួយរំឭកដល់ការចងចាំរបស់លោកបានទេ?

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ប្រហែលជាត្រូវរំឭកថា ហេតុអ្វីបានជាយើងមកទីនេះ ដើម្បីតតាំងលើបណ្តឹងសាទុក្ខប្រឆាំងទៅនឹងសំណុំរឿង០០២/១។ វាមានភស្តុតាងនៃឧក្រិដ្ឋកម្មសង្គ្រាម ដែលប្រព្រឹត្តដោយទាហាន លន់ នល់ គឺថាវាមិនពាក់ព័ន្ធទៅដល់មេធាវីការពារក្តីសម្រាប់សំណុំរឿង ០០២/០១ ឬ ០០២/០២ ទេគឺថាឧក្រិដ្ឋកម្មដែលប្រព្រឹត្តទៅដោយកងកម្លាំងដទៃទៀត គឺវាមិនពាក់ព័ន្ធ

ទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះទេ។ មេធាវីការពារក្តីមិនអាចប្រើប្រាស់ភស្តុតាងបែបនេះទេ។ ដូច្នេះ សំណួរ និងការបង្ហាញបែបនេះ គឺមិនពាក់ព័ន្ធទាល់តែសោះ។ ប្រហែលជាសាក្សីរូបនេះមិនមានភស្តុតាងអីពាក់ព័ន្ធទៅនឹងបញ្ហានេះទេ។

[១៣:៥៥:១៥]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមឆ្លើយតបសង្ខេបទេ។ ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ ទឡ្ហីករណ៍មួយដែលមេធាវីការពារក្តីលើកឡើងគោលនយោបាយឲ្យសម្លាប់ទាហានលន់ នល់ទេ ហើយក៏យើងបានបញ្ជាក់ផងដែរថាវា -- អ្វីដែលវាកើតឡើងនៅទួលពោធិ៍ជ្រៃ វាអាចកើតឡើងដោយសារតែអំពើសងសឹកប្រឆាំងទៅនឹងសកម្មភាពរបស់ទាហានលន់ នល់។ ជាការពិតហើយ ខ្ញុំយល់ស្របជាមួយសហព្រះរាជអាជ្ញា គឺមានការសងសឹករហូតដល់សម្លាប់ទាហានដែលមិនមានកាន់អាវុធ។ អ៊ីចឹងឯង បានជាខ្ញុំយល់ឃើញថា ការតាំងសំណួរបែបនេះជាការសមស្រប ហើយខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរ ថាតើសាក្សីបានដឹងអំពីសកម្មភាពបែបនេះដែរទេ ពាក់ព័ន្ធទៅនឹងការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ដោយសារតែអំពើរបស់ទាហានលន់ នល់ នេះ វាអាចនាំឲ្យមានការសងសឹកប្រឆាំងមកលើទាហានទាំងអស់នេះវិញ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់លោកមេធាវីបន្តិច។ អំមិញ គឺរូបភាពហ្នឹងប្រហែលជាមានដាក់មកហ្នឹង គឺជារូបភាពដែលសកម្មភាពហ្នឹង ប្រព្រឹត្តនៅក្នុងឆ្នាំណា? នៅពេលណា?

**លោក វ៉ិចទ័រ កូប៉េះ**

នៅក្នុងសង្គ្រាមស៊ីវិល គឺចន្លោះពីឆ្នាំ១៩៧០ ដល់៧៥។

[១៣:៥៦:៤៨]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ប្រហែលជារូបភាពនេះ អាចជារូបភាពមុនឆ្នាំ៧៥។ អ៊ីចឹង ការលើកឡើងរបស់លោកសហព្រះរាជអាជ្ញាជាការត្រឹមត្រូវ ដោយសារអង្គហេតុហ្នឹង វាអត់ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ហ្នឹងទេ។ ដូច្នេះ លោកអាចរកសំណួរអីណាផ្សេង ដើម្បីមកបញ្ជាក់សួរលើសាក្សីទៀតបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានៗ បានកត់សម្គាល់នេះ គឺត្រឹមត្រូវហើយ។ ហើយអំពើសម្លាប់នៅទួលពោធិ៍ជ្រៃ វាផ្នែកមួយនៃបណ្ដឹងសាទុក្ខនេះ។ វាមានអំពើសម្លាប់រង្គាលប្រព្រឹត្តឡើងដោយទាហានលន់ នល់ ដែរ។ ហើយធ្វើឲ្យ រស់ ញឹម គឺថាខឹងសម្បា មានការបញ្ជាសងសឹកឲ្យសម្លាប់ទាហានទាំងអស់នេះ។ អ៊ីចឹង ហើយបានខ្ញុំលើកឡើងមក សាកសួរ -- ខ្ញុំមិនមែនចង់សួរអំពើឧក្រិដ្ឋកម្មសង្គ្រាមសម្លាប់ដោយទាហាន លន់ នល់ទេ គ្រាន់តែសួរថា អំពើហ្នឹងវាមានទំនាក់ទំនងជាប់ទៅដល់ការសងសឹកដែលសម្លាប់ទៅដោយកងទ័ពនៅភូមិភាគនោះវិញដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកអាចឆ្លើយបាន សូមអញ្ជើញលោកឆ្លើយ!

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំសូមថាមិនឆ្លើយ ព្រោះខ្ញុំអត់ដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំអស់សំណួរហើយ។

[១៣:៥៨:៤១]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ ហើយជាបន្ត សូមអញ្ជើញលោកសហមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន។ បាទ សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អាកទួរ វែកគែន។ ខ្ញុំជាសហមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរបន្តិចបន្តួចទេ ដើម្បីសួរទៅលោក គឺមិនស៊ីពេលវេលាវែងទេ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ ជាបឋម ខ្ញុំសូមលោក សូមឲ្យលោកបំភ្លឺទាក់ទងទៅនឹងតួនាទីរបស់លោកជានីរសារ។ ពីព្រោះថានៅពេលដែលលោកត្រូវបានសួរដោយអ្នកស៊ើបអង្កេតនៃតុលាការយើងនេះ។ បើតាមខ្ញុំយល់

ឃើញ លោកដូចជានិយាយថា -- បើសិនខ្ញុំយល់ច្រឡំ លោកកែខ្ញុំ -- លោកដូចជាឆ្លើយថាតួនាទីរបស់លោកជានីរសារនោះ មិនមែនត្រឹមតែនាំសារទេ គឺលោកមានការងារខាងធ្វើជាកងការពារដែរ។ កាលយើងជានីរសារ គឺមានមុខងារពីរ។ ការពារផង នាំសារផង។

**លោក ទាត់ ធឿន៖**

**ឆ៖** ពេលដែលនាំសារ និងការពារផង ពេលនៅមន្ទីរលើ។ បាទ ដល់មកសមរភូមិ គឺៗ ខ្ញុំនាំសារដាច់ដោយឡែក ព្រោះខ្ញុំហាត់ជាងគេ ដើរ។ សម័យនោះវាមានកន្លែងខ្លះដើរ អត់មានអីជិះទេ បើមានអីជិះក៏ទៅមិនរួចនឹងថ្មដែរ។

[១៤:០០:២៩]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកមិនទទួលបន្ទុកខាងការពារ រស់ ញឹម នោះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ បើមកសមរភូមិមុខ ខ្ញុំអត់ទទួលខាងការពារទេ បើនៅមន្ទីរក្រោយ ខ្ញុំចូលរួមក្នុងការការពារ នៅមន្ទីរលេខ២០។

**ស៖** អ៊ីចឹងពេលដែលលោកនិយាយថា ទទួលបន្ទុកខាងការពារហ្នឹង មានន័យយ៉ាងម៉េចដែរការ -- តួនាទីជាអ្នកការពារហ្នឹង លោកសំដៅទៅលើអី?

**ឆ៖** បាទ ពេលយប់យើងយាម ចែកវេនគ្នាយាមការពារ។

**ស៖** បាទ ហើយលោកយាមហ្នឹងលោកយាមអីដែរ?

**ឆ៖** យាមការពារមេនេះឯង បាទ ការពារមន្ទីរ។

**ស៖** បាទ លោកយាមផ្ទះ យាមមូលដ្ឋានមួយ យាមបន្ទាយមួយ។ អ៊ីចឹងលោកអាចពន្យល់បានទេ លោកការពារអីឲ្យច្បាស់លាស់ កន្លែងដែល រស់ ញឹម ដេក ឬក៏ជាកន្លែងអីផ្សេងទៀត សូមលោកបញ្ជាក់ឲ្យបានច្បាស់មើល តើយាមហ្នឹងយាមអ្វីដែរ ការពារអ្នកណាដែរ?

**ឆ៖** បាទ យាម រស់ ញឹម គាត់សម្រាន្ត គាត់ដេក ផ្ទះរបស់គាត់នៅហ្នឹង។ ផ្ទះនៅជុំគ្នាហ្នឹងគឺមាន តាកឹ, ផ្ទះ រស់ ញឹម នៅម្ខាងអូរម្នាក់។ អ៊ីចឹងពួកខ្ញុំក្រុមនីរសារ គឺកងការពារ គេខ្វះគឺខ្ញុំបំពេញ គឺយាម ចែកវេនគ្នាយាម។ យាមកន្លែងផ្ទះរបស់គាត់។

**ស៖** អ៊ីចឹងបេសកកម្មហ្នឹង គឺលោកចាប់ផ្តើមបំពេញតាំងពីឆ្នាំ១៩៧០ សំដៅលើថា ការងាររបស់លោកជាអ្នកសន្តិសុខហ្នឹង គឺចាប់ផ្តើមតាំងពីឆ្នាំ៧០មកម្ល៉េះ ឬក៏យ៉ាងម៉េច?

[១៤:០៣:៣២]

**ឆៈ** បាទ តាំងពីពេលដែលខ្ញុំនៅជាមួយគាត់ជាប់លាប់ឆ្នាំ៧០ហ្នឹងមក គឺខ្ញុំនៅ រស់នៅជាមួយគាត់ ហើយយាមកន្លែងហ្នឹង ហើយពេលមានសារបានគាត់ប្រើខ្ញុំឱ្យនាំសារចុះមកមន្ទីរក្រោម មានមន្ទីរនីរសារក្រោមមួយទៀត។ យកមកមន្ទីរក្រោម ហើយមន្ទីរក្រោមមានស្នីផ្ញើបកគាត់វិញ គឺខ្ញុំយកទៅដល់គាត់វិញ។

**សៈ** បាទ យើងទើបនឹងឃើញថា ទើបតែនឹងឆ្នាំ១៩៧៥ ហើយទេដែលខេត្តបាត់ដំបង ហើយនិងពោធិ៍សាត់ហ្នឹងត្រូវបានដណ្តើមបាន។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា កាលពីឆ្នាំ១៩៧០ ហើយនិងឆ្នាំបន្តបន្ទាប់មកហ្នឹង តាញឹម ហ្នឹងគាត់មានមូលដ្ឋាននៅឯណា ឈរជើងនៅឯណា? លោកនិយាយថា លោកនៅយាមផ្ទះគាត់ ក៏ប៉ុន្តែឥឡូវខ្ញុំចង់សួរលោកថាតើកាលនោះច្បាស់លាស់តែម្តង គាត់នៅខេត្តណាដែរ ទីតាំងមូលដ្ឋានរបស់គាត់នោះ? ផ្ទះគាត់អីជាដើម គាត់នៅឯណាកាលនុ៎ង?

**ឆៈ** បាទ ខ្ញុំស្តាប់វាអត់ទាន់ច្បាស់។ សូមសួរម្តងទៀត ពីឆ្នាំណា ទៅឆ្នាំណា បាទ?

**សៈ** បាទ លោកអាចជម្រាបជូនដោយសង្ខេប អំពីការផ្លាស់ប្តូរកន្លែងរបស់គាត់ គឺថាចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ ហ្នឹង គាត់ផ្លាស់ប្តូរមន្ទីរគាត់ ពីណាទៅណាខ្លះ? លេខមន្ទីរសេនាធិការគាត់នោះដូរពីកន្លែងណា ទៅកន្លែងណាខ្លះ?

**ឆៈ** ពីឆ្នាំ៧០ ដល់ ៧៥ គឺមន្ទីររបស់គាត់ អត់មានផ្លាស់ប្តូរទេ មន្ទីរលេខ២០ហ្នឹង គឺនៅក្នុងព្រៃហ្នឹង។ ប្រពន្ធ-កូនគាត់នៅនុ៎ងរហូតដល់៧៥។ ហើយគាត់មកសមរភូមិ គាត់មកដេកតាមព្រៃទេ ឬក៏ផ្ទះអ្នកស្រុក ដេកអង្រឹងទេ។

[១៤:០៦:២៩]

**សៈ** បាទ ខ្ញុំៗគិតថាលោកនិយាយពីកាលព្រឹកមិញហើយ បើ -- ប៉ុន្តែខ្ញុំសួរឱ្យច្បាស់លាស់តែម្តង លោកនិយាយថា “នៅក្នុងព្រៃហ្នឹង” វាដូចជាមិនសូវច្បាស់លាស់ទេ។ អ៊ីចឹងសូមឱ្យលោកបញ្ជាក់ថា នៅភូមិភាគពាយ័ព្យ ក៏ប៉ុន្តែសួរថា ព្រៃហ្នឹងនៅកន្លែងណាបានច្បាស់លាស់តែម្តង?

**ឆៈ** បាទ ខ្ញុំបញ្ជាក់ព្រឹកមិញម្តងហើយ ខ្លាចតែលោកមេធាវីស្តាប់មិនបានមិនដឹង។ គឺនៅភ្នំធំ ជាប់ភ្នំក្រវាញ បាទ។

**សៈ** បាទ សូមអរគុណ។ បាទ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក នៅចម្លើយ១២៤ ជាពិសេសហ្នឹង។ លោកបានរៀបរាប់អំពីពេលជាច្រើនដង ដែលមានលោក -- ដែល រស់ ញឹម គាត់

រអ៊ូរទាំ អំពីមជ្ឈិម។ ខ្ញុំសូមដកស្រង់អំពីដែលលោកបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេត អ្នកតុលាការយើងនេះ។ នៅចម្លើយ១២៤ លោកឆ្លើយដូចតទៅនេះ លោកនិយាយអំពី រស់ ញឹម លោកនិយាយថា "ខ្ញុំបានឮគាត់និយាយពីត្អូញត្អែរអំពីមជ្ឈិម ដែលថាបានជម្លៀសប្រជាជនចេញពីទីក្រុង ហើយនិងបំបាត់ទីផ្សារ ហើយនិងបំបាត់ចាយលុយជាដើម។ គាត់និយាយថា គាត់មិនដែលគេ -- ឃើញគេធ្វើអ៊ីចឹងទេ នយោបាយអ៊ីចឹងទេលើពិភពលោកនោះ"។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកអាចបញ្ជាក់ជូនតុលាការបានដែរឬទេ ថាលោកពិតជាបានឆ្លើយអ៊ីចឹងមែនទៅចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០១៣នោះ?

**ឆ៖** បាទ ពិតជាបានឆ្លើយអ៊ីចឹងមែន។ ព្រោះកាលនុ៎ង ពេលខ្ញុំនៅជាមួយគាត់ បរឡានឲ្យគាត់ខ្លះ ពេលខ្លះ គឺគាត់ជួបមិត្តភក្តិគាត់ដែលជម្លៀសចេញ កាត់មករកជួបគាត់ សុទ្ធតែៗអាចារ្យដូចគ្នា។ អ៊ីចឹងគាត់រៀងមានការធុញថប់ក្នុងការជម្លៀសចេញពីផ្ទះសម្បែង បាទ។

[១៤:០៩:១៦]

**សៈ** បាទ ហើយអ៊ីចឹងគាត់និយាយអ្វីទៅ នៅពេលហ្នឹង ពេលគាត់ថ្នាំងថ្នាក់ចិត្តហ្នឹង?

**ឆ៖** គាត់និយាយថា "លើពិភពលោក ចប់សង្គ្រាមហើយ វាមានតែវិនាសកម្មហិនហោច នឹងត្រូវបិទទ្វារអង្គការ -- បិទទ្វារអន្តរជាតិ ជំនួយអន្តរជាតិទេ។ នេះបិទទ្វារជំនួយអន្តរជាតិហើយជម្លៀសប្រជាជនចេញពីផ្ទះសម្បែង ឲ្យទៅដេកនៅព្រៃ។ គឺធ្វើវាមិនសមហេតុសមផលទៅនឹងសង្គម" គាត់និយាយអ៊ីចឹងមែន។

**សៈ** បាទ ហើយតើលោកចាំបានដែរ អំពីវគ្គដែលលោកទើបតែនិយាយអម្បាញ់មិញនោះ។ លោកមានចាំទេថាគាត់និយាយពីរឿងថ្នាំងថ្នាក់គាត់ហ្នឹង និយាយពេលណាបើលោកធៀបទៅនឹងព្រឹត្តិការណ៍មួយដែលកើតឡើងកាលពីអតីតកាលហ្នឹង? តើ រស់ ញឹម គាត់និយាយថាគាត់អន់ចិត្តហ្នឹងនៅពេលណាដែរ?

**ឆ៖** មុនពេលមកសន្និបាត នៅមជ្ឈិមមុនពេលហ្នឹង ហើយកាលនិយាយហ្នឹងក៏មិនមែនតែគាត់ម្នាក់ឯងទេ មានតាគី មានតាប៉ែត មានតាគុំ មានតាម៉ែ។

**សៈ** បើអ៊ីចឹងគឺជាការពិភាក្សាគ្នានៅក្នុងឡាន ឬក៏លោកបាន -- បើតាម នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹងគឺថា គាត់និយាយត្អូញត្អែរ ឬក៏ថាអន់ចិត្តនេះញឹកញាប់ណាស់។ អ៊ីចឹងខ្ញុំសួរលោកថាគាត់និយាយនៅក្នុងឡាន ពេលគាត់ជិះឡាន ឬក៏គាត់និយាយនៅកន្លែងណាផ្សេង?

[១៤:១១:៤៣]

**ឆ៖** និយាយនៅក្នុងឡានក៏គាត់និយាយ ហើយពេលគាត់ជួបជុំគ្នាគាត់ ក៏គាត់និយាយបាទ ពេលដែលនៅផ្ទះ នៅពេលបរឡាន ពេលជិះឡានទៅក៏គាត់មាននិយាយដែរ។ និយាយរឿងមិនឲ្យលុយ មិនឲ្យចរាចរលុយ មិនឲ្យចាយលុយ ក៏គាត់និយាយ។ គាត់ថា “នៅលើពិភពលោកគ្មាននរណាធ្វើប្រទេសមិនចាយលុយទៅកើតទេ។ ម្នាក់ៗគេខិតខំលុយ បានលុយហើយបានជាមិនចាយវាខុសគេ។” គាត់និយាយថា “វាខុសគេ”។ បាទប៉ុណ្ណឹងបាទ។

**ស៖** បាទ ទាក់ទងនឹងការជម្លៀសមនុស្សចេញពីក្រុង ដូចដែលលោកបានលើកឡើងហ្នឹង យើងត្រូវតែយល់ថា រស់ ញឹម ហ្នឹង គាត់ជំទាស់នឹងការជម្លៀសប្រជាជនចេញពីទីក្រុមនានា។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គាត់មិនមានអារម្មណ៍ជំទាស់ក្នុងការជម្លៀសចេញបាទ។

**ស៖** តើលោកចាំដែរឬទេ ថានៅឆ្នាំ១៩៧៤ លោកបានជូន រស់ ញឹម ទៅចូលប្រជុំមួយដែលប្រព្រឹត្តក្នុងរយៈពេលពីរសប្ដាហ៍ហើយបានប្រព្រឹត្តនៅចម្ងាយប្រហែលជា ៣០០គីឡូម៉ែត្រ ឬក៏ជាង ៣០០គីឡូម៉ែត ពីមន្ទីរប-២០។ អ៊ីចឹងលោកមានចាំទេថាតើនៅឆ្នាំ១៩៧៤ហ្នឹង គឺលោកបានធ្វើដំណើររយៈពេលវែងទៅចូលរួមប្រជុំរយៈពេល ពីរសប្ដាហ៍នៅក្នុងភូមិមួយដែលនៅចម្ងាយប្រហែលជា៤០គីឡូម៉ែត្រ ផ្នែកខាងជើងនៃ ទីរួមខេត្តកំពង់ចាម។ លោកចាំថា តើលោកបានធ្វើអ៊ីចឹងទេ?

**ឆ៖** ឆ្នាំ៧៤ ដូចជាអត់មានទេ មានតែ៧៥ ទេបាទ។ ៧៥ ក្រោយពីសន្និបាតហើយហ្នឹងទេដែលទៅ។

[១៤:១៤:៤៣]

**ស៖** លោកគិតទៅឯណាវិញទៅអ៊ីចឹង?

**ឆ៖** ខ្ញុំអត់យល់សំណួរ។

**ស៖** បាទ សំណួរខ្ញុំនុ៎ងអំមិញដូចជាទូលាយបន្តិច ក៏ប៉ុន្តែអម្បាញ់មិញលោកហាក់ដូចជាយល់ឃើញថា កិច្ចប្រជុំហ្នឹងកើតប្រព្រឹត្តទៅនៅពេលផ្សេងទេ។ អ៊ីចឹង ខ្ញុំសួរលោកថា តើលោកមានចាំទេថាបានជូនដំណើរគាត់ទៅប្រជុំហ្នឹង ហើយលោកនិយាយថាទេ មិនមែនឆ្នាំ៧៤ ទេ តាមពិតឆ្នាំ៧៥។ អ៊ីចឹងលោកចង់និយាយថា ក្រោយពេលជ័យជម្នះខែមេសា ៧៥ ហើយឬក៏យ៉ាងណា?

**ឆ៖** មើល៍សុំនិយាយឡើងវិញ សំណួរឡើងវិញពីទៅប្រជុំនៅកន្លែងណា ហើយសុំបញ្ជាក់ឡើងវិញមើល៍ ខ្ញុំស្ដាប់អត់ទាន់ទេបាទ។

**សៈ** បាទ ខ្ញុំនិយាយឡើងវិញ។ តើភូមិមាយ ស្រុក -- ឃុំព្រៃកកុក នៅក្នុងឆ្នាំ១៩៧៤ ហ្នឹង លោកធ្លាប់ទៅទីនុំងជាមួយ រស់ ញឹម ដែរឬទេ? ភូមិព្រៃកកុក។

**ឆៈ** បាទ អត់ដែលទៅទេ។

**សៈ** លោកមិនដែលបានទៅ តើលោកមានចាំថា នៅក្នុងឆ្នាំ១៩៧៤ហ្នឹងគាត់មានវត្តមានពីរសប្តាហ៍ដើម្បីទៅចូលរួមប្រជុំដែលបានប្រព្រឹត្តទៅនៅចម្ងាយជាង ៣០០គីឡូម៉ែត្រពីមន្ទីរប-២០ ដែរឬទេ?

**ឆៈ** បាទ ខ្ញុំចាំមិនបានទេបាទ។

**សៈ** តើ រស់ ញឹម មានបាននិយាយប្រាប់លោកពីកិច្ចប្រជុំមួយដែលគាត់បានចូលរួមនៅឆ្នាំ ១៩៧៤ ហើយដែលនៅក្នុងកិច្ចប្រជុំនោះ គាត់បានយល់ស្របនឹងការជម្លៀសប្រជាជនចេញពីទីក្រុងនានា?

**ឆៈ** បាទ គាត់មិនដែលនិយាយប្រាប់ខ្ញុំទេ ព្រោះភារកិច្ចខ្ញុំខាងអ្នករត់សារ គឺដឹងតែរត់សារប៉ុណ្ណឹងទេបាទ។

[១៤:១៧:៥៦]

**សៈ** បាទ សូមអរគុណ។ បើតាមការចងចាំរបស់លោក ការដណ្តើមយកខេត្តបាត់ដំបង ពោធិ៍សាត់ ដែលបង្កើតបានជាភូមិភាគពាយ័ព្យហ្នឹង គឺជាការប្រយុទ្ធដ៏ស្វិតស្វាញបំផុត។ អ៊ីចឹង លោកមាននៅចាំទេថា ដណ្តើមបាននៅពេលណាដែរ ហើយពិបាកកម្រិតណាដែរ ចំពោះកងទ័ពបដិវត្តន៍ហ្នឹង ដើម្បីឲ្យបានភូមិភាគពាយ័ព្យទាំងស្រុងតែម្តងនោះ។ លោកអាចរៀបរាប់បានដែរឬទេអំពីការវាយដណ្តើមយកភូមិភាគពាយ័ព្យនេះ?

**ឆៈ** បាទ វាលំបាកដែរការប្រយុទ្ធដណ្តើមយក ប្រយុទ្ធផ្តាច់ព្រ័ត្រហ្នឹងគឺថា មេៗចុះផ្ទាល់ទាំងអស់ ចុះជាប់នៅតាមទិសទាំងអស់ ទាំងតាកី ទាំងតាញឹម ទាំងតាប៉ែត ប៉ុន្តែតាប៉ែត គាត់ទទួលខាងស្បៀង – សេដ្ឋកិច្ច។ អ៊ីចឹងគឺថា តាកី ក៏នៅសមរភូមិ, តាញឹម ក៏នៅសមរភូមិ, ហើយខ្ញុំរត់សារពីកន្លែងតាញឹម មកមន្ទីរលេខ២០ បាទ។ ហ្នឹងថាពិបាកហើយ មានយន្តហោះទម្លាក់គ្រាប់បែកផង បាញ់គ្នាផង កាំភ្លើងធំផ្គោងដាក់ផង មានការតឹងតែង។

**សៈ** បាទ លោកនិយាយថាស្ថានភាពតឹងតែងនោះ លោកអាចនិយាយឲ្យបានលម្អិតបានទេ ព្រោះថា លោកនៅសមរភូមិដែរ លោកជាសាក្សីផ្ទាល់ពីការប្រយុទ្ធគ្នាហ្នឹង។ អ៊ីចឹងនៅពេលដែលលោក

និយាយថា ស្ថានភាពហ្នឹងតឹងតែងហ្នឹង តានតឹងហ្នឹង លោកចង់និយាយថាម៉េចនៅពេលលោកនាំសារ នៅសមរភូមិហ្នឹង គឺលោកចូលរួមប្រយុទ្ធនឹងគេដែរ លោកឮស្នូរកាំភ្លើងគេបាញ់ លោក ពេលដែលយោធាទៅណាហ្នឹង លោកត្រូវធ្វើដំណើរតាមគេដែរ ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺឮស្នូរបាញ់វាច្រើនដែរ ប្រយុទ្ធគ្នា ឮស្នូរបាញ់ ហើយការទៅតាមគេហ្នឹង គឺខ្ញុំទៅតាមទីបញ្ជាការមុខ ជាអ្នកនាំសារ។ ទីបញ្ជាការទៅដល់ណា ខ្ញុំទៅដល់ហ្នឹងដែរបាទ ដើម្បីយកសារមកទីបញ្ជាការក្រោយ រាយការណ៍មកឲ្យមជ្ឈិម។

[១៤:២១:១៣]

**ស៖** នៅពេលដែលគេឈប់ប្រយុទ្ធគ្នានោះ លោកនៅឯណាដែរ? គឺលោកនៅខេត្តពោធិ៍សាត់ និងបាត់ដំបងហើយ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាឈរជើងនៅឯណាដែរ ច្បាស់លាស់តែម្តង?

**ឆ៖** ពេលឈប់ប្រយុទ្ធគ្នាបានបីថ្ងៃ ខ្ញុំបកពីមន្ទីរលើមកដល់វិញ គឺខ្ញុំនៅកំពង់ព្រះ ខាងត្បូងទីរួមខេត្តបាត់ដំបង ឃុំកំពង់ព្រះ។ ទីបញ្ជាការដាក់ត្រង់នុំង។ តាញឹម គាត់នៅត្រង់ហ្នឹង។

**ស៖** បាទ លោកនិយាយថាបីថ្ងៃក្រោយមក តែខ្ញុំសួរលោកអម្បាញ់មិញនេះ ខ្ញុំសួរសំដៅលើថ្ងៃដែលទាហានលន់នល់ចុះចាញ់ ដាក់អាវុធនោះ លោកនៅឯណាដែរ? ឈរជើងនៅឯណានៅពេលនោះ? មិនមែនបីថ្ងៃក្រោយពេលដែល លន់ នល់ ដាក់អាវុធហើយទេ។

**ឆ៖** បាទ ខ្ញុំនៅជាអ្នករត់សារដដែល។ ខ្ញុំគ្រាន់តែ -- ថ្ងៃហ្នឹងគឺខ្ញុំយកសារឡើងមកមន្ទីរលើ។ ថ្ងៃដែលចប់ហ្នឹងបាទ យកសារយកមករាយការណ៍ មកឲ្យខាងទូរលេខគេបញ្ជូនមកមជ្ឈិម នៅកំពង់ព្រះ។

**ស៖** បាទ ខ្ញុំសូមអរគុណ ហើយអ៊ីចឹងទីបញ្ជាហ្នឹងស្ថិតនៅឯណាដែរ?

**ឆ៖** បាទ នៅកំពង់ព្រះហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ លោកសាក្សី អម្បាញ់មិញនេះ លោកបាននិយាយអំពីការកោះហៅអតីតទាហាន លន់ នល់ ដើម្បីទៅជួបសម្តេច សីហនុ។ អង្កាល់នោះ កាលដែលគេអំពាវនាវនោះ លោកនៅខេត្តពោធិ៍សាត់ ខ្ញុំយល់អត់សូវច្បាស់ដែរអម្បាញ់មិញនោះ។ កាលនោះ លោកនៅពោធិ៍សាត់ ហើយលោកឮគេអំពាវនាវ គេហៅអតីតទាហានលន់នល់ ទៅប្រជុំនោះ លោកនៅពោធិ៍សាត់ ឬក៏លោកដឹងរឿងហ្នឹងក្រោយមកហើយទេ?

[១៤:២៤:១៣]

**ឆ៖** បាទ ខ្ញុំនៅកំពង់ព្រះហ្នឹងពេលដែលខ្ញុំ -- ព្រោះពេលហ្នឹង គឺគ្នាខ្ញុំបីនាក់ផ្លាស់វេនគ្នារត់សារ ដើម្បីរាយការណ៍បន្ទាន់ៗមកមជ្ឈិម។ បាទ សំបុត្រគាត់មួយថ្ងៃ ជូនកាលសំបុត្រពីរ អ៊ីចឹងដូរគ្នា។អ៊ីចឹង វារិលជុំ អត់សូវបានសម្រាកទេ ខ្ញុំទាំងបីនាក់ហ្នឹង។ ទៅម៉ៃម្យប់ មកម៉ៃម្យប់ តាមផ្លូវវាមានចម្ងាយ អ៊ីចឹងដែរ។ ហើយការប្រកាសនោះ គឺប្រកាសតាមវ៉ាដ្យូ។

**សៈ** បាទ សូមអរគុណ។ កន្លែងដែលលោកនៅនោះ មានចម្ងាយប៉ុន្មានពីទីរួមខេត្តពោធិ៍សាត់ដែរ?

**ឆ៖** បាទ ប្រហែលជាជិត ១០០គីឡូ ពីពោធិ៍សាត់។

**សៈ** ហើយនៅក្នុងរយៈកាលហ្នឹង តាមអ្វីដែលលោកបានរៀបរាប់ហ្នឹង លោកនិយាយថា អតីតទាហានលន់ នល់ ត្រូវបានគេអំពាវនាវ ហើយឡើងឡាន ហ្សេ.អឹម.សេ។ អ៊ីចឹង ខ្ញុំចង់សួរលោកថា នៅពេលហ្នឹង រស់ ញឹម នៅឯណាដែរ នៅពេលដែលអតីតទាហានលន់ នល់ ហ្នឹងឡើងឡានកាមីញ៉ុង ហ្សេ.អឹម.សេ ហ្នឹង?

**ឆ៖** បាទ នៅកំពង់ព្រះហ្នឹង។

[១៤:២៦:២១]

**សៈ** ក្រោយថ្ងៃជ័យជម្នះ ថ្ងៃទី១៧ មេសា ហ្នឹង តើយោធានៅក្នុងភូមិភាគរបស់លោកហ្នឹងកាន់កាប់ទឹកដីកន្លែងណាខ្លះ? ហើយឈរជើងនៅកន្លែងណា? គេចាត់តាំងឲ្យតែបំពេញភារកិច្ចរបស់ខ្លួនជាយោធាទេ ឬក៏ត្រូវបំពេញភារកិច្ចផ្សេងទៀត?

**ឆ៖** ខ្ញុំមិនដឹងដែរ ព្រោះខ្ញុំដឹងតែខាងរត់សារទេ បាទ។

**សៈ** អ៊ីចឹងនៅក្នុងអង្គភាពរបស់លោកនោះ តើលោកធ្លាប់ឮ និយាយ ឬក៏គេមានបានធ្លាប់ប្រើ ឬក៏ឲ្យគេកំណត់អត្តសញ្ញាណអតីតកងទ័ព ឬក៏យោធានៃសាធារណរដ្ឋខ្មែរដែរឬទេ ដើម្បីយកទៅសម្លាប់ចោលនៅពេលក្រោយ យកទៅកម្ទេច?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ បាទ។

**សៈ** បាទ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនៅក្នុងចម្លើយទី១៧៦ កាលនោះគេបង្ហាញតួលេខមួយជូនលោក -- ៦៧។ ខ្ញុំជម្រាបលោកថា នៅខែមេសា ឆ្នាំ១៩៧៥នោះ យើងត្រូវ --

**អ្នកបកប្រែ៖**

លោកប្រធាន លោកមេធាវី គាត់និយាយលឿនពេក អ្នកបកប្រែតាមអត់ទាន់ សូមឲ្យគាត់

អានម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កុំនិយាយលឿនពេក។ និយាយមួយៗ ព្រោះអ្នកបកប្រែបកអត់ទាន់។

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** បាទ លោកប្រធាន ខ្ញុំនឹងអានមួយសាទៀត។ បាទ សូមទោស។ នៅចម្លើយ១៧៧ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ក្រោយខែមេសា ឆ្នាំ១៩៧៥ កងពល១០០៧ ត្រូវបានចាត់តាំងឲ្យជួសជុលផ្លូវរថភ្លើង ហើយនិងកងពល១០០៦ ត្រូវឲ្យជួលជុលផ្លូវជាតិលេខ៥”។ សូមបញ្ចប់ការដកស្រង់។ តើលោកនៅតែរក្សាចម្លើយលោកនេះដែរឬទេ?

**លោក ទាត់ ធឿន៖**

**ធ៖** បាទ ខ្ញុំនៅតែរក្សា។

[១៤:២៩:២១]

**ស៖** នៅពេលដែលយើងអានកំណត់ហេតុស្តាប់ចម្លើយរបស់លោកដ៏វែងនេះ ដែលធ្វើឡើងនៅឆ្នាំ២០១៣។ យើងយល់ឃើញថា លោកក្លាយជាអនុសេនាធិការដ្ឋាននៃកងទ័ពភូមិភាគហ្នឹង នៅចុងឆ្នាំ១៩៧៥។ លោកនិយាយថា លោកធ្វើតែរយៈពេលជាងមួយខែទេ។ នេះបើសិនជាខ្ញុំបូកសរុបគ្នារវាងចម្លើយ១៦៥ និង១៩៤ របស់លោក។ អ៊ីចឹង លោកអាចបញ្ជាក់បានដែរឬទេ ថានៅឆ្នាំ -- នៅចុងឆ្នាំ១៩៧៥ហ្នឹង លោកបានក្លាយជានាយរងសេនាធិការនៅក្នុងភូមិភាគហ្នឹង ហើយលោកទទួលបន្ទុកខាងសេដ្ឋកិច្ច។ អ៊ីចឹងមែនទេលោក?

**ធ៖** បាទ ក្រោយពីទៅពីសន្និបាតវិញហើយហ្នឹង គឺខ្ញុំបានទទួលភារកិច្ចថ្មីហ្នឹង នៅកន្លែងហ្នឹងគេហៅថាកន្លែងសេដ្ឋកិច្ច តែសេដ្ឋកិច្ច គឺខ្ញុំទទួលបន្ទុកតែខាងរៀបចំអាវុធឃ្លាំង ឃ្លាំងអាវុធ ទុកដាក់អាវុធ បាទ។

**ស៖** ខ្ញុំពេលខ្លះ ខ្ញុំឆ្ងល់ដែរដែរ មិនដឹងថា គេបកប្រែយ៉ាងម៉េច បានជាលោកឆ្លើយយ៉ាងអ៊ីចឹង។ ខ្ញុំសួរម្តងទៀត តើនៅចុងឆ្នាំ១៩៧៥នេះហើយ ដែលបានលោកក្លាយជានាយរងសេនាធិការទទួលបន្ទុកខាងសេដ្ឋកិច្ចនៃកងទ័ពភូមិភាគហ្នឹង។ នៅចុងឆ្នាំ១៩៧៥ ឬក៏យ៉ាងណា?

**ធ៖** បាទ នៅក្នុងៗចុងឆ្នាំ១៩៧៥។

[១៤:៣១:៤២]

**ស៖** តើពេលនុ៎ងហ្នឹង គឺលោកជិតចេញទៅប្រទេសចិនហើយ ឬក៏យ៉ាងណា?

**ឆ៖** នៅក្រោយពេលដាក់រៀបចំអាវុធ -- អាវុធគ្រាប់អីអស់ហើយ បានគាត់ឲ្យទៅចិន បាទ។

**ស៖** នៅពេលដែលលោកទទួលបន្ទុកក្នុងការដាក់អាវុធចូលឃ្លាំងហ្នឹង លោកជានាយរងសេនាធិការភូមិភាគហ្នឹងហើយ ឬក៏យ៉ាងណា?

**ឆ៖** បាទ នាយរងហើយ។ នាយរងទៅទទួលបន្ទុកទុកដាក់អាវុធហ្នឹង បាទ។

**ស៖** អ៊ីចឹងនៅចុងឆ្នាំ១៩៧៥ កងទ័ពភូមិភាគពាយ័ព្យហ្នឹងស្ថិតនៅក្រោមទំនួលខុសត្រូវ ឬចំណុះឲ្យភូមិភាគនៅឡើយទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ចំណុះឲ្យភូមិភាគនៅឡើយ។

**ស៖** បាទ យើងទាំងអស់គ្នាដឹងហើយថា កងទ័ពខ្មែរក្រហម ត្រូវបាន -- អ៊ីចឹងបើតាមការបង្កើតកងទ័ពខ្មែរក្រហមនេះ នៅក្នុងភូមិភាគ--

**អ្នកបកប្រែ៖**

លោកប្រធាន ពីសំណាក់អ្នកបកប្រែសូមឲ្យលោកមេធាវីនិយាយមួយសាទៀត ពីព្រោះអីមានពាក្យ អត់ទេ មានពាក្យកាត់មួយដែលអ្នកបកប្រែចាប់អត់បាន។

**ប្រធានអង្គជំនុំ៖**

សូមលោកនិយាយម្តងទៀត ព្រោះខាងអ្នកបកប្រែចាប់អត់ទាន់ទេ បាទ។

[១៤:៣៤:២៣]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោកសាក្សី យើងដឹងហើយថា កងទ័ពបដិវត្តន៍ខ្មែរក្រហមហ្នឹងត្រូវបានបង្កើតឡើងនៅឆ្នាំ -- ខែមករា ឆ្នាំ១៩៧៥។ ហើយលោកទើបតែនិយាយថា នៅចុងឆ្នាំ១៩៧៥ លោកត្រូវបានគេតែងតាំងឲ្យកាន់តំណែងមួយនៅក្នុងកងទ័ពភូមិភាគពាយ័ព្យ។ ហើយលោកនិយាយថា កងទ័ពកាលនោះនៅចំណុះឲ្យភូមិភាគនៅឡើយទេ អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីក៏មានការលំបាកក្នុងការផ្ទេរអំណាចឬកងទ័ពភូមិភាគហ្នឹងមកឲ្យមជ្ឈិម? ហេតុអ្វីក៏ស៊ីពេល ឬក៏ចំណាយពេលយូរដល់ម្លឹងទម្រាំតែផ្ទេរមកឲ្យស្ថិតនៅក្រោមមជ្ឈិមវិញនេះ កងទ័ពភូមិភាគហ្នឹង?

**លោក ទាត់ ធឿន៖**

**ធ៖** បាទ អត់មានផ្ទេរផង គេដកតែម្តង។ មជ្ឈិមអ្នកដក ក្រោយពីធ្វើផ្លូវដែកចប់ ក្រោយពីធ្វើផ្លូវជាតិលេខ៥ ចប់ទៅធ្វើស្រែ ក្រោយមកគឺគេហៅមេៗមករៀន តាមខ្ញុំដឹងគេហៅមករៀន។ រៀនទៅបាត់ខ្លួនទៅ មករៀនទៅបាត់ខ្លួនទៅបាទ។

**ស៖** អ៊ីចឹងការដកអំណាចពីៗភូមិភាគហ្នឹងនៅពេលណាដែរ នៅចុងឆ្នាំ១៩៧៥ ឬយ៉ាងណាអំណាចកងទ័ព?

**ធ៖** បាទ គឺមិនមែនចុង៧៥ ទេ ហើយក៏មិនច្បាស់នៅពេលណាដែរ ព្រោះពេលខ្ញុំមកពីរៀនវិញឃើញថាកងទ័ពហ្នឹងចូលទើបគេដាក់ទៅមន្ទីរលត់ដំនៅកកោះអស់ហើយ នៅលលកសអស់ហើយបាទ។ ខ្ញុំក៏មិនដឹងច្បាស់ដែរបាទ ដែលដាក់ គេដកពេលណា ដាក់ពេលណាដែរបាទ។

[១៤:៣៧:១០]

**ស៖** បើទាក់ទងទៅនឹងអាវុធ ខ្ញុំសូមឲ្យលោកជួយធ្វើការបំភ្លឺមួយទាក់ទងនឹងអាវុធចំនួន ២០០០០ ដើម។ តាមលោកឆ្លើយកាលព្រឹកមិញហ្នឹងខ្ញុំដូចជាយល់ថា ការងារលោកហ្នឹងមិនមែនដើរប្រមូលអាវុធទាំងអស់នោះពីយោធាទេ គឺលោកទទួលបន្ទុកក្នុងការយកអាវុធហ្នឹងនៅក្នុងចម្ការមួយដែលដាក់មិនល្អរាត់រាយ ហើយអ៊ីចឹងលោកប្រមូលផ្តុំមកសម្អាត ហើយយកមកដាក់ក្នុងឃ្លាំងមួយនៅក្នុងព្រៃឫស្សី។ តើលោកចង់និយាយអ៊ីចឹងឬយ៉ាងម៉េច? ខ្ញុំសង្ខេបអម្បាញ់មិញនេះ ត្រឹមត្រូវដែរឬទេ?

**ធ៖** បាទ ត្រឹមត្រូវ។

**ស៖** តើនៅក្នុងឃ្លាំងហ្នឹង មានតែអាវុធទេ ឬក៏លោកមានដាក់ថ្នាំ ស្បៀងជាថ្នាំ ឬក៏ជាចំណីអាហារ ជាសម្លៀកបំពាក់អ្វីដែរ?

**ធ៖** បាទ អត់មានស្បៀងទេ មានតែអាវុធមួយមុខ។

**ស៖** តើមនុស្សចាស់ទាំងបីនាក់ហ្នឹង តាចាស់ៗដែលលោកបានយកឲ្យគាត់មកជួយធ្វើរោងអីហ្នឹងជាមនុស្សដែលលោកស្គាល់ពីមុនមក ហើយលោកទុកចិត្តលើគាត់ទាំងបីនាក់ហ្នឹង ឬយ៉ាងម៉េច?

**ធ៖** បាទ គាត់ជាមនុស្សធ្លាប់ដឹកជញ្ជូនគ្រាប់កាលពីធ្វើសង្គ្រាម ដឹកជញ្ជូនខ្សែគ្រាប់ និងខ្សែស្បៀងសម័យសង្គ្រាម។ គាត់ជាប្រធាន បាទ។

**ស៖** គាត់ជាមេអ្វីដែរទៅ?

[១៤:៣៩:៤៨]

**ផ៖** មេកងដឹកជញ្ជូនបាទ ដឹកជញ្ជូនគ្រាប់ផ្ដល់ទៅសមរភូមិមុខ។ ដឹកជញ្ជូនស្បៀងផ្ដល់ទៅសមរភូមិមុខ។ មេកង គេហៅថា មេកង១។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនោះ លោកបាននិយាយថាលោកត្រូវបានគេបញ្ជូនទៅប្រទេសចិន ដើម្បីរៀនបើកបរយន្តហោះទម្លាក់គ្រាប់បែក ដេ២៨។ អ៊ីចឹងខ្ញុំចង់សួរលោកថា ម៉ាកយន្តហោះហ្នឹង យន្តហោះយ៉ាងម៉េចទៅ?

**ផ៖** យន្តហោះកង្ហារបាទ កង្ហារដូចរបស់ លន់ នល់ ប្រើដែរ ស្លាបដាក់នឹងយន្តហោះកង្ហារ។ កង្ហារមួយពីមុខម៉ាស៊ីន នៅពីមុខតែកុង។

**ស៖** លោកចង់និយាយថាយន្តហោះហ្នឹងមិនមែនយន្តហោះប្រើកង្ហារទេ ឬយ៉ាងម៉េច?

**ផ៖** យន្តហោះហ្នឹងប្រើកង្ហារបាទ។

**ស៖** តើមុននឹងត្រូវបានគេបញ្ជូនទៅរៀនបើកបរយន្តហោះហ្នឹង លោកមានធ្លាប់ទទួលការបណ្ដុះបណ្ដាលផ្នែកហ្នឹងទេពីមុនមក?

**ផ៖** បាទ អត់ដែលផង។

**ស៖** អ៊ីចឹងជាលទ្ធផលចុងក្រោយហ្នឹងលោកក៏អាចរៀនបើកបរយន្តហោះហ្នឹងបានឬក៏យ៉ាងម៉េច?

**ផ៖** បាទ ខ្ញុំរៀនបានតែត្រឹមទ្រឹស្ដី មិនទាន់បានបើកឡើងសាកល្បង។

**ស៖** អ៊ីចឹង ពេលដែលលោកទៅរៀនហ្នឹង រៀនអ្វីដែរ ហើយនៅលើយន្តហោះហ្នឹង លោកត្រូវធ្វើអីនៅក្នុងយន្តហោះហ្នឹង?

**ផ៖** ខ្ញុំរៀននៅក្នុងថ្នាក់នៅឡើយ រៀនជាទ្រឹស្ដី រៀនពីការហោះហើរ។

[១៤:៤៣:៣៣]

**ស៖** បាទ លោកសុំឆ្លើយម្ដងទៀត ព្រោះកាលដែលលោកឆ្លើយអម្បាញ់មិញនេះ អ្នកបកប្រែស្ដាប់ចម្លើយលោកអត់ឮទេអម្បាញ់មិញ។

**ផ៖** បាទ ខ្ញុំរៀន --

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកមេធាវី តើសុំលោកជម្រាបផងថា តើមានភាពពាក់ព័ន្ធអីចំពោះការតាំងសំណួរនេះ?

**លោក អាកទួរ វែកកែន៖**

បាទ ខ្ញុំចង់ដឹងថា ហេតុអីបានជាគាត់ត្រូវបានគេបញ្ជូនទៅចិន ហើយបន្ទាប់មកខ្ញុំនឹងសួរគាត់ទាក់ទងទៅនឹងក្រោយពេលដែលគាត់ត្រឡប់មកវិញ ហើយនិងសួរពីរឿងដែល រស់ ញឹម មិនសប្បាយចិត្តដោយសារគាត់មិនព្រមត្រឡប់ទៅប្រទេសចិនរៀនបន្តទៀតហ្នឹង។ ពីព្រោះថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់នោះ គាត់ថាគាត់ទៅរៀនបើកយន្តហោះទម្លាក់គ្រាប់បែក។ អ៊ីចឹងហើយឥឡូវនេះ ខ្ញុំសួរគាត់អម្បាញ់មិញនេះ គាត់ឆ្លើយថាគាត់មិនទាន់នឹងបានបើកបរយន្តហោះអីផង។ អ៊ីចឹង សួរថាគោលបំណងហ្នឹងដើម្បីអ្វី?

**សួរដោយលោក អាកទួរ វែកកែន៖**

**ស៖** អ៊ីចឹង លោកសាក្សី ខ្ញុំសួរលោកថាទៅរៀនបើកយន្តហោះហ្នឹង ដេ២៨ នេះ គោលបំណងនៃការរៀនហ្នឹង រៀនដើម្បីអ្វី ហើយកម្មវត្ថុសំខាន់ពេលរៀនហ្នឹងមានអ្វីខ្លះ?

[១៤:៤៥:០១]

**លោក ទាត់ ធឿន៖**

**ឆ៖** គោលបំណងការរៀនគឺខ្ញុំមិនយល់ដែរ ព្រោះបញ្ជូនខ្ញុំទៅ ដឹងតែរៀនបាទ ហើយគោលបំណងដែលចេះធ្វើអីទៀត គឺខ្ញុំអត់ដឹងដែរ។ ខ្ញុំទៅតាមការចាត់តាំងរបស់អង្គការ។ កាលនោះគេហៅអង្គការ។

**ស៖** អ៊ីចឹងហេតុអីបាន រស់ ញឹម មិនសប្បាយចិត្តនៅពេលដែលលោកត្រឡប់មកប្រទេសខ្មែរវិញ ដើម្បីសម្រាក ហើយក្រោយមកលោកជំទាស់ លោកបដិសេធមិនព្រមទៅបន្តរៀននៅចិនវិញហើយ រស់ ញឹម ពេលនោះគាត់មិនសប្បាយចិត្តទេ។ អ៊ីចឹងខ្ញុំសួរលោកថា តើ រស់ ញឹម មានបានប្រាប់លោកទេថា ហេតុអីបានគាត់មិនសប្បាយចិត្តពេលដែលលោកមិនត្រឡប់ទៅប្រទេសចិនបន្តរៀនបន្តទៀតនោះ?

**ឆ៖** គាត់អត់មានប្រាប់អីទេ គាត់ថាឲ្យទៅរៀនបន្តទៀតឲ្យចេះមកវិញ ហើយក្នុងភាសាមួយដែលខ្ញុំមិនភ្លេចបាន ប៉ុន្តែវាមិនដឹងពេលណា ប្រហែលជាក្រោយពេលដែលគាត់បានជួបខ្ញុំ ហើយបាយជុំគ្នា។ គាត់ថា “យើងត្រូវតែចេះបញ្ជាយន្តហោះនេះ ដើម្បីវាយយកទឹកដីមកវិញ ទឹកដីកម្ពុជាក្រោម ទឹកដីសុរិន្ទ នគររាជ” ពេលដែលបាយជុំខ្ញុំហ្នឹង ពន្យល់ខ្ញុំអ៊ីចឹង។ ហើយដល់បាយហើយ ខ្ញុំថា ខ្ញុំមិនទៅទេព្រោះយុទ្ធមិត្តបាត់អស់ហើយ ខ្ញុំមិនទៅងាប់ចោលឆ្អឹងស្រុកគេទេ។ ខ្ញុំគ្មានទឹកចិត្តនឹងរៀនតទៀតទេ

ទោះបីសម្លាប់ខ្ញុំ ក៏ខ្ញុំមិនទៅដែរ។ បាទ មានតែប៉ុណ្ណឹង។

**ស៖** ពីព្រោះថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង គឺត្រូវបានទទួលរងទណ្ឌកម្ម ហើយគេបញ្ជូនឲ្យទៅធ្វើជីលាមកជាដើម ប៉ុន្តែការងារហ្នឹងជាការងារមិនស្រួលនោះទេ។ អ៊ីចឹងដោយ-សារតែលោកជំទាស់មិនព្រមត្រឡប់ទៅប្រទេសចិន ដើម្បីបន្តរៀនទៀតហ្នឹង លោកត្រូវបានទទួលទណ្ឌកម្មឲ្យទៅធ្វើជីលាមក។ អ៊ីចឹងមែនទេ?

[១៤:៤៧:៥៣]

**ឆ៖** បាទ ពេលហ្នឹងគាត់ថា បើមិនទៅទេ ទៅធ្វើជីអាចម៍ទៅ ជីលេខ១។ ខ្ញុំថាធ្វើជីក៏ធ្វើដែរ។ រឿងទៅវិញ ខ្ញុំអត់ទៅ។ អ៊ីចឹងឲ្យខ្ញុំទៅធ្វើជីអាចម៍ទៅ។

**ស៖** ហើយពេលក្រោយហ្នឹងបន្តិច លោកសម្រេចចិត្តបង្កើតកងតស៊ូមួយ។ តើ រស់ ញឹម អង្គាល់ហ្នឹងមានគាំទ្រលោកទេ ដើម្បីបង្កើតកងតស៊ូមួយហ្នឹង?

**ឆ៖** បាទ គាត់មិនដឹងថាខ្ញុំអ្នកបង្កើតទេ ឬក៏គាត់ដឹងក៏មិនដឹង ព្រោះខ្ញុំលួចបង្កើត ដោយសារខ្ញុំរស់នៅមិនបានក្នុងរបបអង្គការហ្នឹងបាទ ព្រោះមិត្តភក្តិជាច្រើន គេចាប់ទៅអស់ហើយ ខ្ញុំគិតថាគ្មានអ្នកណាមួយរស់បាន ដោយឡែកតែឯងបានទេ ច្បាស់ជាមានចម្លើយពាក់ព័ន្ធដល់ខ្ញុំ។ ហើយខ្ញុំរង់ចាំតែថ្ងៃស្លាប់ ដល់គេមកចាប់ខ្ញុំពីរដងអ៊ីចឹងទៅមិនបាន ខ្ញុំសម្រេចចិត្តថា ខ្ញុំវាយទៅ ហើយពេលនោះ ខ្ញុំក៏បានប្រាប់គាត់ថា ខ្ញុំទៅហើយ ខ្ញុំអត់នៅជាមួយទៀតទេ ហើយបើចង់បាញ់ខ្ញុំ បាញ់ឲ្យហើយទៅ តែបើបាញ់ខ្ញុំឲ្យងាប់ បើបាញ់មិនងាប់ទេ ខ្ញុំបាញ់វិញ។ ហើយតែខ្ញុំទៅហើយ គឺខឹងឯងមិនយូរទេ គេចាប់ហើយ ខ្ញុំប្រាប់គាត់អ៊ីចឹង។ គាត់ដឹងថាខ្ញុំទៅ។

[១៤:៤៩:៥៤]

**ស៖** បាទ លោកសាក្សី នៅក្នុងចម្លើយលេខ៤១ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក កាលពីឆ្នាំ២០១៣ហ្នឹង លោកនិយាយថា៖ កាលដែល រស់ ញឹម មកនិយាយជាមួយលោកនោះ។ កាលនោះលោកនៅក្នុងព្រៃរួចទៅហើយ លោកចូលព្រៃរួចទៅហើយ។ លោកនិយាយដូចតទៅនេះអំពីក្បត់នោះ។ លោកនិយាយថា "ពួក រស់ ញឹម នោះ គាំទ្រចលនាតស៊ូរបស់ពួកខ្ញុំ"។ អ៊ីចឹង ខ្ញុំមើលទៅឃើញថា រស់ ញឹម ហ្នឹងដឹងតាំងពីទីតាំងនៃចលនាហ្នឹងទៀតផង ព្រោះគាត់ចូលទៅលេងលោកដល់ទៅពីរដងឯណោះ ហើយគាំទ្រលោក។ ហើយលើសពីហ្នឹងទៅទៀត កាលពីព្រឹកនោះ លោកបានឆ្លើយថា កងទ័ពរបស់លោកនោះ មានកាំភ្លើងដែលលោកបានលាក់នៅក្នុង -- ដែលលោកបានបង្កើតដោយសម្ងាត់ជាមួយនឹង

រស់ ញឹម។ អ៊ីចឹង ខ្ញុំចង់សួរលោក ថាតើលោកយល់យ៉ាងណាដែរ ពេលលោកនិយាយថា រស់ ញឹម មិនដឹងទេ ហើយនៅក្នុងចម្លើយកំណត់ហេតស្តាប់ចម្លើយលោក ឃើញថា រស់ ញឹម គាំទ្រលោកទៅ លេងលោកដល់ទៅពីរដង?

[១៤:៥១:១៦]

**ឆ៖** បាទ ចំណុចនេះវាមិនមែនអ៊ីចឹងទេ គឺក្រោយពេលដែលគាត់ដឹងថា គេក៏ទៅចាប់គាត់ដែរ។ គេអស់ -- ទាហានជុំវិញគាត់ កងការពារអីអស់ហើយ។ បានគាត់ទៅរកខ្ញុំឯណោះ ហើយទៅរកឯណោះ គឺមិនទៅដល់តំបន់ខ្ញុំកាន់កាប់ទេ ទៅតែព្រំប្រទល់ម្ខាងស្ទឹងម្នាក់។ ទៅលើកទី១នោះ គាត់ទៅទាហានច្រើន ប្រហែលជា១០ ឬ២០នាក់ មិនដឹងទេ ពីរឡាន។ ពេលហ្នឹង ខ្ញុំរកវាយកម្ទេចគាត់ហើយ។ ខ្ញុំស្មានតែគាត់មករកវាយពួកខ្ញុំ។ ហើយក្រោយមក បាននីរសារទាក់ទងគ្នា ថាគាត់មកជួបទេ។ ខ្ញុំថាបើចង់ជួប គឺមកតែឯងមក កុំមានទាហាន។ បានប្រហែលមួយអាទិត្យក្រោយទៀត បានប្រហាក់ប្រហែលប៉ុណ្ណឹង បានគាត់ទៅតែតែកុងឡាន និងពរប្អូន –មីកញ្ច្រែង កូនគាត់មីពៅនោះ– ត្រូវជាប្អូនរបស់ខ្ញុំដែរនោះ ដែលយកទៅ។ មានតែប៉ុណ្ណឹងឯង។ ពេលនុំង ខ្ញុំក៏សម្រេចចេញមកជួបមក។ បាទ មានប៉ុណ្ណឹង បាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមសម្រាកសិន ដើម្បីប្តូរ ឌីវីឌី។ សម្រាកមួយនាទី។

*(សម្រាករយៈពេលខ្លី)*

[១៤:៥៣:៣៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានសំណួរច្រើនទៀតទេ? ហើយសូមអញ្ជើញបន្ត បាទ។

**លោក អាកទួរ វែកគែន៖**

ខ្ញុំជិតចប់ហើយ លោកប្រធាន ខ្ញុំនឹងបញ្ចប់នៅពេលបន្តិចទៀតនេះ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី លោកទើបតែផ្តល់ព័ត៌មានមួយចំនួនឲ្យលោកបានពន្យល់អំពីឥរិយាបថរបស់ រស់ ញឹម ចំពោះលោក។ ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុរបស់លោក លោកបានបញ្ជាក់ថា លោកបានបញ្ជូនទាហាន៣០០នាក់ទៅឲ្យការពារគាត់។ អ៊ីចឹង នេះគឺជាការបង្ហាញអំពីទម្រង់នៃការសហការគ្នារវាង

លោកនិងគាត់។ ពីព្រោះថាលោកបានផ្តល់កងទ័ព៣០០នាក់ឯណោះ ទៅដល់គាត់ ដើម្បីការពារគាត់។ អ៊ីចឹងមានន័យថា លោក និងគាត់ហ្នឹង មានការសហការគ្នាហើយ?

**លោក ទាត់ ធឿន៖**

**ធ៖** បាទ គាត់ -- ហ្នឹងគឺគាត់សុំ។ គាត់សុំខ្ញុំ មិនមែនសហការនឹងខ្ញុំទេ។ គាត់សុំខ្ញុំ។ គាត់ថាអស់ទាហានការពារហើយ។ គេបោសសម្អាតយកអស់ហើយ។ អ៊ីចឹង គាត់សុំខ្ញុំ៣០០នាក់បានអត់។ ហើយខ្ញុំក៏គិតមើល រួចហើយមួយសន្ទុះក្រោយ ខ្ញុំថាបាន តែកុំយកទៅវាយចោល ចាំខ្ញុំរកឱ្យ កុំយកទៅវាយចោលឲ្យសោះ បើថាវាយចោល ខ្ញុំក៏បាញ់ឪវិញដែរ វាយឪឯងវិញដែរ។ បើគ្រាន់តែប្រើការពារ ខ្ញុំឲ្យៗទាំងអាវុធ -- អ៎! ឲ្យទាំងមនុស្ស ឲ្យទាំងកាំភ្លើង។ នេះមិនមែនទៅជាសហការទេ គឺទៅសុំ។

**ស៖** បាទ សូមអរគុណ ប្រហែលជាបញ្ហាបកប្រែមើលទៅអ៊ីចឹង។ នេះជាសំណួរចុងក្រោយលោកប្រធាន។ លោកបានឆ្លើយថា ក្រោយឆ្នាំ៧៩ហ្នឹង លោកទៅរៀននៅសហភាពសូវៀតក្នុងរយៈពេល១០ខែ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើមិនមានបញ្ហាអីទេ ដែលគេបញ្ជូនលោកដំបូងទៅចិន ហើយក្រោយមកលោកបានទៅសូវៀតហ្នឹង គឺអត់មានបញ្ហាអីទេមែនទេ?

[១៤:៥៦:២១]

**ធ៖** បាទ អត់មានបញ្ហាអីទេ ប៉ុន្តែទៅរៀនៗនៅសហភាពសូវៀតហ្នឹងក៏អត់មានបញ្ហាអីដែរ តែគ្រាន់តែមានបញ្ហាអារម្មណ៍បងប្អូន កូនចៅចាស់របស់ខ្ញុំនៅនេះវា មានអ្នកបំផុសបំពងសំឡេងថា ខ្ញុំត្រូវយួនចាប់បាត់ហើយ។ ដល់អ៊ីចឹងទៅបំភ័យទៅ ខ្លះក៏នាំគ្នារត់អស់ទៅ ឈប់ធ្វើទាហាន ឈប់ធ្វើស្វ័យត្រាន រត់ទៅជំរំរបស់ប៉ាវ៉ា ខ្លះរត់ទៅថៃ ហើយការពិតគឺខ្ញុំត្រូវបានបញ្ជូនទៅរៀនពិតប្រាកដទេ មិនមែនគេចាប់ទេ តែអ្នកបំភ័យ មានពួកបំភ័យអ៊ីចឹងដែរ គឺមានបញ្ហាបាត់បង់កូនចៅបាទ។

**ស៖** សំណួរចុងក្រោយលោកសាក្សី តើចន្លោះឆ្នាំ៧៥ដល់ឆ្នាំ៧៩ លោកមានធ្លាប់ទៅវៀតណាមទេ?

**ធ៖** ៧៥-៧៩ អត់ មិនដឹងថាទឹកដីវៀតណាមនៅត្រង់ណា មុខយ៉ាងម៉េចផងបាទ។

**លោក អាកឡូវ វ៉ែកគែន៖**

បាទ ឯកឧត្តមប្រធាន សហមេធាវី -- សហភាតារបស់ខ្ញុំមានសំណួរសួរមួយសំណួរទៀតលោកប្រធាន។

**លោក គង់ សំអុនៈ**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុនៈ**

**សៈ** សូមជម្រាបសួរលោក ទាត់ ធឿន ខ្ញុំមានសំណួរខ្លីមួយទាក់ទងទៅនឹងការលាក់ទុកអាវុធរបស់លោកនៅបាត់ដំបង។ ដោយលោកបញ្ជាក់ថា លោកបានប្រមូលអាវុធពីចម្ការចេក ហើយយកទៅនៅម្ដុំខាងភ្នំវាយចាប។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា តើ សោ ភឹម មាន -- សូមទោស រស់ ញឹម មានបានណែនាំលោកពីរបៀបលាក់អាវុធហ្នឹងដូចម្ដេចខ្លះទេ?

[១៤:៥៨:៥៣]

**លោក ទាត់ ធឿនៈ**

**ធៈ** បាទ អត់បានណែនាំទេ គឺគ្រាន់តែថា រៀបចំលាទុកដាក់ ធ្វើឃ្លាំងទុកឱ្យស្អាតប៉ុណ្ណឹង។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសង់ឃ្លាំង ពីព្រោះលោកបានបញ្ជាក់ខាងដើមគឺជាការសង់ថ្មី ហើយទីតាំងទៀតគឺមិនស្ថិតនៅក្នុងកន្លែងដែលសាធារណជន ឬក៏អ្នកដទៃដឹងច្រើនទេ ជាការលាក់កំបាំង។ ទាក់ទងចំណុចនេះ តើលោក រស់ ញឹម មានបានណែនាំពីទំហំ ពីកម្ពស់ ឬក៏ពីបរិវេណនៃការសង់ឃ្លាំងនោះទេ?

**ធៈ** បាទ គាត់អត់មានការណែនាំទេ ព្រោះឃ្លាំងនេះវាធ្លាប់ -- ខ្ញុំធ្លាប់បានធ្វើតាំងពីសម័យសង្គ្រាមអស់ហើយ។ ហើយគាត់ក៏មិនណែនាំអី ធ្វើឃ្លាំងអីយ៉ាងម៉េចទៀតដែរ។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញ គឺតាមសក្ខីកម្មរបស់លោកអម្បាញ់មិញនេះ មានន័យថា លោក រស់ ញឹម បានដឹងពីសមត្ថភាពរបស់លោកក្នុងការសង់ឃ្លាំងដាក់អាវុធនេះកន្លងមកហើយ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ធៈ** បាទ ព្រោះគាត់ដឹងថា ខ្ញុំទុកដាក់អ្វីបានគត់មត់ល្អ គាត់ដឹងហើយ។ ហើយតា១បីនាក់ដែលខ្ញុំយកមក ក៏គាត់ធ្លាប់ធ្វើការងារជំនាញហ្នឹងហើយ បាទ។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ លោកធ្លាប់សង់ឃ្លាំងដាក់អាវុធនេះចំនួនប៉ុន្មានហើយ ក្នុងរយៈពេលតស៊ូរបស់លោកហ្នឹង?

[១៥:០១:០៩]

**ធៈ** បាទ កាលពីសម័យសង្គ្រាម ខ្ញុំបានធ្វើឃ្លាំងនេះបីកន្លែងរួចមកហើយ។ គឺទី១ កន្លែងមន្ទីរ

៤១០ នៅក្នុងដីពោធិ៍សាត់ ជាប់បាត់ដំបង ព្រំប្រទល់ជាប់បាត់ដំបង ក្បែរស្ទឹងមោង។ ហើយទី២ គេធ្វើឃ្លាំងនៅល្អាងដី ក្នុងដីស្រុកមោង តំបន់គេហៅតំបន់ល្អាងដី។ ល្អាងដី១ហ្នឹងគឺស្ទឹង វាបាក់ដូចល្អាងអ៊ីចឹង ហើយជាច្រាបកន្លែងខ្លា កន្លែងសត្វស៊ីដីហ្នឹង។ ឃ្លាំងទី២ គឺឃ្លាំង -- ឃ្លាំងទី៣ គឺឃ្លាំងរបស់មន្ទីរលេខ ២០ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងតា១បីនាក់ដែលលោកបានរៀបរាប់ឈ្មោះ តារ៉ន, តាឈឿម ហើយនិង តាចៅ នេះ លោកដឹងពីជោគវាសនារបស់គាត់ទេ ក្រោយពីការសង់ឃ្លាំងដាក់គ្រាប់ដែលលោកបានលាក់ចុងក្រោយហ្នឹង?

**ឆ៖** បាទ គាត់នៅមើលថែរក្សាហ្នឹងរហូតដល់តែខ្ញុំចេញទៅរត់ទៅព្រៃ ក៏គាត់ទៅជាមួយខ្ញុំ។ ដល់៧៩ ខ្ញុំបកមកវិញ ក៏គាត់មកជាមួយទាំងអស់គ្នាវិញដែរ។ គាត់ទើបតែខូចឆ្នាំ៨៥ រោគចាស់ជរាពាធហើយបាទ។

[១៥:០៣:០៨]

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរខ្លីមួយទៀត ទាក់ទងទៅនឹងពេលចុងក្រោយ នៅពេលដែលលោកធ្វើការតស៊ូ ហើយវាយជាមួយពួកខ្មែរក្រហមដែលលោកថា ជាអ្នកបាក់ទ័ពចេញពីភ្នំពេញទៅ ហើយដែលលោកថាមានចំនួនកាន់តែច្រើនទៅៗ លោកអត់បានដឹងពីការវាយប្រហាររបស់កងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋកម្ពុជាជំនាន់នុ៎ងទេ ប៉ុន្តែដល់ក្រោយមក លោកដឹង ហើយក៏មានការទាក់ទងគ្នាសហការគ្នា។ ហើយលោកបាននាំខាងក្រុមរំដោះហ្នឹង វាយពួកខ្មែរក្រហមនៅខាងបូព៌ាហ្នឹងទៀត។ ខ្ញុំចង់សួរថា តើលោកមានទំនាក់ទំនងយ៉ាងដូចម្តេច នៅដំណាក់កាលដំបូង បានអាចធ្វើការទាក់ទងគ្នាបាន?

**ឆ៖** បាទ វាយគ្នា បាញ់គ្នាមួយប្រាវ។ ដល់ទៅ ឃើញមានតែសុទ្ធតែស១ ខ្ញុំក៏គិតថា ទាហានចិនមកជួប ប៉ុល ពត ខ្ញុំអត់ដឹងថា វៀតណាមទេ។ វាយចាប់ពីម៉ោងដប់មួយថ្ងៃ រហូតដល់ម៉ោងប្រាំកន្លះល្ងាច បានខ្ញុំចាប់បានប្រាំពីរនាក់។ សួរទៅថា កងទ័ពរបស់វៀតណាមជួយរណសិរ្សសាមគ្គីសង្គ្រោះជាតិ មានតែ ប៉ែន សុវណ្ណ, មាន ហេង សំរិន, លោក ជា ស៊ីម ពេលនុ៎ង ក៏ខ្ញុំបានឱ្យប្អូននាក់ -- អ៎!ឱ្យបីនាក់មកវិញ។ ហើយនាំពួកខ្ញុំ ១០នាក់ -- ប្រាំពីរនាក់មិនដឹងទេវាយូរពេកដែរហើយ ហើយឱសានវាទខ្ញុំគឺថាទាក់ទងក្នុងរយៈពេល១០ថ្ងៃ បើមិនឃើញរបស់ខ្ញុំមកវិញទេ ប្អូននាក់នេះក៏ខ្ញុំសម្លាប់ដែរ" ខ្ញុំនិយាយអ៊ីចឹង។ បន្ទាប់មកគេទៅតែបួនថ្ងៃគេបកមកវិញ។ ពេលហ្នឹងខ្ញុំក៏ទាក់ទងគ្នាបានទៅ ដោយ

សហការគ្នានាំវាយតាមព្រំដែនថៃទៅបាទ វាយ ប៉ុល ពត តាមព្រំដែនថៃចេញទៅកោះកុង ខ្ញុំ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម បាទៗសូមអញ្ជើញបាទ!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីទ្បាត៖**

សូមអរគុណឯកឧត្តមប្រធាន ខ្ញុំៗព្យាយាមរក្សាឲ្យមានលំដាប់លំដោយនៃការសួរសំណួរ។

**សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីទ្បាត៖**

**ស៖** ពាក់ព័ន្ធទៅនឹងការដែលលោកទៅប្រទេសចិន នៅពេលដែលលោកបាននិយាយថា ឪពុកចិញ្ចឹមរបស់លោកបាននិយាយថា "យើងត្រូវតែដឹងអំពីរបៀបបើកបរយន្តហោះដើម្បីឲ្យយើងអាចដណ្តើមយកកម្ពុជាក្រោមនិងទីក្រុងដទៃទៀតបាន"។ ដូច្នេះតើគាត់និយាយថាយើងហ្នឹងគឺសំដៅលើអ្នកណាដែរ នៅពេលដែលគាត់និយាយថាយើងត្រូវធ្វើដើម្បីដណ្តើមទីក្រុងហ្នឹងមកវិញ។ តើ"យើង"ហ្នឹងជាអ្នកណា?

**លោក ទាត់ ធឿន៖**

**ធ៖** ខ្ញុំអត់យល់ន័យគាត់ធំទូលាយ ទូលំទូលាយដែរ តែគាត់និយាយអ៊ីចឹង ខ្ញុំក៏មិនយល់ដែរប៉ុន្តែខ្ញុំក៏ប្រកែកបណ្តោយទៅ។

[១៥:០៧:០៨]

**ស៖** លោកក៏បាននិយាយថា លោកបានឆ្លើយទៅគាត់ថា លោកមិនទៅបរទេសទេ ព្រោះលោកមិនចង់ស្លាប់នៅប្រទេសចិន។ ហេតុអ្វីបានជាលោកគិតថាជាការគ្រោះថ្នាក់ដែលត្រូវត្រឡប់ទៅប្រទេសចិននោះ?

**ធ៖** បាទ ព្រោះខ្ញុំបានគិតថា មួយពាយ័ព្យគេចាប់ទៅអស់ហើយ ហើយមិនអាចនៅតែខ្ញុំម្នាក់ទេច្បាស់ជាអ្នកដែលទៅចាប់មក គេចាប់យកមកហ្នឹង គឺថាឆ្លើយដល់ខ្ញុំដែរហើយបាទ នៅពេលហ្នឹងខ្ញុំគិតថាខ្ញុំក៏ទៅដែរ គ្រោះថ្នាក់ដែរបាទ។

**ស៖** តើលោកមិនគិតថា រស់នៅប្រទេសចិនវាមានសុវត្ថិភាពជាងទេឬ?

**ធ៖** ខ្ញុំអត់បានគិតអ៊ីចឹងទេ ខ្ញុំគិតថាមិត្តភក្តិខ្ញុំស្លាប់អស់ហើយ គេចាប់ទៅអស់ហើយ។ អ៊ីចឹងខ្ញុំនៅទឹកដីរបស់ខ្ញុំគឺថា ទោះបីយ៉ាងម៉េចក៏ខ្ញុំមានឱកាសតស៊ូវិញ ក៏ខ្ញុំបានប្តេជ្ញាថាមិនឲ្យចាប់បានទេ។ បើបាញ់បានបាញ់ បើថាបាញ់មិនបានទេ គឺខ្ញុំបាញ់វិញ បាញ់ហើយខ្ញុំបាញ់សម្លាប់ខ្លួនឯងតាមក្រោយ។

ខ្ញុំប្តេជ្ញាអ៊ីចឹងបាទ។

**ស៖** សូមអរគុណលោក។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ មុននឹងផ្តល់វេទិកានេះ ទៅឱ្យសហព្រះរាជអាជ្ញាខ្ញុំចង់សួរសហព្រះរាជអាជ្ញានិងមេធាវីនាំមុខបន្តិច។ តើលោក ការតាំងសំណួរនេះ លោកត្រូវការពេលវេលាប៉ុន្មានដែរ ទាំងពីរហ្នឹង ឬក៏ទៅតាមស្ទីដែលមាននៅក្នុងកម្មវិធីនេះ ឬក៏អាចសុំបន្ថែមយ៉ាងម៉េចទៀតដែរ? សូមអញ្ជើញមានយោបល់បន្តិចបាទ។

**លោក នីកូឡាស គូមជែន៖**

យើងសុំពេលបន្តិចលោកប្រធាន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំត្រូវការពេលវេលាតែ ១០ ទៅ១៥នាទីទេ ឯកឧត្តមប្រធាន ខ្ញុំសូមអនុញ្ញាតចាប់ផ្តើមមុន ហើយបន្ទាប់មកគឺឱ្យសហព្រះរាជអាជ្ញាឆ្លើយតបពាក់ព័ន្ធនឹងបញ្ហានេះ។

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោស ខ្ញុំអំមិញ ខ្ញុំចុចប៊ូតុងស៊ីសំឡេងខុស ទោះបីយ៉ាងណាមិនអីទេ។ ខ្ញុំអាចធ្វើបាន វាជាមិនបញ្ហាអ្វីទេ។ ដោយសារមិនមានការបកប្រែ ខ្ញុំសុំបញ្ជាក់ឡើងវិញ។ ខ្ញុំប្រាកដថា ទាំងមេធាវីការពារក្តី ក៏ដូចខាងមេធាវីដើមបណ្តឹង ក៏ដូចថាខាងព្រះរាជអាចបញ្ចប់នៅត្រឹមយ៉ាងយូរបំផុតម៉ោងបួន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង អង្គជំនុំជម្រះសុំធ្វើការសម្រាក១០នាទីសិន ហើយនឹងចូលមកវិញបាទ។

*(សវនាការសម្រាកពីម៉ោង ១៥:១១ នាទី ដល់ម៉ោង ១៥:២៤ នាទី)*

[១៥:២៤:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ ហើយនាពេលនេះ គឺសូមប្រគល់វេទិកានេះជូនខាងសហ

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាដើម្បីតាំងសំណួរដល់សាក្សី។ បាទ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណឯកឧត្តមប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរខ្លីៗទេ ដើម្បីសុំឲ្យលោកបំភ្លឺទៅនឹងចម្លើយរបស់លោក ដែលលោកបានផ្តល់តាំងពីព្រឹកមិញមក។ សំណួរទី១ ដែលខ្ញុំចង់សួរលោក គឺពាក់ព័ន្ធទៅនឹងរយៈពេលដែលលោកស្នាក់នៅប្រទេសចិន កាលពីព្រឹកមិញ ហើយនិងរសៀលនេះ លោកបាននិយាយថា លោកបានចាកចេញទៅចិននៅឆ្នាំ៧៦ ក៏ប៉ុន្តែលោកមិនបានបញ្ជាក់អំពីខែពិតប្រាកដដែលលោកចាកចេញទៅទេ អ៊ីចឹងខ្ញុំចង់ឲ្យជម្រាបជូនអង្គជំនុំជម្រះតុលាការកំពូលថា តើនៅខែណាដែលលោកចាកចេញទៅរៀននៅប្រទេសចិន?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ កន្លែងនេះគឺខ្ញុំវាយូរដែលហើយ ខ្ញុំវាមិនបានចាំទេ ប៉ុន្តែខ្ញុំដឹងថា ក្នុងដើមឆ្នាំ៧៦ប៉ុណ្ណឹងឯង បាទ ដល់ចាំខែ ខ្ញុំចាំមិនបានទេ យូរពេកហើយ។

[១៥:២៦:៥១]

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ដែលយើងបាននិយាយច្រើនរួចមកហើយតាំងពីព្រឹកមក នៅចម្លើយទី១២ លោកបានបញ្ជាក់ថាលោកបានចាកចេញទៅគឺនៅក្នុងខែមករា ឆ្នាំ១៩៧៦។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកឲ្យបានច្បាស់ថា លោកមាននឹកឃើញឡើងវិញទេថា លោកបានចាកចេញទៅគឺនៅខែមករា ឆ្នាំ១៩៧៦?

**ឆ៖** បាទ ប្រហែលជាក្នុងអំឡុងពេលហ្នឹងឯងបាទ។

**ស៖** លោកចាំទេថា នៅពេលដែលលោកត្រឡប់ចូលមកប្រទេសកម្ពុជាវិញ នៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំវាមិនចាំបានទេ ប៉ុន្តែពេលដែលខ្ញុំមក គឺរដូវវស្សាហើយ ប្រហែលជាពេលសម្រាកបុណ្យភ្ជុំមិនដឹង ឬបុណ្យចូលឆ្នាំក៏មិនដឹង ខ្ញុំបានសម្រាកមកលេងស្រុក ប្រហែលជារដូវបុណ្យភ្ជុំបាទ។

**ស៖** សូមអរគុណ នៅក្នុងកំណត់ហេតុរបស់លោកដដែលនៅក្នុងចម្លើយទី១៣ លោកបានឆ្លើយ

ថាលោកបានចូលមកវិញ គឺនៅខែវិច្ឆិកា ឆ្នាំ១៩៧៧។ អ៊ីចឹងតើលោកចាំឡើងវិញហើយឬនៅ?

**ឆ៖** បាទ ប្រហែលជាក្នុងពេលហ្នឹងឯង ប្រហែលចន្លោះប៉ុណ្ណឹងឯង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ ខ្ញុំចង់ឲ្យមានការណែនាំទាក់ទងទៅនឹងសេចក្ដីសម្រេចថា តើឯកសារណាដែលយើងអាចប្រើប្រាស់ជាមួយសាក្សីនេះបាន។ ខ្ញុំបានអានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ហើយខ្ញុំឃើញថាព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយរបស់ -- កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីនេះទេ។ ប្រសិនបើអនុញ្ញាតមែន យើងខ្ញុំក៏ត្រូវប្រើយ៉ាងច្រើនដែរ ប៉ុន្ដែខ្ញុំឃើញថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះបានហាមមិនឲ្យទាំងអស់គ្នាប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយ ទាំងមេធាវីដើមបណ្ដឹង ក៏ដូចជាសហព្រះរាជអាជ្ញា។

[១៥:២៩:២១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ការបំភ្លឺមានសារៈសំខាន់ណាស់ ឯកឧត្ដមប្រធាន ពីព្រោះថាខ្ញុំអានសេចក្ដីសម្រេចទៅ គឺខ្ញុំឃើញថា ពួកយើងត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារមួយនេះដើម្បីយកមកសួរដេញដោលសាក្សី។ សូមឯកឧត្ដមប្រធានបំភ្លឺអំពីករណីនេះ។

ហើយនៅក្នុងឯកសារ F26 ដែលខ្ញុំពិនិត្យមើលនោះ គឺមិនមានការបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ត្រូវបានទទួលការអនុញ្ញាតផ្សេងគ្នាអំពីអង្គជំនុំជម្រះទេ។ អ៊ីចឹងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ គឺ F26។ ហើយខ្ញុំសូមអនុញ្ញាតឲ្យអនុញ្ញាតឲ្យខ្ញុំបន្ដទៅទៀត ហើយសាក្សីក៏បានឆ្លើយទៅហើយនូវសំណួរអម្បាញ់មិញនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំនិយាយមិនច្បាស់អស់ជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្ដែខ្ញុំប្រាកដអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលហាមឃាត់ព្រះរាជអាជ្ញាមិនឲ្យប្រើប្រាស់ឯកសារនេះ។ តើវាជាការត្រឹមត្រូវមែនឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំកំពុងតែរង់ចាំការចង្អុលបង្ហាញពីអង្គជំនុំជម្រះ ថាតើខ្ញុំអាចបន្តទៀតបាន ឬក៏យ៉ាងណា។ តាមរយៈឯកសារ F26 គឺខ្ញុំយល់ឃើញថា ខ្ញុំអាចមានសិទ្ធិប្រើប្រាស់ឯកសារនេះ យកមកសួរដេញ

ដោលបាន។ ខ្ញុំប្រហែលជាអង្គុយចុះសិនមើលទៅ ដើម្បីអត់ធ្មត់ចាំចម្លើយពីអង្គជំនុំជម្រះ។

**លោក នីកូឡាស គូមជែន៖**

ដើម្បីឲ្យអ្វីៗដំណើរការទៅបានល្អ ខ្ញុំគិតថា ឯកសារនេះត្រូវបានដកចេញមិនឲ្យព្រះរាជអាជ្ញាប្រើប្រាស់ ព្រោះ ERN មិនត្រូវបានផ្ដល់ ប៉ុន្តែខ្ញុំគិតថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដូចជាមិនមានការហាមឃាត់នោះឡើយ។ ខ្ញុំសូមអរគុណ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំសូមសួរមេធាវីការពារក្ដីបន្តិច លោកដឹងអំពីកំណត់ហេតុនេះ គឺអំពីឯកសារដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែយោង។ មេធាវី យើងដឹង យើងប្រើប្រាស់នេះយ៉ាងច្រើនណាស់ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយគឺថាទាក់ទងទៅនឹងការប្រើប្រាស់ឯកសាររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ព្រោះថាឯកសារសេចក្ដីសម្រេច គឺអង្គជំនុំជម្រះហាមមិនឲ្យព្រះរាជអាជ្ញាប្រើប្រាស់។ តើលោកយល់យ៉ាងម៉េចដែរលោក វែកគែន? តើមេធាវី ខៀវ សំផន ស្គាល់ឯកសារ ដឹងឯកសារនេះច្បាស់លាស់ទេ?

[១៥:៣២:៣៤]

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំស្គាល់ច្បាស់ ឯកសារហ្នឹងច្បាស់ណាស់ បើសួរខ្ញុំថាស្គាល់ ខ្ញុំស្គាល់។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ថាតើលោកជំទាស់ទៅនឹងការដែលព្រះរាជអាជ្ញា -- ជំទាស់ទៅនឹងមិនឲ្យព្រះរាជអាជ្ញាប្រើប្រាស់ឬទេ?

**លោក អាកទួរ វែកគែន៖**

បាទ គឺខ្ញុំជំទាស់មិនឲ្យសហព្រះរាជអាជ្ញាប្រើទេ គឺអង្គជំនុំជម្រះបានសម្រេចរួចទៅហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមបញ្ជាក់បន្តិចមើល៍ ទាក់ទងនឹងលេខឯកសារដែលជាភាសាខ្មែរដាក់ F2/411 នេះជាភាសាខ្មែរ។ ប៉ុន្តែខ្ញុំឃើញបញ្ចាំងនៅក្នុងស្លាយនេះ-- អ៎! ក្នុងនេះ ក្នុងកុំព្យូទ័រដាក់លេខ E319/127 បាទ វាមិនច្បាស់ឯកសារហ្នឹងដែរ ខ្ញុំវាអត់ទាន់ច្បាស់ដែរ តើលោកមេធាវីអាចពន្យល់បានទេ?

[១៥:៣៣:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកសារដែលខ្ញុំនិយាយយោងមួយព្រឹកមកនេះ គឺជាឯកសារដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែប្រើប្រាស់ ហើយយើងមិនមានបញ្ហាអ្វីជាមួយឯកសារនេះទេ។ ទោះបីជាឯកសារនេះមិនមាននៅក្នុងបញ្ជី ប៉ុន្តែខ្ញុំជំទាស់ទៅនឹងការដែលព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញាមិនអាចប្រើប្រាស់បានទេ ព្រោះអង្គជំនុំជម្រះហាមឃាត់មិនឲ្យព្រះរាជអាជ្ញាបាន -- មិនឲ្យប្រើប្រាស់បាន។ ឥឡូវនេះ វាស្ថិតថាតើយើងដោះស្រាយយ៉ាងម៉េចទៅលើបញ្ហាសេចក្តីសម្រេច។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តាមពិតទៅ គឺដោយសារតែមានពេលវេលាកំណត់ ដូច្នេះខ្ញុំសូមរក្សាទុកការជំទាស់ទុកសិន ហើយបន្ទាប់មកទៀត ខ្ញុំនឹងជជែកអំពីបញ្ហានេះ ដោយសារតែយ៉ាងណាក៏ដោយ យើងត្រូវតែឲ្យភាគីទាំងអស់ដឹងអំពីឯកសារនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងនឹងរក្សាទុកនូវអ្វីដែលលោកលើកឡើងហ្នឹងរក្សាទុកសិន ជាពិសេសការហាមឃាត់មិនឲ្យព្រះរាជអាជ្ញាប្រើប្រាស់ឯកសារទាំងអស់នេះ។

ហេតុដូច្នេះ យើងសុំសួរទៅខាងព្រះរាជអាជ្ញាថាតើព្រះរាជអាជ្ញាយល់ថាកំណត់ហេតុស្តាប់ចម្លើយនោះវាមានប្រយោជន៍ឬក៏អត់? ហើយថាតើព្រះរាជអាជ្ញាចង់លើកយកឯកសារនេះមកប្រើប្រាស់ដែរ ឬក៏អត់? ប្រសិនបើព្រះរាជអាជ្ញាយល់ថាឯកសារនេះអាចប្រើប្រាស់បានហើយមានប្រយោជន៍ យើងនឹងពិភាក្សាសម្រេចនៅក្នុងអង្គជំនុំជម្រះ។

**លោក នីកូឡាស គូមជែន៖**

យើងអត់ត្រូវការឯកសារនេះទេ ដូច្នេះអង្គជំនុំជម្រះបន្តទៅមុខទៀតចុះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណឯកឧត្តមប្រធាន។

[១៥:៣៥:២៩]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ខ្ញុំត្រឡប់មកសំណួរខ្ញុំវិញ គឺខ្ញុំត្រូវបានអនុញ្ញាតឲ្យដកស្រង់នូវសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលមេធាវីការពារក្តីបានប្រើច្រើនមកហើយតាំងពីពេលព្រឹកមក។ ដូច្នេះ ខ្ញុំចង់

សួរសំណួរចុងក្រោយអម្បាញ់មិញនេះឡើងវិញដើម្បីឲ្យមានកំណត់ត្រាក្នុងប្រតិចារឹក។ លោកសាក្សីអម្បាញ់មិញនេះលោកបានឆ្លើយថា លោកចាំមិនច្បាស់ទេ អំពីកាលបរិច្ឆេទដែលលោកត្រឡប់ពីចិនចូលមកកម្ពុជាវិញ ហើយខ្ញុំក៏បានអានទូវចម្លើយទី១៣របស់លោកនៅក្នុងកំណត់ហេតុហ្នឹង ខ្ញុំបានបង្ហាញថា គឺខែវិច្ឆិកា ឆ្នាំ១៩៧៧ ហើយខ្ញុំបានសុំចម្លើយរបស់លោក ថាតើវាត្រឹមត្រូវទៅនឹងការចងចាំរបស់លោកដែរទេ គឺខែវិច្ឆិកា ឆ្នាំ១៩៧៧។

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ វាប្រហាក់ប្រហែលប៉ុណ្ណឹងឯង កំណត់យកប៉ុណ្ណឹងចុះ។

**ស៖** នៅពេលដែលលោកនៅប្រទេសចិន តើលោកមានដឹងអំពីហេតុការណ៍ដែលកើតឡើងនៅភូមិភាគពាយ័ព្យទេ លោកមានមធ្យោបាយអីដើម្បីទទួលបានព័ត៌មានអំពីស្ថានភាពដែលកើតឡើងនៅភូមិភាគពាយ័ព្យទេ?

**ឆ៖** បាទ អត់មានទេ តែព័ត៌មានវ៉ាដ្យូក៏អត់មានដែរ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយជាច្រើនដងអំពីសន្និបាតដែល រស់ ញឹម បានទៅចូលរួមនៅភ្នំពេញ ហើយលោកក៏បានជូនគាត់ទៅក្នុងឋានៈជាអ្នកបើកឡានឲ្យគាត់។ ខ្ញុំចង់សួរសំណួរដើម្បីឲ្យដឹងច្បាស់អំពីសន្និបាតដែលលោកបាននិយាយនេះ។ តើលោកអាចបញ្ជាក់បានទេថា តើសន្និបាតហ្នឹងមានរយៈពេលប៉ុន្មានដែរ មួយថ្ងៃ ឬក៏ច្រើនជាងមួយថ្ងៃ តើលោកអាចរៀបរាប់អំពីសន្និបាតហ្នឹងបានទេ?

**ឆ៖** បាទ មានរយៈពេលច្រើនថ្ងៃប្រហែលជាជិតមួយខែក៏មិនដឹង ឬមួយខែលើសក៏មិនដឹងបាទ ដោយសារយូរពេក ខ្ញុំមិនចាំបាន។

[១៥:៣៨:១៩]

**ស៖** នៅភ្នំពេញ តើសន្និបាតហ្នឹង គេធ្វើឡើងនៅកន្លែងណាដែរ លោកនៅចាំទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងថាធ្វើនៅកន្លែងណាទេ ប៉ុន្តែខ្ញុំជូនគាត់មកដល់មុខវាំងហើយ ល្ងាចហ្នឹងជូនមកបាយនៅ -- មានបាយ គេហៅបាយរួមនៅបុរីកីឡា ជូនមកដល់កន្លែងបាយ ខ្ញុំបកទៅកន្លែងវិញទៅបាទ។

**ស៖** ឯកឧត្តមប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីរៀបរាប់កន្លែងពីរដែលមាននៅក្នុងកថាខណ្ឌនៃៗសាលក្រមដែល នួន ជា និង ខៀវ សំផន បានប្តឹងសាទុក្ខ។ ខ្ញុំចង់ពិនិត្យមើលថាតើឈ្មោះពីរកន្លែងនេះធ្វើឲ្យសាក្សីនៅចាំវិញទេ គឺព្រះវិហារព្រះកែវមរកត ដែលធ្វើឡើងនៅខែឧសភា ឆ្នាំ៧៥ ហើយនិងពហុ

កីឡដ្ឋានជាតិអូឡាំពិក។ អ៊ីចឹងលោកមាននៅចាំកន្លែងពីរហ្នឹងទេ លោកសាក្សី?

**ឆ៖** បាទ កន្លែងសន្និបាត ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំគ្រាន់តែជូនមកដល់ហ្នឹង ហើយនៅភ្នំពេញនេះ គឺមានអ្នកនៅភ្នំពេញគេអ្នកទទួលជូនគាត់ទៅសន្និបាតអី គឺថាគេអ្នកទទួល។

**ស៖** មុននេះលោកបាននិយាយថា សន្និសីទគឺមានរយៈពេលមួយខែ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើ រស់ ញឹម គាត់ស្នាក់នៅភ្នំពេញពេញមួយខែតែម្តង ដើម្បីចូលរួមសន្និសីទនេះមែនទេ? លោកដឹងទេ?

[១៥:៤០:២៥]

**ឆ៖** បាទ នៅពេញទាំងអស់គ្នាហ្នឹង ទាំង រស់ ញឹម, ទាំង តាកឹ, ទាំង តាប៉ែត ប្រជុំគ្នាទាំងអស់ហ្នឹង។ ហើយដោយឡែក ខ្ញុំ ក្រុមការពារ និងនីរសារ ខ្ញុំប្តូរវេនគ្នាទៅផ្ទះ ទៅបាត់ដំបង ព្រោះមកភ្នំពេញនេះ ហូបអង្ករចេកសល់ពីសង្គ្រាម ធ្វើអង្ករចេក ដាំបាយហូប ខ្ញុំអត់ចេះហូប។ រត់ទៅយកអង្ករបាត់ដំបងមកហូបមក ដូរវេនគ្នា ចាំគាត់ចេញ។ ទៅប្រាំថ្ងៃម្នាក់ ទៅបាត់ដំបង។

**ស៖** មុនពេលដែលលោកចាកចេញទៅប្រទេសចិន នៅខែមករា ឆ្នាំ៧៦ តើលោកធ្លាប់ជូន រស់ ញឹម មកភ្នំពេញ ដើម្បីចូលរួមក្នុងឱកាសណាផ្សេងទៀត ក្រៅពីសន្និសីទមួយហ្នឹងទេ?

**ឆ៖** បាទ អត់មានទេ មានតែ -- ខ្ញុំអត់មានទេ មានតែជូនគាត់មកភ្នំពេញបានតែមុតងនុ៎ងទេ បាទ។

**ស៖** តើលោកដឹងទេថា នៅសម័យនោះ រស់ ញឹម គាត់ទៅភ្នំពេញញឹកញាប់ទេ? គឺខ្ញុំសំដៅទៅមុនពេលដែលលោកទៅចិននៅខែមករា ឆ្នាំ១៩៧៦។

**ឆ៖** បាទ តាំងពីពេលដែលគាត់បកទៅវិញ គឺខ្ញុំអត់ដឹងទេ។ មិនដឹងថាគាត់មកញឹកញាប់ ឬយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ បាទ។

**ស៖** មុនពេលលោកចាកចេញទៅចិននៅខែមករា ឆ្នាំ៧៦ តើលោកធ្លាប់ឃើញមេដឹកនាំអង្គការ ឬក៏មេដឹកនាំគណៈអចិន្ត្រៃយ៍មកទស្សនកិច្ចនៅក្នុងភូមិភាគរបស់លោកទេ?

**ឆ៖** បាទ មាន ក៏ប៉ុន្តែមិនដឹងថាថ្នាក់ណា អ្នកណា ព្រោះជិះឡានទៅ គឺឡានពួក ឡានអង្គការជិះហ្នឹង គេបាញ់ថ្នាំជិតកញ្ចក់អស់ បាញ់ថ្នាំមិនឲ្យមើលឃើញ នៅសល់តែទ្វារមុខរបស់ខាងតៃកុង និងកងការពារទេ។ អ៊ីចឹងខ្ញុំមិនដឹងថាអ្នកណាចុះទៅ គ្រាន់តែឃើញទៅ។ មួយខែ ឬកន្លះខែឃើញទៅម្តង។

**ស៖** តើគេមាននិយាយប្រាប់លោកទេថា អ្នកដែលមកទស្សនកិច្ចហ្នឹង ជាអ្នកណាខ្លះ?

[១៥:៤៣:២៤]

**ឆ៖** បាទ អត់មានទេ ហើយយើងក៏អត់ហ៊ានសួរដែរ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងចម្លើយដែលមាននៅក្នុងសាលក្រម ដែល នួន ជា និង ខៀវ សំផន បានប្តឹងសាទុក្ខ។ គឺកខណ្ឌ៧៤៧ នៅក្នុងសាលក្រម ដែលមានបញ្ជាក់អំពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ នៅខែសីហា ឆ្នាំ១៩៧៥។ តើពេលដែលលោកឃើញឡានថ្នាក់ដឹកនាំដែលមកហ្នឹង គឺនៅក្នុងខែសីហា ឆ្នាំ៧៥ហ្នឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ ប៉ុន្តែមានទៅបាទ។ ខ្ញុំមិនចាំខែបានទេ។

**ស៖** តើលោកដឹងថា ពួកគាត់មកទីនុំង គាត់ធ្វើអីខ្លះទេ? ហើយពួកគាត់ទៅទស្សនកិច្ចនៅកន្លែងណាខ្លះទេ? លោកចាំទេ ឡានដែលបិទកញ្ចក់ហ្នឹងគេទៅណាខ្លះ?

**ឆ៖** បាទ ព្រោះខ្ញុំអត់ដឹងថាទៅណាទេ ដឹងថាទៅផ្ទះ តាញ៉ឹម មកនៅកន្លែងផ្ទះ តាញ៉ឹម នៅអំពិលប្រហោង ហើយចេញទៅទៀត គឺគាត់ទៅកន្លែងណាទៀតខ្ញុំអត់ដឹងទេបាទ។

[១៥:៤៥:២៤]

**ស៖** សូមអរគុណ។ លោកបានឆ្លើយទៅនឹងសំណួររបស់ កូប៉េ ពាក់ព័ន្ធទៅ នួន ជា លោកឆ្លើយថាលោកធ្លាប់ឮឈ្មោះគាត់ ប៉ុន្តែលោកមិនដែលជួប នួន ជា ដោយផ្ទាល់ទេ។ ខ្ញុំចង់ឲ្យលោកប្រតិកម្មតបទៅនឹងសំណួរ -- ទៅនឹងចម្លើយមួយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺនៅក្នុងចម្លើយទី៣៥ នៅក្នុងកំណត់ហេតុរបស់លោក លោកបាននិយាយថា នួន ជា និង រស់ ញ៉ឹម ហ្នឹងជាមិត្តភក្តិគ្នាតាំងពីយូរណាស់មកហើយ ពួកគាត់រៀននៅជាមួយគ្នា ហើយក៏បួសជាមួយគ្នានៅថៃ។ តើលោកអាចជម្រាបបានទេថា តើ នួន ជា និង តាញ៉ឹម នេះ មានទំនាក់ទំនងជាមួយនឹងគ្នាយ៉ាងម៉េចដែរ បើតាមការចងចាំរបស់លោកនៅសម័យនោះៗ?

**ឆ៖** បាទគឺ ដំណឹងនេះ គឺខ្ញុំឮពីឪពុកចិញ្ចឹមខ្ញុំនិយាយទេ គាត់រៀបរាប់ពីប្រវត្តិរបស់ តានួន ជា បាទ និយាយប្រាប់ឲ្យខ្ញុំស្តាប់។

**ស៖** នៅពេលដែលលោកនិយាយអំពីប្រវត្តិនេះ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ បើខ្ញុំតាមខ្ញុំឮពីភាសាបារាំងមក គឺឮអ៊ីចឹង?

**ឆ៖** បាទ សូមសំណួរម្តងទៀត ខ្ញុំស្តាប់អត់ទាន់កន្លែងហ្នឹងបាទ មិនទាន់យល់សំណួរបាទ។

**ស៖** ខ្ញុំបានឲ្យលោកឆ្លើយតបនឹងចម្លើយមួយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត នេះជាសម្តីរបស់លោក ហើយមានការកត់ត្រានៅក្នុងកំណត់ហេតុ "នួន ជា និង តាញ៉ឹម ជាពួកម៉ាកគ្នា

យូរមកហើយ ធ្លាប់ទៅរៀន និងបួសនៅស្រុកថៃជាមួយគ្នា”។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកដឹងព័ត៌មាននេះ? ហើយលោកមានព័ត៌មានអ្វីផ្សេងទៀតពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាង នួន ជា និង តាញឹម នៅសម័យនោះទេ?

[១៥:៤៨:០០]

**ឆ៖** បាទ គឺខ្ញុំដឹងតាមរយៈ តាញឹម –ឪចិញ្ចឹមខ្ញុំហ្នឹង– គាត់និយាយរៀបរាប់ប្រាប់ខ្ញុំពីប្រវត្តិតានួន ជា ជាមួយគាត់។ ដឹងតាមរយៈអ៊ីចឹងបាទ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី នៅក្នុងចម្លើយដដែល គឺនៅខាងលើ។ លោកបាននិយាយថា លោកបានពិភាក្សាគ្នាជាមួយឪពុកធម៌របស់លោក ហើយគាត់បានប្រាប់លោកថា “នួន ជា ក្បត់យើង”។ តើលោកអាចបញ្ជាក់អំពីខ្លឹមសារនៃការសន្ទនាគ្នារវាងលោក និងឪពុកធម៌របស់លោកហ្នឹងទេ ហើយហេតុអីបានជាឪពុកធម៌របស់លោកមានអារម្មណ៍ថា “នួន ជា ក្បត់ពួកយើង” នៅក្នុងឃ្លាហ្នឹង?

**ឆ៖** បាទ ក្នុងកំណត់ត្រានេះ គឺមិនមែនឪពុកធម៌ខ្ញុំអ្នកថាទេ ប្រហែលជាអ្នកបកប្រែខុសពីមុនខ្ញុំមិនដឹងយ៉ាងម៉េចទេ។ ខ្ញុំបានប្រាប់គាត់ថា “ប្រហែល នួន ជា ហ្នឹងក្បត់យើងហើយ បានសម្លាប់អស់អ្នកពាយ័ព្យនោះ” បាទ ភាសាគឺអ៊ីចឹងទេបាទ។

**ស៖** សូមអរគុណលោកសាក្សី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ឯកឧត្តមប្រធានខ្ញុំអស់សំណួរហើយ សូមអនុញ្ញាតប្រគល់វេទិកានេះជូនការិយាល័យសហព្រះរាជអាជ្ញា។ សូមអរគុណឯកឧត្តមប្រធាន។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណឯកឧត្តមប្រធាន។ សូមគោរពអង្គជំនុំជម្រះ។

[១៥:៥០:០៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំមានសំណួរខ្លីទេចង់សួរបញ្ជាក់លោក។ តែមុននឹងចាប់ផ្តើមដល់សំណួរខ្ញុំ ខ្ញុំមានសំណួរបន្តពីមេធាវីនាំ

មុខដើមបណ្តឹងរដ្ឋប្បវេណី។ លោកបាននិយាយថា "ប្រហែលជា នួន ជា ក្បត់យើងហើយមើលទៅ"។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឬក៏យល់ឃើញដូច្នេះ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ព្រោះខ្ញុំគិតថា នួន ជា គាត់នៅបាត់ដំបង នៅវត្តគ ហើយឪពុករបស់ខ្ញុំគាត់នៅភ្នំស្រុក តែបានប្រពន្ធនៅខ្សាច់ពយ នៅជិតគ្នា បានគ្នា។ ហើយពេលហ្នឹងគឺថា អ្នកដែលទៅបាត់ខ្លួនចាប់ខ្លួន គេហៅមករៀននៅភ្នំពេញ។ ចាប់ខ្លួននៅភ្នំពេញ ថ្នាក់តំបន់ ថ្នាក់កងពលអីយកមកភ្នំពេញរៀន ចាប់អស់។ ពេលហ្នឹងជាការសន្និដ្ឋានរបស់ខ្ញុំថា បើ នួន ជា មិនក្បត់ គេយក -- គឺ នួន ជា មិនអាចដែលថា ចាប់កម្មាភិបាលពាយ័ព្យ។ នេះគឺការកំណត់ក្នុងចិត្តរបស់ខ្ញុំ ហើយខ្ញុំជាមួយគាត់។

[១៥:៥១:៣៦]

**ស៖** ចាស សូមអរគុណ។ ត្រឡប់មកថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកបានប្រើអង្គសវនាការនៅថ្ងៃនេះថា ក្រោយរំដោះប្រហែលជាជិត១០ថ្ងៃ អាចមុន១០ថ្ងៃបន្តិច ឬក៏ក្រោយ១០ថ្ងៃបន្តិចហ្នឹង គឺ តាវ៉ាញ ជាអ្នកកាន់ឃោសនាសព្ទវិទ្យុចម្ការចេក។ គាត់បានអំពាវនាវឱ្យទាហាន លន់ នល់ ទាំងអស់ហ្នឹងដាក់អាវុធ។ ខ្ញុំចង់ឱ្យលោករំឭកអំពីព្រឹត្តិការណ៍នោះបន្តិចថា តើពេលនោះ តាវ៉ាញ ហ្នឹងគាត់មានតួនាទីអ្វី? ហើយគាត់បានប្រកាសថាម៉េចខ្លះ? ហើយប្រកាសនៅកន្លែងណាដែរ?

**ឆ៖** បាទ ពេលនោះគឺ តាវ៉ាញ គឺគាត់តួនាទីប្រធានតំបន់២ តួនាទីគាត់ ហើយគាត់ជាសាស្ត្រាចារ្យម្នាក់ទទួលបន្ទុកបញ្ញវន្តផ្ទៃក្នុង។ បានន័យថា ពួកបញ្ញវន្តដែលនៅក្នុង លន់ នល់។ អ៊ីចឹង គឺស្គាល់គាត់ច្រើន។ អ៊ីចឹង បានចាត់តាំងឱ្យគាត់និយាយឃោសនាសព្ទគេអាចគេស្តាប់បានច្រើនជាង គេស្តាប់តាមគាត់ច្រើន។

[១៥:៥៣:២៥]

**ស៖** ចុះពេលហ្នឹងគាត់បាននិយាយតាមវិទ្យុហ្នឹង គាត់និយាយថាយ៉ាងម៉េចខ្លះ? លោកនៅចាំពាក្យពេចន៍ ឬក៏សម្តីរបស់គាត់ពេលដែលគាត់ប្រកាសហ្នឹងទេ? ហើយខ្លឹមសារហ្នឹងគឺសំដៅចង់បានអ្វីដែរ?

**ឆ៖** បាទ ពេលហ្នឹងគឺតាមខ្ញុំចាំបានខ្លះ បើចាំទាំងអស់ ខ្ញុំចាំមិនបានទេ វាកាត់ៗបានខ្លះថា ប្រទេសបានរំដោះហើយ របបចក្រពត្តិនិយមដួលរលំហើយ ស្តេចនរោត្តមសីហនុបានមកគ្រប់គ្រងជាប្រមុខរដ្ឋវិញហើយ បងប្អូនមាន សង្គ្រាមចប់ត្រឹមហ្នឹងហើយ សុំឱ្យស្តាប់ទៅតាមការអំពាវនាវរបស់

រណសិរ្សបាទ”។

**ស៖** តើគាត់អំពាវនាវឲ្យបងប្អូនហ្នឹង គឺសំដៅទៅលើក្រុម ឬក៏មនុស្សប្រភេទណាដែរ ដើម្បីឲ្យចុះចូលជាមួយនឹងរណសិរ្សហ្នឹង?

**ឆ៖** បាទ គាត់ -- និយាយរួម គឺសំដៅរួមទូទៅទាំងប្រជាជន ទាំងទាហាន ទាំងរាជការស៊ីវិល និយាយទាំងអស់ បាទ។

**ស៖** ចុះដោយឡែក បន្ទាប់ពីគាត់បានប្រកាសអំពាវនាវអ៊ីចឹងហើយហ្នឹង មានមនុស្សប្រភេទណាខ្លះដែលចុះចូលមក ហើយមនុស្សប្រភេទ -- ក្រុមប្រភេទណាដែលមានអាវុធ ហើយបានត្រឡប់មកចុះចូលជាមួយគាត់ហ្នឹង?

**ឆ៖** មានអាវុធ គឺកងទាហាន ទាហានរបស់លន់ នល់ នៅបាត់ដំបង ហើយកាលនុ៎ងគេហៅកងស្វ័យត្រាណ ប៉ុន្តែដាក់អាវុធទាំងអស់គ្នា។ អាវុធរាយប៉ាយ ដាក់មិនមែនយកមកគរម្ដុំទេ រាយប៉ាយពេញតែផ្លូវហ្នឹងឯង គ្រប់កន្លុក គ្រប់កន្លែង បានយក គេដឹកទៅយកដាក់នៅចម្ការចេកទៅ។

[១៥:៥៦:៥១]

**ស៖** ចុះក្រោយពីទាហានលន់នល់ ដែលមានអាវុធហ្នឹងគាត់បានចុះចូល។ មានន័យថាប្រគល់អាវុធហើយហ្នឹង តើមានរឿងអ្វីកើតឡើងចំពោះទាហានលន់នល់ ដែលបានប្រគល់អាវុធទាំងអស់នោះ?

**ឆ៖** បាទ ក្រោយមក ខ្ញុំដូចបានជម្រាបខាងដើមហើយថា គេឲ្យពួកគាត់មកទទួលស្ដេច ទទួលសម្ដេចឪ បានវិលត្រឡប់មក គេឲ្យទៅទទួលសម្ដេច ដឹកទាំងឡានៗទៅទទួលស្ដេច និងក្រោយមកបានប្រហែលជា១០ថ្ងៃ បានខ្ញុំដឹងថាគេយកទៅវាយចោល បាទ។

**ស៖** ហេតុអ្វីបានជាលោកដឹងថា គេយកទាហាន នល់ នល់ ទាំងអស់ហ្នឹងទៅវាយចោល? ហើយគេយកទៅវាយចោលនៅកន្លែងណាដែរ បើលោកដឹង?

**ឆ៖** មិនដឹងថាគេយកទៅវាយចោលកន្លែងណាទេ គឺគេដឹកមកត្បូងមក កាត់ពីជិតកន្លែងខ្ញុំនៅកំពង់ព្រះហ្នឹង។ មុនដំបូង ខ្ញុំអន់ចិត្តគេ អន់ចិត្តនឹងឪខ្លួនឯង ខំតស៊ូ ខំរត់សំបុត្រ រត់សារចង់ងាប់ មិនបានទៅទទួលស្ដេច ឲ្យគេដាក់អាវុធថ្មី គេបានទទួលស្ដេច វាវាងអន់ចិត្តដែរ។ ដល់អ៊ីចឹងទៅ បានក្រោយពីរត់សារបានពីរដើងមក សម្រាក បានឈ្មោះ ណូ – ណូ ធំនោះបាទ – ឈ្មោះ ណូ ធំថា៖ “ឯងច្រណែនស្អី ពួកហ្នឹងគេយកទៅវាយចោលហ្នឹង មិនទៅទទួលស្ដេចឯណា”។ អ៊ីចឹងបានខ្ញុំថា អឺ! ប៊ិះដោយ បើអញសុំទៅដែរ បែបដោយទៅដែរអ៊ីចឹង។ ខ្ញុំក៏ថាអ៊ីចឹងទៅ។

[១៥:៥៩:០៩]

**ស៖** ចុះលោកថា គេបានដឹកទាហានលន់នល់ ទាំងអស់ហ្នឹងកាត់មុខលោកហ្នឹង តើលោកឃើញស្ថានភាពពេលនោះយ៉ាងម៉េចដែរ មានន័យថាឃើញចំនួនប៉ុន្មាន ហើយស្ថានភាពដែលគេដឹកចេញហ្នឹងដោយមធ្យោបាយណាដែរ?

**ឆ៖** បាទ ដឹកចេញដោយឡាន ហ្សេ.អឹម.សេ និង ឡានដួតសំណាញ់។ ទាំងឡានៗចេញទៅ ហើយចំពោះទាហាន លន់ នល់ ស្រែក "ជយោ! សម្តេចឪ!" អ៊ីចឹងទៅ ស្រែក "ជយោ! សម្តេចឪ!" តែរហូតអ៊ីចឹងទៅនៅលើឡាន ទៅទទួលសម្តេចឪ "ជយោ!សម្តេចឪ!" អ៊ីចឹងទៅ។ ហើយខ្ញុំ វាចំផ្លូវដែលខ្ញុំរត់សំបុត្រទៅមក វាពីកំណាត់មោង មកកំពង់ព្រះហ្នឹងវាវែងដែរ ជិតជាង២០គីឡូដែរ អ៊ីចឹងឃើញអ៊ីចឹងវាមានអារម្មណ៍មួយថា គេបានទៅ ខ្ញុំអត់បានទៅ។ ហើយការស្រែករបស់ទាហានលន់ នល់ គេស្រែកប៉ុណ្ណឹង អត់មានភ័យតក់ស្លុត អត់ដឹង ហើយស្រែកថា "ជយោ! សម្តេចឪ!, ជយោ! ទៅទទួលសម្តេចឪ!" ស្រែកតែអ៊ីចឹងបាទ។

**ស៖** តើលោកបានដឹងទេថា ហេតុអ្វីបានជាមានគោលនយោបាយ ដើម្បីប្រមូលទាហានលន់នល់ទាំងអស់នោះ?

**ឆ៖** ខ្ញុំទាន់យល់សំណួរ បាទ។ សូមបញ្ជាក់ម្តងទៀត។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ ខ្ញុំចង់សួរលោកថា តើលោកបានដឹងថា ហេតុអ្វីបានមានគោលនយោបាយក្នុងការប្រមូលទាហាន លន់ នល់ ទាំងអស់នោះ ទៅសម្លាប់ទេ?

[១៦:០១:៣០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកស្រីព្រះរាជអាជ្ញា តើលោកស្រីសួរយ៉ាងដូចម្តេចដែរ? គឺថាសំណួរដែលលោកស្រីដាក់គឺហាក់ដូចជាលើកបង្ហាញថាវាមានគោលនយោបាយ ប៉ុន្តែសាក្សីមិនបានបញ្ជាក់អះអាងអំពីអង្គហេតុមួយនេះទេ សូមលោកស្រីព្រះរាជអាជ្ញាសួរសំណួរឡើងវិញ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកស្រីចៅក្រម ខ្ញុំនឹងរៀបចំសំណួរម្តងទៀត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តើលោកបានដឹងថា ហេតុអ្វីបានជាមានការប្រមូលមនុស្សទាំងអស់ហ្នឹងដឹកតាមឡាន

ហើយតាមដែលលោកថាហ្នឹង គឺយកទៅសម្លាប់នោះ?

**លោក ទាត់ ធឿន៖**

**ធ៖** បាទ ខ្ញុំអត់ដឹងដែរ។ មិនដឹងថា ពីត្រឹមណា ថ្នាក់ណា អ្នកណាបញ្ជា ខ្ញុំអត់ដឹងដែរ។

**ស៖** ចាស អរគុណ។ ខ្ញុំចង់សួរបញ្ជាក់លោកបន្តិច ពាក់ព័ន្ធទៅនឹងមូលហេតុដែលឪពុកចិញ្ចឹមរបស់លោក គឺ រស់ ញឹម បានបញ្ជូនលោកទៅរៀនបើកយន្តហោះនៅប្រទេសចិន។ ពេលដែលលោកត្រឡប់មកវិញហ្នឹង ឪពុករបស់លោកបានប្រាប់លោកឲ្យត្រឡប់ទៅប្រទេសចិនវិញ ហើយលោកប្រកែកមិនទៅ។ ហើយឪពុករបស់លោកបានប្រាប់លោកថា ឲ្យលោកទៅរៀនហ្នឹង ដើម្បីឲ្យលោកចេះបើកយន្តហោះ ដើម្បីវាយដណ្តើមយកទឹកកម្ពុជាក្រោមត្រឡប់មកវិញ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើពេលនោះហ្នឹង គាត់បានប្រាប់លោកថាហេតុអ្វីបានជា ឬក៏គំនិតរបស់គាត់ដែលប្រាប់លោកថា ត្រូវតែវាយដណ្តើមយកទឹកដីកម្ពុជាក្រោមមកវិញហ្នឹង។ គាត់ចង់សំដៅដល់ស្ថានភាពណាមួយ ឬក៏គាត់ចង់ប្រាប់លោកពីខ្លឹមសារអ្វីដែរនៅពេលនោះ នៅពេលដែលលោកកំពុងតែនិយាយជាមួយគាត់ពេលនោះ?

[១៦:០៣:៣៤]

**ធ៖** ខ្ញុំមិនដឹងថាគាត់និយាយសំដៅន័យយ៉ាងម៉េច ក្នុងខ្លឹមសារគាត់និយាយអ៊ីចឹង។ និយាយដើម្បីលើកទឹកចិត្តឲ្យខ្ញុំបានត្រឡប់ទៅរៀនវិញ ឬក៏មានគោលដៅរបស់អង្គការអ៊ីចឹងមែន ខ្ញុំក៏អត់ដឹងដែរ បាទ តែគាត់បាននិយាយអ៊ីចឹងមែន ថាត្រូវតែយកទឹកដីកម្ពុជាក្រោម យកទឹកដីនគររាជមកវិញ ដីដែលបាត់បង់ពីមុន។ អ៊ីចឹងត្រូវខំទៅរៀនទៅ។ ខ្ញុំថា ខ្ញុំមិនទៅ ព្រោះអត់មានមិត្តភក្តិ បាត់អស់ហើយ។

**ស៖** នៅលើប្រធានបទមួយទៀតហ្នឹង គឺទស្សនកិច្ចរបស់ថ្នាក់ដឹកនាំមកខេត្តបាត់ដំបង។ មុននេះលោកបានឆ្លើយជាមួយនឹងសហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណីថា ថ្នាក់ដឹកនាំមកខេត្តបាត់ដំបងហ្នឹង គឺកន្លះខែ ទៅមួយខែម្តង ហើយខ្ញុំចង់សួរបញ្ជាក់លោកថា រយៈពេលដែលគាត់មកកន្លះខែ មួយខែម្តងហ្នឹង ចាប់ផ្តើមពីពេលណា –ខ្ញុំចង់និយាយពី១៧ មេសា ៧៥– រហូតដល់ពេលណាដែរតាមដែលលោកចាំ?

**ធ៖** បាទ គឺក្រោយពេលដែលសន្និបាតហើយ សន្និបាតពួកគាត់មកសន្និបាតនៅភ្នំពេញហើយ។

**ស៖** ក្រោយពេលសន្និបាតហើយហ្នឹង លោកនៅចាំបានទេថាមកបានប៉ុន្មានដង ជាសរុបតាមដែលលោកដឹង តាមដែលលោកចាំ?

[១៦:០៥:៤៣]

**ឆ៖** បាទ ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែបើមិនខ្វះពីពីរដង ហើយក៏មិនលើសពីបីដងដែរបាទ ក្នុងរង្វង់ប៉ុណ្ណឹងឯងបាទ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណ។ សូមអរគុណឯកឧត្តមប្រធាន សូមផ្ទេរវេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអរគុណលោកសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោក ខ្ញុំឈ្មោះ នីកូឡាស គូមជែន។ ខ្ញុំមានសំណួរមួយចំនួនដែលលោកបានបញ្ជាក់រួចមកហើយនៅព្រឹកនេះ គឺថាលោកគឺជាអ្នកនាំសារពីភូមិភាគទៅមជ្ឈិម។ ដូច្នេះខ្ញុំចង់ផ្តោតតែក្នុងខែមេសា ឆ្នាំ៧៥។ តាមដែលលោកដឹង ថាតើក្នុងមួយថ្ងៃមានសារប្រហែលប៉ុន្មានដែរដែលគេបញ្ជូនទៅខាងមជ្ឈិម?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ពេលដែលបើកយុទ្ធនាការវាយខ្លាំងហ្នឹង គឺមួយថ្ងៃមានម្តង ពីរដង ទៅបីដង មានអស់ៗច្រើនបីដងក្នុងមួយថ្ងៃ។ អ៊ីចឹងពួកខ្ញុំទាំងបីនាក់ហ្នឹងគឺថាអត់មានបានពេលទំនេរទេ វិល។ បើខ្ញុំទៅនាំសារទៅពេលព្រឹក ពេលថ្ងៃមានមួយសារទៅតាមក្រោយខ្ញុំទៀត មានមនុស្សម្នាក់ទៀត។ បើមានពេលល្ងាច មានម្នាក់ទីបីហ្នឹង គេយកសារទៅពេលល្ងាចទៀត។ ដល់អ៊ីចឹងទៅដល់នោះ គេប្រាប់ខ្ញុំថាឲ្យស្រូតមកវិញ អស់មនុស្សហើយ។ ខ្ញុំក៏ស្រូតមកទាំងយប់វិញ បកមកវិញ។ ដល់ព្រឹកឡើង ឬក៏មួយថ្ងៃ ឬពីរថ្ងៃមកដល់ ទៅដល់ ទទួលយកបន្តទៀត។ អ៊ីចឹងនិយាយរួម គឺថាពេលយុទ្ធនាការវាយ ដើម្បីវាយរំដោះហ្នឹង គឺថាសារជាប្រចាំគឺពីរដង បីដងក្នុងមួយថ្ងៃ។

[១៦:០៧:៥៥]

**ស៖** នៅពេលដែលលោកនិយាយអំពីការបញ្ជូនសារទៅមជ្ឈិម តើលោកចង់និយាយសំដៅទៅលើការបញ្ជូនសារទៅដល់ទីតាំងដោយផ្ទាល់ដៃតែម្តង ឬមួយក៏លោកនិយាយអំពីការបញ្ជូនតាមសារទូរលេខ?

**ឆ៖** បាទ ខ្ញុំយល់សាររបស់គាត់ ៗដាក់ក្នុងស្រោមសំបុត្រ គាត់បិទ គាត់ដាក់លេខ បង់លេខមកមន្ទីរសារទូរលេខកន្លែងផ្សាយទូរលេខ នៅមន្ទីរលេខ២០។ កន្លែងទូរលេខគេបកបាំង គេផ្សាយបន្ត។ ហើយមានអ្វីពីមជ្ឈិមមក គេបកបាំងអស់ហើយ គេបិទស្រោមសំបុត្រ ដាក់ស្រោមសំបុត្រ គេបិទ

ហើយគេឲ្យខ្ញុំកាន់មកវិញ វាមានទៅមកអ៊ីចឹង បញ្ជោសគ្នាទៅមកអ៊ីចឹង។

**ស៖** ដូច្នេះ ដើម្បីឲ្យបានច្បាស់ អ៊ីចឹងលោកនិយាយថា -- អំមិញលោកនិយាយថាមួយទៅបីដងក្នុងមួយថ្ងៃ ដូច្នេះគឺលោកនិយាយពីមួយទៅបីដងក្នុងមួយថ្ងៃហ្នឹង ពីភូមិភាគទៅមជ្ឈិម។ ចុះពីមជ្ឈិមមកភូមិភាគវិញ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមធ្វើការសង្កេតបន្តិចទៅលើសំណួរនេះ។ ខ្ញុំគិតថាការប្រើប្រាស់ពាក្យថា "មជ្ឈិម" ៗនៅទីនេះគឺហាក់ដូចជាមិនមែនស្ថិតនៅក្រុងភ្នំពេញនោះទេ។ ដូច្នេះប្រហែលជាមានការយល់ច្រឡំរបស់សាក្សី ឬមួយក៏យ៉ាងម៉េច ព្រោះថាហេតុការណ៍នេះ គឺថាសាក្សីគាត់និយាយថាគាត់ជាអ្នកបញ្ជូនសារពីភូមិភាគទៅ។ ដូច្នេះនៅមុនថ្ងៃ១៧ មេសា ៧៥ មិនទាន់មានមជ្ឈិមនៅឡើយ។

[១៦:១០:០៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺថាខ្ញុំគិតថា លោកប្រហែលជាយល់សំណួរខ្ញុំច្បាស់ហើយ។ នៅពេលដែលខ្ញុំនិយាយថាមជ្ឈិមហ្នឹង តើលោកយល់ថាមជ្ឈិមហ្នឹងសំដៅលើអីដែរ? តើលោកគិតថាខ្ញុំហ្នឹងចង់សំដៅលើអ្វីដែរជាមួយនឹងពាក្យថា "មជ្ឈិម" នោះ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ កាលពេលនោះ គឺនៅភូមិភាគពាយ័ព្យ គេបាននិយាយអ៊ីចឹងហើយ ហៅថ្នាក់លើ ឬក៏មជ្ឈិមអ៊ីចឹង តាំងពីនៅព្រៃម្លេះ បាទ។

**ស៖** សូមអរគុណលោក។ ដូច្នេះខ្ញុំចង់សួរលោក លោកនិយាយអំពីចំនួនសារពីភូមិភាគទៅមជ្ឈិម។ ចុះចំនួនសារពីមជ្ឈិមបញ្ជូនមកភូមិភាគវិញ តើមានចំនួនប៉ុន្មានដែរ?

[១៦:១១:០៣]

**ឆ៖** បាទ ខ្ញុំវាអត់ដឹងច្បាស់ដែរ ពីថ្នាក់លើ ពីមជ្ឈិមមកភូមិភាគ ព្រោះជួនកាល ខ្ញុំបានទទួល ជួនកាលអ្នកទី២ គេទទួលដែលអ្នកជើងទី២។ ជួនកាលអ្នកជើងទី៣ គេទទួលយកមក បាទ។

**ស៖** តើៗការបញ្ជូនហ្នឹងវាធ្វើឲ្យឡើងជាញឹកញាប់ ឬមួយក៏យ៉ាងម៉េចដែរ? វាធ្វើឡើងជាទៀងទាត់យ៉ាងម៉េចដែរ ពីការបញ្ជូនពីមជ្ឈិម មកភូមិភាគនោះ?

**ឆ៖** ពេលចាប់ផ្តើមបើកយុទ្ធនាការវាយ គឺជួនកាលពីរថ្ងៃពីជម្លឹម បានខ្ញុំទទួលម្តង។ ជួនកាល

បីថ្ងៃទទួលម្តង ក៏ប៉ុន្តែអ្នកទី២ និងអ្នកទី៣ មិនដឹងថាគេបានទទួលអត់ ខ្ញុំវាអត់ដឹងដែរ ព្រោះការងារហ្នឹង គេអត់មានបានសួរដេញដោលគ្នាបានទេ ព្រោះការលាក់ការណ៍រៀងៗខ្លួន គេអត់ឲ្យមានការសួរគ្នាបានទេ រឿងហ្នឹង។

**ស៖** សូមអរគុណ ដោយ -- ហើយយើងសូមអរគុណច្រើន ដែលលោកនិយាយតែអ្វីដែលលោកដឹង នេះជាការល្អ។ លោកសាក្សី បន្ទាប់ពីភ្នំពេញត្រូវបានដណ្តើមកាន់កាប់បាន គឺនៅក្រោយថ្ងៃ១៧ មេសា ៧៥ តើលោកនៅបន្តការងារជាអ្នកបញ្ជូនសារ យកសារហ្នឹងមកភ្នំពេញទៀត ឬមួយក៏យ៉ាងណា?

**ឆ៖** បាទ ក្នុងប្រហែលអំឡុងពេលដែលបីខែ ១៧ មេសា ប្រហែលមើល៍ ប្រហែលៗជាខែ៨, ខែ៧ ខែ៨ ចុះ ក្នុងអំឡុង ចន្លោះប៉ុណ្ណឹង ខែ៧ ខែ៨។ ពេលហ្នឹង បានដកទូរលេខពីលើយកមកភ្ជាប់ជាមួយគាត់ហើយ ភ្ជាប់ជាមួយនឹង តាញឹម ហើយ។ ដកពីមន្ទីរមក គឺមានឡាន អង្គាល់នុ៎ងបានឡានបានទាហាន លន់ នល់ ហ្នឹង ដាក់ទូរលេខមួយគ្រឿង ហើយបុគ្គលិកប្រើប្រាស់ទូរលេខហ្នឹង មួយគ្រឿង គឺគាត់ទៅណា ឡានហ្នឹងចល័តទៅតាមគាត់ជាប់ បាទ។

[១៦:១៣:៤៨]

**ស៖** សូមទោស ខ្ញុំចង់សួរលោក ថាតើលោកធ្លាប់ធ្វើដំណើរទៅភ្នំពេញ គឺថាលោកយកសារពីរស់ ញឹម ទៅភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់យកមកភ្នំពេញ។ យកសារ និងយកអង្ករ យកផ្លែឈើ ហើយធុរេន ផ្លែសាម៉ារពីប៉ៃលិនមកបាទ។

**ស៖** លោកសាក្សី នៅពេលដែលលោកបញ្ជូនសារហ្នឹង ថាតើលោកយកសារហ្នឹង មកដល់ហើយ តើលោកឲ្យទៅអ្នកណា?

**ឆ៖** បាទ កាលពីខ្ញុំមកនៅបញ្ជូនសារយកមកហ្នឹង គឺមកឲ្យឈ្មោះ ប៉ង់ៗ។ ព្រោះភូមិភាគពាយ័ព្យហ្នឹងវាមានកន្លែងនីរសារវាមួយនៅមុខវាំង ផ្ទះនៅមុខវាំង ពីខាងជើងមុខវាំងហ្នឹង មានផ្ទះហ្នឹងមួយសម្រាប់ទទួលសារទៅមក។ មកហ្នឹងគេដាក់ឈ្មោះ ដាក់លេខៗ ទូរស័ព្ទ មាន អង្គាល់នុ៎ង គេមានប្រើទូរស័ព្ទរវៃ។ អ៊ីចឹង បើសារដាក់មកឈ្មោះ ប៉ង់ គឺហៅមានលេខទូរស័ព្ទឈ្មោះ ប៉ង់។ ហ្នឹងរវៃតាមហ្នឹងទៅគាត់មកយក ហើយអង្ករយកមក ឲ្យទៅឈ្មោះ ប៉ង់ ផ្លែឈើដែលយកមកក៏ឲ្យទៅឈ្មោះ ប៉ង់។

**ស៖** តើលោកធ្លាប់មនុស្សជាក្រុមមកជាមួយលោកមកភ្នំពេញដែរឬទេ?

**ឆ៖** បាទ អត់ដែលនាំជាក្រុមទេ។ បើមកជាក្រុមមានតែមកតែនាំតាៗគាត់មកសន្និបាតហ្នឹងឯងបាទ។

**ស៖** តើលោកធ្លាប់ដឹកជញ្ជូនប្រជាជនកម្ពុជាក្រោមមកទេ?

**ឆ៖** សុំសំណួរម្តងទៀត។ ដឹកកម្ពុជាក្រោមពីណាទៅណាបាទ សុំសំណួរម្តងទៀត។

[១៦:១៦:៤៥]

**ស៖** ខ្ញុំគ្រាន់តែចង់សួរថា លោកធ្លាប់ដឹកប្រជាជនកម្ពុជាក្រោម ខ្មែរកម្ពុជាក្រោមហ្នឹងឆ្លងកាត់ទីក្រុងភ្នំពេញ ឬក៏មកក្បែរទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ដឹកបានមួយជើង មិនមែនធ្លាប់ដឹកទេ ខ្ញុំជូន ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវិញ។ នៅពេលនោះ អង្គការគេថាបញ្ជូនត្រឡប់ទៅប្រទេសវិញ។ បញ្ជូនតាមខ្សែកាណូតពីសាលាតាអន បាត់ដំបង តាមផ្លូវទន្លេសាបមកភ្នំពេញ មកយកសំបុត្រពី ប៉ង់ បន្តទៅក្អមសំណ។ ខាងក្អមសំណគ្នាប៉ុន្មាននាក់អ៊ីចឹងទៅ ប៉ង់ ចារបន្ថែម ឬប្រគល់ទៅខាងភាគីវៀតណាម ទាំងមនុស្សទាំងទូក។ ទូក គឺទូករបស់ជនជាតិវៀតណាមហ្នឹង ហើយកាណូតដែលអូសទៅ គឺកាណូតរបស់កងទ័ពជើងទឹកតំបន់៤។ ខ្ញុំជូនទៅបានមួយជើង បាទ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកនាំសារពី រស់ ញឹម ទៅ ប៉ង់ ហើយក្នុងពេលនុ៎ង លោកបានទទួលសារពី ប៉ង់ ហើយបញ្ជូនទៅវៀតណាម។ តើ ប៉ង់ មានតួនាទីអ្វីដែរ? តើលោកអាចជម្រាបបានទេថាតើ ប៉ង់ មានឋានៈអ្វីដែរនៅក្នុងឋានានុក្រមនុ៎ង?

**ឆ៖** បាទ ខ្ញុំដឹងមិនច្បាស់ដែរទេ ប៉ុន្តែអង្គាល់ហ្នឹងគេហៅថាប្រធានមន្ទីរ។ បាទ ប្រធានមន្ទីរ។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ លោកសាក្សីប្រហែលជាអត់ដឹងច្បាស់អំពីតួនាទីរបស់ ប៉ង់ ប៉ុន្តែ ខ្ញុំសុំយោងទៅលើកថាខណ្ឌពី១១, ១២, ១៤ នៅក្នុងសាលក្រម និងកថាខណ្ឌ៨៨៣ ទាក់ទងទៅនឹងតួនាទីរបស់ ប៉ង់។ សូមអរគុណ។

ឯកឧត្តមប្រធាន ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសុំបន្ថែមថា ប៉ង់ ក្រោយមកត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ដោយសារទោសក្បត់។

**លោក គង់ សំអុន៖**

ឯកឧត្តមប្រធាន ខ្ញុំសុំធ្វើការកត់សម្គាល់ខ្លីមួយ។ តាមសក្ខីកម្មរបស់សាក្សីអម្បាញ់មិញនេះ

លោកមិនបាននិយាយថា ប៉ង់ ផ្ញើសារទៅវៀតណាមទេ គឺជាការសរសេរបន្ថែមលើការអនុញ្ញាតដើម្បីឲ្យមានទំនាក់ទំនងទៅខាងព្រំដែនបន្តទៀត តាមសម្តីរបស់សាក្សី។ បាទ សូមអរគុណ។

[១៦:២០:១៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ បើអ៊ីចឹងខាងមេធាវី ហើយនិងសហព្រះរាជអាជ្ញា ព្រមទាំងមេធាវីនាំមុខអស់សំណួរហើយ គឺសូមឆ្លងចូលដល់សំណួររបស់ចៅក្រម។

អ៊ីចឹងសូមលោកស្រីចៅក្រម ម៉ុម បា ជាអ្នកផ្តើមសួរមុន។ បាទ សូមអញ្ជើញ!

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណឯកឧត្តមប្រធាន។

**សួរដោយចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរពីរបីទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ សំណួរទី១ គឺថា តើលោកបានឃើញអំពីការប្រជុំដែលធ្វើឡើងនៅទីរួមខេត្តពោធិ៍សាត់ ដែលនៅក្នុងការប្រជុំហ្នឹង អតីតទាហាន ហើយនិងអ្នករដ្ឋការរបបនល់នល់ ត្រូវបានគេប្រមូលផ្តុំដែរឬទេ? គឺខ្ញុំនិយាយក្រោយពេលរំដោះ។ តើលោកបានឃើញអំពីហេតុការណ៍នេះទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានឃើញទេ បាទ។

**ស៖** ដោយសារតែលោកមិនបានឃើញហេតុការណ៍នេះ អ៊ីចឹងប្រហែលលោកជាមិនដឹងថាតើអ្នករដ្ឋការហ្នឹងមានឋានន្តរសក្តិ ឬក៏មានឋានៈអ្វីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះខ្ញុំមិនបានដឹង ហើយក៏មិនដឹងថាគេប្រជុំនៅពេលណាដែរ បាទ។

[១៦:២១:៣៨]

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណលោកសាក្សី សូមអរគុណឯកឧត្តមប្រធាន ខ្ញុំអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម ម៉ុង មុន្នីចរិយា!

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បាទ សូមអរគុណឯកឧត្តមប្រធាន។

**សួរដោយចៅក្រម ម៉ុង មុន្នីចរិយា៖**

**ស៖** សំណួររបស់ខ្ញុំគឺទាក់ទងនឹងបញ្ហាបទពិសោធន៍ផ្ទាល់ខ្លួនរបស់សាក្សី ដោយសារតែលោកធ្លាប់ជានីរសារ ហើយក្រោយមកក៏បានក្លាយទៅជាសេនាធិការរងរបស់ភូមិភាគ។ អ៊ីចឹងតើតាំងពីលោកកាន់ការងារនេះ ទាំងនីរសារក្តី រហូតដល់ក្រោយឆ្នាំ៧៥ យើងបានក្លាយខ្លួនទៅជាសេនាធិការរងក្តី មានដែលបានធ្លាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីគោលនយោបាយរបស់ ហៅថា កម្ពុជាប្រជាធិបតេយ្យហ្នឹងទេ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ អត់ដែលបានចូលរួមទេ តែការស្តាប់ឮ វាមាន ដែលគាត់បង្រៀនកម្មាភិបាលតំបន់ ភូមិភាគគេរៀន ថ្នាក់តំបន់ ថ្នាក់ស្រុកអីហ្នឹង គឺពួកខ្ញុំតែងតែទៅជាប់ជាមួយគាត់ដើម្បីរត់សារហ្នឹង គឺថាស្តាប់ឮ មានបណ្តុះបណ្តាល ប៉ុន្តែខ្លឹមសារយ៉ាងម៉េច គឺខ្ញុំអត់ដឹងទេ។

[១៦:២៣:៣៥]

**ស៖** អ៊ីចឹងការឮនេះមានន័យថា លោកឮអំពីហៅថា របៀបនៃការបង្រៀន របៀបនៃការប្រាប់របស់បុគ្គលណាមួយចំពោះមន្ត្រីនៅក្រោមឱវាទរបស់ខ្លួន នៅក្នុងមូលដ្ឋានដែលលោកបានបំពេញការងារនោះ?

**ឆ៖** មិនយល់សំណួរលោកចៅក្រមទេ។

**ស៖** លោកនិយាយថា បានឮ ប៉ុន្តែអំមិញ ចម្លើយរបស់លោកថាបានឮ ប៉ុន្តែលោកមិនបានដឹងខ្លឹមសារ។ តើលោកបានឮមានន័យថាម៉េច លោកបានឮអំពីខ្លឹមសារនៃការផ្សព្វផ្សាយគោលនយោបាយដែរ ឬក៏លោកបានឮថាម៉េច សូមលោកបញ្ជាក់បន្តិច?

**ឆ៖** បាទ បានឮ បានដឹង ព្រោះពេលការផ្សព្វផ្សាយគោលនយោបាយហ្នឹង គឺមេៗភូមិភាគហ្នឹងគាត់អ្នកផ្សព្វផ្សាយ ហើយខ្ញុំទៅណា ទៅជាប់ជាមួយគាត់ហ្នឹង ជាអ្នករត់សារ អ៊ីចឹងដឹង។ មានវគ្គបីថ្ងៃ មានវគ្គពីរថ្ងៃ ការបង្រៀនរបស់គាត់។ ជួនកាលម៉ែអ៊ីចឹងទៅ តារស់ ញឹម គាត់បង្រៀនទៅ។ ពីរថ្ងៃទៅតាគី គាត់បង្រៀនទៅ។ អ្នកបង្រៀន ធម្មតាមានតែពីរនាក់ហ្នឹងទេ ដែលបង្រៀន បំពាក់បំប៉នអីនោះ ហើយ តាប៉ែត គាត់អត់មានសមត្ថភាពនៃការបង្រៀនទេ បាទ។ តាតុំ ក៏អ៊ីចឹងដែរ។

**សៈ** ទាក់ទងទៅនឹង -- បើលោកបានដើរជាមួយពួកគាត់ លោកពិតជាបានដឹងខ្លះហើយ សួរថា តើនៅក្នុង ទាំងមុន១៩៧៥ រហូតដល់ក្រោយ ១៧ មេសា ១៩៧៥ ថាតើលោកដឹងទេ អំពីរបៀបនៃការអនុវត្តបទបញ្ជារបស់ថ្នាក់លើ ឬក៏ថ្នាក់បន្តបន្ទាប់?

[១៦:២៥:៤១]

**ឆៈ** មុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ គឺការបង្រៀនរបស់គាត់និយាយពីបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ហ្នឹងគោលដៅសំខាន់នៃការរៀនសូត្រពីរំដោះប្រទេសជាតិ ធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ កាលពេលនុ៎ង។ ដល់តែក្រោយរំដោះ៧៥ ក្រោយពីមកសន្និបាតនៅភ្នំពេញហើយ បានបង្រៀនថ្នាក់តំបន់ គាត់បង្រៀន។ តាញឹម អ្នកបង្រៀន មួយកន្លែងម៉្ងៃ, តាគី ពីរថ្ងៃ។ ហ្នឹងខ្ញុំបានជូនគាត់ទៅកន្លែងបង្រៀនហ្នឹង គឺពីរកន្លែង។ "និយាយពីបដិវត្តន៍ ដូររបបហើយ ដូរពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យមកបដិវត្តន៍សង្គមនិយម មហាលោតផ្លោះ មហាអស្ចារ្យ" គេនិយាយអ៊ីចឹង។ ហើយអត់មានឃុំទៀតទេ គឺបង្កើតសហករណ៍។ និយាយពីសហករណ៍ ហើយខ្ញុំក៏មិនយល់ថាយ៉ាងម៉េចដែរ។ អាហ្នឹង គឺខ្លឹមសារដូចជាមិនដឹងថាន័យវាយ៉ាងម៉េច ហើយក៏ជាទូទៅ ឯកសារ ឬក៏ការនិយាយ បង្រៀនបន្ត ខ្ញុំក៏អត់ដឹងដែរ ប៉ុន្តែឮអ៊ីចឹង។ សូមអស់បាទ។

**សៈ** ចុះលោកមានបានជ្រាបទេ អំពីរបៀបនៃការអនុវត្តសេចក្តីសម្រេចផ្សេងៗ ថាតើថ្នាក់ណាអាចសម្រេចបែបណា ថ្នាក់ណាអាចសម្រេចបែបណាបាន។ មានបានដឹងពីបញ្ហាហ្នឹងទេ?

**ឆៈ** បាទ អត់បានដឹងដែរ បាទ។ គ្រាន់តែដឹងថា អ្នកណាខាងស្បៀង គឺចាត់ចែងស្បៀង។ អ្នកណាខាងកម្លាំង ចាត់ចែងកម្លាំង។ ដឹងថាបែងចែកគ្នាដាច់ៗអ៊ីចឹង អត់មានលូកលាន់គ្នាទេ។ កាលនោះមានរបបចាត់តាំង វាមានពីរ។ វាមានស្នងការ។ ស្នងការហ្នឹងគឺលេខា។ ព្រោះក្នុងកងទ័ព គេហៅថា ស្នងការ និងបញ្ជាការ។ ស្នងការហ្នឹង គេខាងចាត់តាំងហើយ មេធំហើយ។ ហើយបញ្ជាការហ្នឹង ខាងគ្រប់គ្រង ដឹកនាំវាយ។ ហើយនៅភូមិភាគក៏ដូចគ្នា មានលេខាបក្ស ភូមិភាគ វាមានអនុលេខា វាមានបញ្ជាការភូមិភាគ។ គេចែកគ្នាអ៊ីចឹង បាទ។

[១៦:២៩:០៣]

**សៈ** ចុះមានដែល លោកមានដែលឮទេ អំពីការផ្សព្វផ្សាយអំពីគោលនយោបាយនៃការថា ចាប់ខ្លួនរបស់មនុស្សក្នុងសង្គមនោះ មានបានន័យថា អ្នកដែលធ្វើខុសជាមួយនឹងគោលនយោបាយបក្សហ្នឹង តើថ្នាក់ណាអាចចាប់បានយ៉ាងម៉េច សម្រេចអំពីការចាប់ខ្លួន? ឬក៏គាត់មានដែលនិយាយទេ ពីគោល

នយោបាយចំពោះទាហានរបស់សម័យ លន់ នល់ ដែលត្រូវបាន គេហៅថាក្រោយពីជ័យជម្នះថ្ងៃទី១៧ មេសា នោះ?

**ឆ៖** បាទ នៅកន្លែងនេះខ្ញុំក៏វាមិនយល់ដែរ ហើយខ្ញុំក៏មិនដឹងដែរ តែបានឃើញការជម្លៀសចេញ ការប្រមូលម្ដុំបញ្ជូនមកទទួលសម្ដេច ទៅទាំងឡានអីចឹង។ ខ្ញុំឃើញ ហើយថ្នាក់ណាសម្រេច គឺខ្ញុំអត់ដឹងដែរ។ ហើយការចាប់មនុស្សនៅក្នុងថ្នាក់កម្មាភិបាលទាំងនោះ គឺខ្ញុំមិនដឹងដែរ ប៉ុន្តែថាតាមខ្ញុំសួរ ពេលដែលខ្ញុំមកវិញសួរ ណាម, សួរ ខួង ម៉េចក៏ចាប់គ្នាអីចឹង អស់រលីងអីចឹង? ថាគេហៅមករៀននៅភ្នំពេញ ហៅមករៀនហ្នឹង គេថាចាប់ខ្លួនហើយអ្នកហ្នឹងក្បត់។

**ប្រធានអង្គជំនុំ៖**

បាទ សុំសម្រាកមួយនាទីដើម្បីប្ដូរ ឌីវីឌី បាទ។

*(សម្រាករយៈពេលខ្លី)*

បាទ សូមចៅក្រម ម៉ុង មុន្នីចរិយា បន្ត!

[១៦:៣១:៤០]

**សួរដោយចៅក្រម ម៉ុង មន្នីចរិយា៖**

**ស៖** ទាក់ទងនឹងអង្គហេតុមួយទៀតដែលលោកអះអាងអំពីការដែលលោកបានឃើញថាគេដឹកទាហាន លន់ នល់ទៅសម្លាប់នោះជាអង្គហេតុមួយ។ ប៉ុន្តែទីនោះ គឺមានចម្ងល់មួយ សួរថាតើក្រោយពីជ័យជម្នះ ១៧មេសា ហ្នឹង ទាហានទាំងនោះ គេយកទៅដាក់ម្ដុំឬយ៉ាងម៉េច បានជាគេអាចប្រមូលបាន?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ ពេលខ្ញុំឃើញ ពេលដែលកំពុងជិះឡានទៅ មិនដឹងថាគេប្រមូលយ៉ាងម៉េច ហើយឡើងឡានពីត្រឹមណាមក អត់ដឹងដែរ ព្រោះខ្ញុំឃើញនៅកំពង់ព្រះ ហើយចន្លោះពីមោងមកកំពង់ព្រះបាទ។ ឃើញឡើងឡានស្រែក "ជយោ!" អីចឹងទៅ ប៉ុនមិនថាគេយកត្រឹមណាមក ហើយប្រមូលយ៉ាងម៉េច គឺខ្ញុំអត់ដឹងដែរបាទ ហើយនៅកន្លែងណាគឺខ្ញុំអត់ដឹងដែរ។

**ស៖** ថាតើការដែលគេប្រមូលដឹកទាំងឡានៗនោះមានទាំង មានតែទាហាន បានន័យថាជាអ្នកដែលមានបណ្ដាស័ក្តិជាទាហានរបស់របបលន់ នល់ ឬក៏មានក្រុមគ្រួសាររបស់ពួកគាត់ទៅជាមួយដែរ?

**ឆ៖** បាទ ទៅតែទាហាន។

**ស៖** អម្បាញ់មិញលោកបានបញ្ជាក់ថា ឈ្មោះ ណូ ជាអ្នកប្រាប់លោកថា ជាអ្នក -- ទាហាន

លន់ នល់ ដែលបានដឹកទៅនោះគេសម្លាប់អស់ហើយ។ ថាតើឈ្មោះ ណូ នោះជានរណាដែរ? ហើយមានទំនាក់ទំនងយ៉ាងណាជាមួយនឹងលោក បានជាគាត់បានដឹងរឿងនេះច្បាស់?

**ឆ៖** ឈ្មោះ ណូ ហ្នឹងគឺកងការពារផ្ទាល់របស់ រស់ ញឹម ហ្នឹង។ មាន ខួង, មាន ណាម, ធួង, ណូ។ បួននាក់ហ្នឹងនៅការពារផ្ទាល់។ ហើយ ធួង ខាងច្រាស់ដុសធ្មេញ ខាងខោអាវ បោកគក់ខោអាវ។ ណាម ខាងទៅរកម្ហូប រកបន្លែ, ណូ ខាងដាំបាយ។ កងការពារ ប៉ុន្តែមានដាំបាយអីចឹង ជាមួយ ខួង។

[១៦:៣៤:៥៥]

**ស៖** អ៊ីចឹងលោកមានបានសាកសួរទេ ថាតើ ណូ ហ្នឹងដឹងពីណាមក? បានន័យថាដឹងពីតា រស់ ញឹម ឬក៏បានទទួលព័ត៌មានដោយផ្ទាល់ពីខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំអត់ដឹងថាគាត់ដឹងពីណាមកទេ ប៉ុន្តែពេលហ្នឹងគឺខ្ញុំដឹងតែ គឺខ្ញុំទៅដែលរអ៊ូច្រើនថា “ហ៊ឺ! ខំតស៊ូចង់ងាប់ មិនបានទទួលស្តេចនឹងគេ ឲ្យតែពួកទាហានលន់ នល់ទៅទទួលមុន” ហើយដល់រអ៊ូទៅ អាណូ ប្រាប់ខ្ញុំអ៊ីចឹងថា “គេយកទៅវាយចោលហ្នឹង”។ អ៊ីចឹងបានភ្ញាក់ព្រើតថា “ហ៊ឺ! បើៗសុំទៅដែរបែបគេវាយចោលដែរ” ព្រោះណូ ហ្នឹងវាអាយុប្រហាក់ប្រហែលខ្ញុំដែរបាទ។

**ចៅក្រម ម៉ុង មន្នីចរិយា៖**

បាទ អរគុណលោកសាក្សី សូមអរគុណឯកឧត្តមប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម សោម សិរិវឌ្ឍ។

**សួរដោយចៅក្រម សោម សិរិវឌ្ឍ៖**

**ស៖** លោកសាក្សី ខ្ញុំចង់ជម្រាបសួរលោកអំពីបទពិសោធន៍របស់លោកដែលកន្លងមកនេះគឺថា លោកមានលទ្ធភាពអាចអូសទាញប្រជាជនដែលនៅក្នុងសម័យរបបនោះគឺថា គេប្រើពាក្យថា “វាស់ដីឲ្យដើរ”នោះ ហើយកម្លាំងរបស់ប្រជាជនគេនាំគ្នាមកចូលរួមលោក តើលោកធ្វើការអូសទាញគេតាមរបៀបណា? សូមលោកជួយប្រាប់។ ហើយម្យ៉ាងទៀតនេះគឺថានៅក្នុងរបបនោះ វាមិនមានវិទ្យុផ្សាយសំឡេងណានឹងអាចធ្វើការផ្សព្វផ្សាយឲ្យប្រជាជនទាំងអស់ដឹងបានទេ តើម៉េចក៏លោកមានលទ្ធភាពអូសទាញបានប្រជាជនកាន់តែច្រើនឡើងៗ? សូមអរគុណ។

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ការអូសទាញប្រជាជនកាលនោះ គឺខ្ញុំអត់មានអូសទាញគាត់ទេ។ កងចលត័ក៏ខ្ញុំអត់

អូសទាញដែរ មុនដំបូង ខ្ញុំថាខ្ញុំទៅធ្វើចោរព្រៃ លួចអង្ករសហករណ៍ស៊ីទេ ហូបទេ លួចស្រូវ តែវាទើស មុខខ្ញុំ ហើយខ្ញុំក៏វាយផ្ការីកបន្តិចឲ្យវរៈ១៨ទៅ ពេលហ្នឹងវាល្បីៗ ថានៅក្នុងព្រៃមានទ័ព ហើយមានខ្ញុំដឹក នាំអ៊ីចឹង គេចេះតែទៅៗ រត់ទៅ ថានៅនេះក៏ងាប់ ទៅនោះមុននឹងងាប់ក៏បានស៊ីឆ្អែត ហើយមុនស៊ីឆ្អែតក៏ -- អ់! មុននឹងងាប់ក៏បានតដៃរត់គេចអ៊ីចឹង ចេះតែនាំគ្នារត់ទៅ ម៉្ងៃ ៤០០-៥០០, ១.០០០អ៊ីចឹងទៅ ១០០ អ៊ីចឹងទៅ រាល់តែថ្ងៃកងចល័ត ហើយប្រជាជនអ្នកណាមានរទេះ ក៏ទៅទាំងរទេះទៅ។ គឺខ្ញុំអត់បាន កៀងគរគាត់ទេ គឺគាត់ទៅតាម។ បាទអស់ហើយបាទ។

**ស៖** ខ្ញុំៗហាក់ដូចជានៅមានចម្ងល់ ពីព្រោះថាវាៗមិនមែនជាការងាយស្រួលទេ ដែលលោក បានលើកឡើងថា ប្រជាជនទៅទាំងរទេះដើម្បីចូលរួមនោះ។ តើវាបានតែតំបន់ដែលនៅជិតកន្លែង ដែល លោកកាន់កាប់ ឬក៏យ៉ាងម៉េច?

[១៦:៣៨:៥៥]

**ឆ៖** បាទ លោកចៅក្រម ខ្ញុំថាមុនដំបូងគឺវា -- ពេលដែលខ្ញុំវាយទៅហ្នឹង វារន្ទឺខ្ទរខ្ទារទៅ ដល់ប្រជាជនវាទៅតែតំបន់ដែលខ្ញុំវាយហ្នឹង គឺវាមានជាប់ព្រំប្រទល់គ្នាមានស្រុកបាត់ដំបង គេហៅ "បាត់ដំបងលើ" កាលហ្នឹង ស្រុកសង្កែ និងស្រុកគាស់ក្រឡ ស្រុកមោង។ អ៊ីចឹងវាជាប់ព្រំប្រទល់កៀក ដែលខ្ញុំវាយហ្នឹង ហើយបូកទាំងស្រុកសំឡូតមួយទៀត។ ដល់អ៊ីចឹងវាទៅ វាបាក់ទៅៗ វាទៅនោះ ខ្ញុំមាន -- វាមានអង្កររបស់ខ្ញុំ -- មានស្រូវ មិនមែនមានអង្ករទេ ខ្ញុំក៏ចេះចែកឲ្យហូបសិនទៅ ហើយបំបែក កម្លាំងឲ្យជូនៗពួកគាត់មកលួចស្រូវ បានបុកហូបអ៊ីចឹងទៅ គាត់ក៏ចេះតែខ្សឹបតគ្នាមក។ ហើយពេល ដែលកងចល័តទៅបានច្រើនទៅ ហើយទាហានគេលត់ដំមន្ទីរកកោះ យកទៅច្រកករកា។ អាហ្នឹង គឺខ្ញុំ ទាក់ទងបានទាំងមេទាំងកូន ថ្នាក់វរសេនាតូច ដែលគេមិនទាន់វាយចោលហ្នឹង ថ្នាក់កងអនុសេនាធំខ្លះ កងតូចខ្លះ។ ខ្ញុំក៏បំពាក់ពួកហ្នឹងឡើងវិញ បែងចែកទិសដៅការងារវាឡើងវិញ ហើយខ្ញុំក៏បានមកជួប តាមសហករណ៍ និងចៅហ្វាយស្រុកខ្លះ មិនចៅហ្វាយទេ វានៅសល់តែអនុនោះទេ អាប្រធានគេចាប់ អស់ហើយ លោកប្រធានគេចាប់អស់ហើយ។ អ៊ីចឹង ខ្ញុំប្រាប់ថា កុំទៅប្រជុំទៀត--

**ប្រធានអង្គជំនុំ៖**

លោកសាក្សី ឆ្លើយខ្លីៗបានហើយ ដូចជាមិនត្រូវការអីចម្លើយហ្នឹងវែងឆ្ងាយដល់ប៉ុណ្ណឹងពេកទេ គ្រាន់តែចៅក្រមគាត់សួរថា របៀបនៃការប្រមូលដើម្បីឲ្យគេចូលរួមក្នុងសកម្មភាពលោកអ៊ីចឹង ដូចវា វែងពេក។ ខ្ញុំមើលទៅ ដូចកាត់ខ្លះទៅ ព្រោះម៉ោងក៏ល្ងាចណាស់ហើយ។

[១៦:៤១:៣០]

**សួរដោយចៅក្រម សោម សិរិវឌ្ឍ៖**

**ស៖** ខ្ញុំមានសំណួរមួយទៀត ចង់ឲ្យលោកបញ្ជាក់អំពីពេលវេលា។ ខ្ញុំបានឃើញចម្លើយរបស់លោកថា លោកបានកៀងគរប្រជាជន រហូតដល់៧.០០០គ្រួសារ។ ហើយចង់សួរថា តើពេលហ្នឹង ជាពេលដែលវៀតណាមគេរំដោះ គេចូលមកក្នុងទឹកដីកម្ពុជាហើយ ឬក៏នៅក្នុងរបបដែល ឬក៏រយៈពេលមុនៗ ពេលវៀតណាមចូលមករំដោះ? សូមអរគុណ។

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ រយៈពេលមុន មុនថ្ងៃ៧មករា បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម មីឡាត បាទ!

**សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** សូមអរគុណ។ លោកសាក្សី លោកបានប្រាប់យើងថា លោកបានឃើញឡានដឹកទាហានលន់ នល់ ។ តើលោកប្រាប់បានទេ ថាលោកឃើញឡានដឹកប៉ុន្មានឡានដែរ?

[១៦:៤២:៤៩]

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ លោកស្រីចៅក្រមគឺ ដែលខ្ញុំឃើញប្រហែលជាវាយូរពេកហើយ ប្រហែលជាមិនតិចជាង១០ឡានទេ បាទ។

**ស៖** តើលោកៗឃើញឡានហ្នឹង គេដឹកទៅៗចេញទៅតែមួយជើងទេ ឬក៏ឡានហ្នឹង ត្រឡប់មកដឹកថែមទៀត ថែមជើងទៀត? តើលោកឃើញលក្ខណៈបែបណាដែរ?

**ឆ៖** បាទ ខ្ញុំឃើញទៅវាពីរលើក ពេលយប់មួយលើក ព្រលប់ៗ។ ហើយពេលពីថ្ងៃ ដែលខ្ញុំមកតាមផ្លូវជួបមួយលើក ហើយពេលយប់ ហើយព្រលប់ៗហ្នឹង កន្លែង តាញឹម គាត់នៅជាប់ឃ្លាតពីផ្លូវប្រហែលជា២០០ម៉ែត្រ ហើយខ្ញុំនៅឃ្លាតពីគាត់ប្រហែលជា៥០ម៉ែត្រ។ ឮសូរទៅមួយលើកទៀត ឮសូរមាត់ស្រែក “ជយោ! ជយោ! សម្តេចឪ!”ហ្នឹង។ ទៅមួយខ្សែឡានទៀត បាទពីរដង តែបានឃើញម្តងឮមាត់ស្រែក “ជយោ! សម្តេចឪ!” ម្តងបាទ។

[១៦:៤៤:៣២]

**ស៖** តើនៅក្នុងឡានទីមួយៗហ្នឹង មានមនុស្សប៉ុន្មាននាក់ជិះដែរ? លោកអាចប្រមើលមើល៍ថាមានប៉ុន្មាននាក់ដែរ ក្នុងមួយឡាន?

**ឆ៖** បាទ ខ្ញុំពិបាកសន្និដ្ឋានដែរ បើឡានដូតសំណាញ់ហ្នឹង ប្រហែលជាជាប់៤០នាក់ ៥០នាក់ជិះឈរៗតោងគ្នា ដែលខ្ញុំឃើញពីថ្ងៃ។ ហើយឡាន ហ្សេ.អឹម.សេ នោះ ប្រហែល២០នាក់ជាង បាទ។

**ស៖** តើអ្នកដែលជិះហ្នឹងគេមានពាក់ឯកសណ្ឋានដែរឬទេ?

**ឆ៖** បាទ មានពាក់ជាទាហាន តែខ្លះក៏ពាក់ស័ក្តិ ខ្លះក៏អត់មានពាក់ស័ក្តិ តែជាឯកសណ្ឋានទាហាន តែអត់មានកាំភ្លើងទេ។ កាំភ្លើងបានបោះចោលនៅតាមកន្លែងរៀងៗខ្លួនអស់ហើយ។

**ស៖** ខ្ញុំយល់ សូមអរគុណលោកសាក្សី។ ខ្ញុំនៅសំណួរមួយទៀត ហើយសូមអភ័យទោសប្រសិនបើសំណួរហ្នឹងវាសួរដដែលៗ ព្រោះថាសំណួរហ្នឹងត្រូវបានសួរដោយចៅក្រម ចរិយា រួចហើយប៉ុន្តែ ខ្ញុំមិនទទួលបានចម្លើយច្បាស់លាស់។ ដូច្នេះ ប្រសិនបើខ្ញុំយល់មិនខុសទេ តើលោកដឹង ឬក៏មិនដឹងអំពីគោលនយោបាយណាមួយដែលពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ ថាតើមានគោលនយោបាយអ្វីនិយាយថា ឲ្យៗយកចិត្តទុកដាក់ ឬក៏ឲ្យសម្លាប់ ឬក៏ឲ្យលើកលែងទាហានលន់ នល់ជាដើម។ តើលោកដឹងទេថា តើធ្លាប់មានគោលនយោបាយរបស់ខ្មែរក្រហមដែលលោកធ្លាប់ឮ? គឺគោលនយោបាយខ្មែរ-ក្រហមស្អីក៏ដោយទាក់ទងនឹងទាហានលន់ នល់។ តើលោកធ្លាប់ដឹងទេ?

[១៦:៤៦:៥២]

**ឆ៖** បាទ គោលនយោបាយខ្មែរក្រហម ខ្ញុំបានធ្លាប់ឮខ្លះៗ ប៉ុន្តែវាមិនច្បាស់លាស់ដែរទេ គឺគេថាគេកម្ទេច វាប៉ុណ្ណឹងបាទ។ "កម្ទេចពួកអតីតចក្រពត្តិ កម្ទេចពួកសក្តិភូមិ" អ៊ីចឹងទៅ ហ្នឹងឮអ៊ីចឹងទៅ។

**ស៖** តើលោកឮគោលនយោបាយហ្នឹងដោយរបៀបណាដែរ?

**ឆ៖** បាទ ដោយគេប្រជុំ ហើយខ្ញុំក៏នៅជិតកន្លែងគេប្រជុំ។

**ស៖** តើអ្នកណាជាអ្នកប្រាប់លោក?

**ឆ៖** បាទ អត់មានអ្នកប្រាប់ទេ ឮគេនិយាយអ៊ីចឹងតែម្តង ហើយអ្នកនិយាយហ្នឹងគឺ តាគឹ អ្នកនិយាយអ៊ីចឹង ពេលប្រជុំ។ ហើយកន្លែងប្រជុំនៅច្រាបក្រសាំង ខាងលិចបាត់ដំបង។

**ស៖** នៅពេលណាដែរការប្រជុំនោះ?

**ឆ៖** បាទ ក្រោយពេលរំដោះប្រហែលជាជិតមួយខែ។ មុនៗគាត់ឡើងមកសន្និបាតនៅភ្នំពេញ។

**ស៖** អ៊ីចឹង ក្រោយពេលរំដោះ ប៉ុន្តែមុនសន្និសីទនៅភ្នំពេញ។ អ៊ីចឹង តើវាមុនឬក្រោយពេល

ដែលលោកឃើញឡានដឹកមនុស្សទៅនុំង?

**ឆ៖** ក្រោយពេលដែលឃើញឡានដឹកមនុស្សទៅ ពេលហ្នឹងគឺក្រោយពេលហ្នឹង បាទ។

**ស៖** ហើយតើអ្នកណាខ្លះចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះ -- នៅក្នុងកិច្ចប្រជុំនោះ? តើមានអ្នកមកពីមជ្ឈិមដែរឬទេ? តើមានអ្នកមកពីភូមិភាគដែរឬទេ?

[១៦:៤៩:៥២]

**ឆ៖** បាទ អ្នកចូលប្រជុំហ្នឹង គឺមាន តាញឹម ជាអធិបតីហ្នឹង គណៈភូមិភាគហ្នឹង ហើយតាកឺ ហើយអ្នកអគ្គាធិប្បាយហ្នឹង ហើយតាប៉ែត, តាសាយ, តាវ៉ាញ, តាតុំ, តាហ៊ីង, តាស៊ុយ, តាស៊ូ ប្រធានៗតំបន់បាទ។

**ស៖** ថាតើគោលនយោបាយហ្នឹងត្រូវបង្ហាញថាជាគោលនយោបាយរបស់ រស់ ញឹម ឬក៏ជារបស់អ្នកណាផ្សេងទេ?

**ឆ៖** ថាថ្នាក់លើ គោលនយោបាយថ្នាក់លើ ថ្នាក់លើបញ្ជា។

**ស៖** ដូច្នេះលោកបាននិយាយអំពីការប្រជុំ ដែលលោកបានឃើញដោយផ្ទាល់ ហើយលោកបានចូលរួមដោយផ្ទាល់។ អ៊ីចឹងមែនទេ? ឬក៏លោកស្តាប់ឮ -- ឬក៏គ្រាន់តែលោកបានស្តាប់ឮការប្រជុំហ្នឹងដោយអ្នកដទៃប្រាប់ទេ?

**ឆ៖** បាទ នេះគឺខ្ញុំស្តាប់ឮទេ ខ្ញុំមិនបានចូលរួមប្រជុំទេ ដោយសារផ្ទះពីរជាន់ ផ្ទះឈើ ផ្ទះក្បឿង គាត់ប្រជុំនៅខាងលើ ពួកខ្ញុំនៅខាងក្រោម នៅខាងក្រោមផ្ទះហ្នឹង បាទ ហើយខ្ញុំស្តាប់ឮ។

**ស៖** លោកនិយាយថា ថ្នាក់លើ។ តើពាក្យ "ថ្នាក់លើ"ហ្នឹង លោកយល់យ៉ាងម៉េចដែរ? ថាតើអ្នកណាដែរ?

**ឆ៖** បាទ បើថ្នាក់លើភូមិភាគ មានតែមកមជ្ឈិមទេបាទ ព្រោះភូមិភាគនិយាយអ៊ីចឹងបាទ។

**ស៖** តើគេមាននិយាយឲ្យចំឈ្មោះអ្នកណាម្នាក់ដែរទេ?

**ឆ៖** បាទ អត់មានទេ និយាយតែថ្នាក់លើទេបាទ។

[១៦:៥៣:២៧]

**ស៖** តើនិយាយដោយ រស់ ញឹម មែនទេ?

**ឆ៖** និយាយដោយ តាកឺ បាទ។

**ស៖** តាកឺ អ៊ីចឹង? តើលោកចង់និយាយអីបន្ថែមទៀត សូមអញ្ជើញលោកសាក្សី!

**ឆ៖** បាទ ព្រោះ តាគី អ្នកអត្ថាធិប្បាយ។ តាញឹម គាត់នៅហ្នឹងទាំងអស់គ្នាហ្នឹងឯង ជុំគ្នា។ បាទ មានប៉ុណ្ណឹង បាទ។

**ស៖** តើលោកយល់ថា អ្នកដែលចូលរួមក្នុងកិច្ចប្រជុំទាំងអស់ហ្នឹង គេឯកភាពជាមួយគោលនយោបាយហ្នឹង ឬក៏អត់ទេ?

**ឆ៖** បាទ ក្នុងហ្នឹងគឺ ក្រោយមក ក្រោយពីរថ្ងៃ គឺពួកគាត់ ដែលខ្ញុំស្ដាប់ឮ គាត់ថាគាត់នឹងតស៊ូជាមួយមជ្ឈិម មិនឲ្យសម្លាប់ និងមិនឲ្យ -- និងឲ្យប្រជាជនវិលត្រឡប់ទៅនៅផ្ទះសម្បែងវិញ មិនឲ្យទៅនៅដេកដីទេ។ បានក្រោយមក បាននាំគ្នាមកប្រជុំនៅមជ្ឈិម មកសន្និបាតនៅមជ្ឈិមទៅ បាទ។

**ស៖** តើសន្និបាតមួយណាដែរ?

**ឆ៖** ដែលខ្ញុំបានជូនគាត់មកម្ដងហ្នឹង បាទ។

[១៦:៥៥:៤៥]

**ស៖** សូមលោកកែខ្ញុំ ប្រសិនបើខ្ញុំនិយាយខុស។ គឺថាមុនពេលដែលមានសន្និសីទហ្នឹង អ្នកខ្លះគាត់បញ្ចេញយោបល់ ឬក៏បញ្ចេញ បង្ហាញអារម្មណ៍ថា គួរតែអនុញ្ញាតឲ្យទាហានលន់ នល់ ត្រឡប់មកវិញ។ បានន័យថា ឲ្យទាហានលន់ នល់ ចូលរួមក្នុងសង្គមវិញ។ តើអ៊ីចឹងមែនទេ? ហើយបន្ទាប់មក គឺគេបានប្រកាសអំពីគោលនយោបាយនៅក្នុងសន្និសីទហ្នឹង តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ក្នុងបំណងរបស់ភូមិភាគ មេៗភូមិភាគ និងមេតំបន់ គេចង់ឲ្យទាហានហ្នឹង កុំឲ្យមានសម្លាប់តទៀត ហើយប្រជាជនហ្នឹងឲ្យវិលត្រឡប់ទៅនៅផ្ទះសម្បែងវិញ។ ហ្នឹងគោលបំណងរបស់ភូមិភាគ របស់មេៗភូមិភាគ និងមេតំបន់ បាទ ហើយឲ្យមានលុយចាយ លុយមានហើយ ចាប់ផ្ដើមបោះហើយ និយាយអ៊ីចឹង។

**ស៖** សូមអរគុណលោកសាក្សី។ សូមអភ័យទោស ខ្ញុំនៅសល់មួយសំណួរទៀត។ តើលោកធ្លាប់ឮអំពីការដកខ្លួនចេញពីគោលនយោបាយហ្នឹងដែរឬទេ? តើមានការបញ្ជាឲ្យ មានការបញ្ជូនគោលនយោបាយ ឬក៏ឲ្យមានការផ្សព្វផ្សាយគោលនយោបាយហ្នឹងសាជាថ្មីដែរឬទេ នៅពេលក្រោយ?

**ឆ៖** បាទ ខ្ញុំអត់បានឮទេ បាទ។

[១៦:៥៧:០២]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម យ៉ា ណារិន។

**ចៅក្រម យ៉ា ណារិន៖**

បាទ អរគុណលោកប្រធាន។

**សួរដោយចៅក្រម យ៉ា ណារិន៖**

**ស៖** លោកសាក្សី នៅពេលនេះ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក ប៉ុន្តែសំណួរខ្ញុំ សូមកុំឆ្លើយវែងពេក ហើយខ្ញុំសួរជាខ្លីៗទេ។ ដើម្បីកុំឲ្យមានខាតពេលយូរ ហើយឥឡូវយើងម៉ោងប្រាំហើយ។ សំណួរខ្ញុំទី១ តើមន្ទីរ៥៦០ ជាមន្ទីរអ្វី?

**លោក ទាត់ ធឿន៖**

**ឆ៖** មន្ទីរ៥៦០ ហ្នឹង គឺខ្ញុំមិនទាន់ដឹង ក៏មិនដឹងច្បាស់លាស់ដែរ ប៉ុន្តែបានបាត់ ដូរឈ្មោះ ប្រហែលជាដូចឈ្មោះពីមន្ទីរលេខ២០ មក៥៦០ បាទ។

**ស៖** តើមន្ទីរហ្នឹងស្ថិតនៅក្រោមអ្នកណា?

**ឆ៖** បាទ នៅភូមិភាគ បាទ។

**ស៖** តើមន្ទីរ៨៧០ ជាមន្ទីរស្អី?

**ឆ៖** មន្ទីរ៨៧០ គឺនៅមជ្ឈិម – នៅតាប៉ង់ បាទ។

[១៦:៥៩:៤៣]

**ស៖** តើអ្នកណា -- តើមន្ទីរ៧៨០ ស្ថិតនៅក្រោមអ្នកណា?

**ឆ៖** បាទ ខ្ញុំមិនដឹងថាស្ថិតនៅក្រោមអ្នកណាទេ ព្រោះវានៅភ្នំពេញបាទ។ ដឹងថា ប៉ង់ នៅប្រធានមន្ទីរ។

**ស៖** នៅពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ពេលនោះលោកជានីរសារ។ តើលោកធ្លាប់បាននាំសារពីមន្ទីរ៥៦០ ទៅ៨៧០ហ្នឹង ជាញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលនាំសាររបស់មន្ទីរ៥៦០ទេ ខ្ញុំនាំសារតែរបស់ តាញ៉ឹម ប៉ុណ្ណឹងទេបាទ– ផ្ទាល់ដៃរបស់ តាញ៉ឹមបាទ មក ប៉ង់ បាទ។

**ស៖** តើនាំសារផ្ទាល់ដៃពី រស់ ញ៉ឹម ទៅ ប៉ង់ ហ្នឹង តើ ប៉ង់ ទៅមន្ទីរ៨៧០ហ្នឹងមែនទេ?

**ឆ៖** បាទ វាមកភ្នំពេញនៅ -- ខ្ញុំយកមកដល់មុខវាំងហ្នឹង ខ្ញុំទូរស័ព្ទហៅ ប៉ង់ មកយកបាទ។

**សៈ** តើជាមធ្យមក្នុងមួយខែ ប្រហែលប៉ុន្មានៗសារដែរ បើសិនជានាំមកនោះ?

**ឆៈ** បាទ តាំងពីក្រោយពេលដកមន្ទីរលេខ២០ ចុះមក បំបែកលេខ២០ទៅ ខ្ញុំនាំមកបានពីរដង បាទ។

**សៈ** សំណួរខ្ញុំមួយទៀតគឺ តើនៅពេលណាដែលលោកនាំកងទ័ពរត់ចូលព្រៃ? ថ្ងៃខែឆ្នាំ ចាំដែរ ឬទេ?

**ឆៈ** បាទ ក្នុងឆ្នាំ៧៨ ប្រហែលជាពាក់កណ្តាលឆ្នាំ ឬក៏ជិតចុងឆ្នាំ ហ្នឹងប្រហែលជាជិតចុងឆ្នាំ ហើយ ព្រោះខែខ្ញុំមិនចាំបានទេ ពេលដែលនោះ គឺថាស្រូវចាប់ផ្តើមផើម រែកន្តោង មេៗ ស្រូវនាងមិញ ទន់ កាលពីដើមគេហៅ "នាងមិញទន់"នោះ បាទប្រហែលចុងឆ្នាំ៧៨ ក្រោយពេលខ្ញុំវាយហើយបាទ។

**សៈ** តើនៅពេលនោះ រស់ ញឹម នៅជាប្រធានភូមិភាគដែរឬទេ?

[១៧:០៣:០៩]

**ឆៈ** កាលពីខ្ញុំចេញទៅ គឺរស់ ញឹម នៅជាប្រធានភូមិភាគ។

**សៈ** តើ រស់ ញឹម ដែលធ្លាប់យកកម្លាំងទៅកម្ទេចពួកលោកដែរឬទេ?

**ឆៈ** បាទ អត់ដែលទេ ហើយក៏មិនដឹងថាគាត់ដឹង ឬក៏មិនដឹងដែរ ព្រោះខ្ញុំរៀបសម្ងាត់ដែរបាទ ប៉ុន្តែក្រោយមកបានគាត់ទៅសុំកម្លាំងខ្ញុំ ក៏ខ្ញុំសម្រេចចិត្តឲ្យទៅបាទ។

**សៈ** ពេលដែលលោកចូលទៅ លោកអះអាងថាលោកបានទៅប្រាប់ រស់ ញឹម។ តើពេលនោះ រស់ ញឹម មានប្រតិកម្មដែរឬទេចំពោះការនាំទ័ពចូលព្រៃនេះ?

**ឆៈ** បាទ គាត់ -- មិនមែនខ្ញុំប្រាប់គាត់ថាខ្ញុំនាំបះបោរទ័ពចូលព្រៃទេ ខ្ញុំថា "ខ្ញុំនឹងទៅធ្វើចោរព្រៃ ខ្ញុំមិនដេកឲ្យគេចាប់អារកទេ ហើយបើចង់សម្លាប់ខ្ញុំសម្លាប់ឲ្យហើយទៅ ខ្ញុំឲ្យគ្រាប់ភ្លើង ឲ្យទាំងកាំភ្លើង បាញ់ចុះ ហើយបើមិនបាញ់ខ្ញុំសម្លាប់ទេ បើខ្ញុំទៅហើយ គឺមិនបាច់តាមខ្ញុំទេ តែតាមខ្ញុំៗបាញ់ទាំងអស់ មិនថាអ្នកណាទេ ខ្ញុំទៅធ្វើចោរព្រៃ" បាទ ខ្ញុំប្រាប់អ៊ីចឹង ហើយគាត់ក៏អត់មានប្រតិកម្មអីទេបាទ។

**ចៅក្រម យ៉ា ណារិនៈ**

បាទ សូមអរគុណ សំណួរចប់ត្រឹមតែប៉ុណ្ណឹង អរគុណ។

[១៧:០៥:១១]

**លោក វ៉ិចទ័រ កូប៉េៈ**

លោកប្រធាន អនុញ្ញាតឲ្យខ្ញុំសូមសួរមួយសំណួរជាចុងក្រោយបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកដឹងទេថា ហេតុអ្វីបានជា រស់ ញឹម បញ្ជាឲ្យសម្លាប់ទាហាន លន់ នល់ ឆាប់ៗម្ល៉េះ ក្រោយពីរំដោះទីក្រុងពោធិ៍សាត់ និងបាត់ដំបងភ្លាមៗ? ហេតុអីក៏មិនរង់ចាំដូចអ្វីដែល សោម ភឹម បានធ្វើនៅភូមិភាគបូព៌ា គាត់ធ្លាប់បានចាប់ទាហានទាំងនេះ ហើយក្រោយមក ដោះលែងពួកគេ? ហេតុអ្វីបានជានៅពាយ័ព្យនេះ គឺថាចាប់ហើយ សម្លាប់អីលឿនម្ល៉េះ?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ បាទ។

**ដោយលោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ចប់ហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកចៅក្រម យ៉ាស៊ីញហ៍។

**សួរដោយចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេះ**

**ស៖** ដោយសារថាម៉ោងប្រាំហើយ ខ្ញុំមិនចង់ឲ្យលោកនៅយូរពេកទេ ខ្ញុំមានតែពីរសំណួរខ្លីៗទេ។ លោកបានឆ្លើយថា លោកបានផ្ដល់ទ័ព៣០០នាក់ ឲ្យការពារ រស់ ញឹម។ ដោយពិចារណាទៅលើថាគាត់ជាលេខាភូមិភាគ ជាប្រធានភូមិភាគ ហើយហេតុអ្វីក៏ចាំបាច់ត្រូវការជំនួយពីលោក?

**លោក ទាត់ ធឿន៖**

**ឆ៖** បាទ ទាហានជុំវិញគាត់ គេចាប់អស់ហើយ បាទ។

**ស៖** សូមអរគុណ។ មួយសំណួរទៀត។ លោកបានស្នើសុំឲ្យ រស់ ញឹម ទៅចូលគាត់ ចូលជាមួយលោកនៅក្នុងព្រៃ ហើយលោកមានកងទ័ព៤.០០០នាក់ ហើយប៉ុន្តែគាត់មិនបានចូលរួមទេ ដោយសារគេមិនទាន់ចាប់ខ្លួនគាត់នៅឡើយទេ ហើយគាត់មិនព្រមចូលជាមួយគាត់ទេ។ តើលោកអាចពន្យល់ឲ្យបានលម្អិតបានបន្តិចបានទេថា ហេតុអ្វីបានជាគេគាត់មិនទៅចូលរួមជាមួយនឹងលោក ដោយសារថាលោកមានបញ្ជាទ័ពដល់ទៅ៤.០០០នាក់ឯណោះ?

[១៧:០៧:៥៣]

**ឆ៖** បាទកន្លែងនេះគឺ ទ័ពដែលទៅជាមួយខ្ញុំហ្នឹង គាត់អត់ដឹងថាខ្ញុំបានកងទ័ពពីណាទេ ប្រហែលជាគាត់មិនជឿខ្ញុំ ក៏មិនដឹង ឬក៏គាត់ធ្វើយ៉ាងម៉េចទៀត សម្រេចចិត្តរបស់គាត់មិនដឹង ខ្ញុំមិនដឹងទេ ប៉ុន្តែគាត់ថាគាត់មិនៗទៅជាមួយខ្ញុំទេ បាទ។

**ស៖** ប៉ុន្តែ លោកបានស្នើឱ្យគាត់ទៅចូលរួមជាមួយនឹងលោក អ៊ីចឹងមែនទេ?

**ឆ៖** បាទ មុនពេលដែលខ្ញុំឱ្យកងទ័ព ៣០០នាក់មកគាត់ គឺខ្ញុំសូមឱ្យគាត់ទៅចូលរួមជាមួយខ្ញុំធ្វើមេដឹកនាំខ្ញុំ តស៊ូ។ ដល់គាត់អត់ទៅ គាត់ថាសុំត្រឹម ៣០០មកការពារខ្លួនសិន។ បាទ គាត់និយាយតែប៉ុណ្ណឹង។

**ស៖** គាត់ត្រូវបានចាប់ខ្លួន -- តើគាត់ត្រូវបានគេចាប់ខ្លួនភ្លាមៗ ក្រោយពីពេលលោកស្នើសុំឱ្យគាត់ទៅចូលរួមជាមួយលោកអ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ ក្រោយពេលដែលប្រហែលជា១០ថ្ងៃជាង ប្រហែលជា១០ថ្ងៃ ខ្ទង់ចន្លោះ១០ថ្ងៃ ទៅ ១៥ថ្ងៃហ្នឹងឯង ក្នុងចន្លោះហ្នឹងឯង បាទ។

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

សូមអរគុណ លោកសាក្សី។ ខ្ញុំអស់សំណួរហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង បើអស់សំណួរហើយ លោកសាក្សី ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាក្សីដែរ ដែលបានឆ្លៀតពេលវេលាពីកិច្ចរបស់លោកបានចូលរួមក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការកំពូលនេះ ហើយនៅពេលនេះ លោកអាចអញ្ជើញត្រឡប់ទៅវិញបាន។

ហើយយើងខ្ញុំក៏សូមប្រកាសជូនមេធាវីជនជាប់ចោទ និង ភាគីទាំងអស់ ព្រមទាំងសហព្រះរាជអាជ្ញាផងដែរថា សវនាការលើកក្រោយ អង្គជំនុំជម្រះនឹងសម្រេចទៅតាមដីការកំណត់កាលបរិច្ឆេទរបស់អង្គជំនុំជម្រះតុលាការកំពូលដែលនឹងធ្វើការសម្រេចនៅពេលក្រោយ។

អ៊ីចឹង នៅពេលនេះគឺយើងផ្អាកសវនាការនៅត្រឹមនេះ ហើយសូមអញ្ជើញលោកមន្ត្រីខាងពន្ធនាគារនាំជនជាប់ចោទទាំងពីរទៅពន្ធនាគារវិញ។

អ៊ីចឹង តុលាការសម្រេចផ្អាកសវនាការ៕

*(សវនាការផ្អាកនៅម៉ោង ១៧:១១ នាទី)*